00285850

Decalssified to Public
06 September 2012

E1/1.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premire instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩**

**កិច្ចប្រជុំរៀបចំសវនាការ(អសាធារណៈ)**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោក យ៉ា សាខន

លោកស្រី សែ កុលវុឌ្ឍី (ក្រឡាបញ្ជី)

កញ្ញា ណាតាចាក់ វិចស៊ែល (ក្រឡាបញ្ជី)

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា** ខាតវ៉ាយច៍

លោកស្រី ជា**លោក** ហ្សង់ ម៉ាកឡាវ៉ែន៍

លោក ធូ មណី

លោក យូរ ឧត្តរា

**មេធាវីសាលាដំបូង៖**

លោក លឹម សួយហុង

លោក ពេជ្រ **លេខ្យា** ម៉ាតូ គ្រីស្តារ

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក រ៉ូបឺត ពើទីត

លោក យ៉េត ចរិយា

លោក វាលៀម ស្មីត

លោក តាន់ សេណារ៉ុង

លោក អាឡិចសាន់ឌឺ ប៊ែត

លោក ជឹហ្គិន អាស្មាន

លោក ប៉ាក ចាន់លីណូ (ក្រឡាបញ្ជី)

**មេធាវីការពារជនត្រូវចោទ កាំង ហ្គេកអ៊ាវ ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រ៉ូ

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក គង់ ពិសី

លោក យុង ផានិត

លោក គឹម ម៉េងឃី

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី ស៊ីលឃីស្ទួត ហ្សឺនស្គី

លោក ម៉ាទីន ហ្សាកឃ្វីន (ហ្សាកកាំង)

កញ្ញា ទី ស្រីនណា

លោក អាឡាំង វ៉ែនណឺ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក សាន់ វ៉ាដា

# កិច្ចដំណើរការប្រជុំ

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអស់លោក លោកស្រីអង្គុយចុះ!

ជាបឋម ខ្ញុំសូមជម្រាបសួរឯកឧត្តម អស់លោក លោកស្រី នាងកញ្ញាដែលមានវត្តមាននាពេលនេះ ។ អនុលោមតាមតាមវិធាន ៧៩.៧ និងវិធានផ្ទៃក្នុង ដែលចែងថា "ដើម្បីសម្របសម្រួលដល់កិច្ចប្រព្រឹត្តទៅនៃកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តធម៌និងឆាប់រហ័ស អង្គជំនុំជម្រះសាលាដំបូង អាចពិគ្រោះយោបល់ជាមួយភាគីទាំងឡាយ ដោយធ្វើការប្រជុំរៀបចំសវនាការ ហើយដែលកិច្ចប្រជុំនេះត្រូវធ្វើជាអសាធារណៈ" ។ ហេតុដូច្នេះហើយទើបអង្គជំនុំជម្រះសាលាដំបូងរៀបចំឲ្យមានកិច្ចប្រជុំនាថ្ងៃនេះ និងថ្ងៃស្អែក ។

តាំងនាមឲ្យអង្គជំនុំជម្រះសាលាដំបូង ខ្ញុំសូមសម្តែងការស្វាគមន៍ចំពោះការអញ្ជើញចូលរួមរបស់ឯកឧត្តម លោក លោកស្រី នាងកញ្ញា ដែលជាសហព្រះរាជអាជ្ញា មេធាវីការពារជនជាប់ចោទ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងតំណាងអង្គភាពចំណុះការិយាល័យរដ្ឋបាលទាំងអស់ ដែលបានចូលរួមនាឱកាសនេះ ។

កិច្ចប្រជុំសវនាការនេះ គឺជាទស្សនៈថ្មីមួយដែលមិនមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាទេ ប៉ុន្តែការអនុវត្តស្រដៀងគ្នានេះ មានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាដែរ ដែលមានឈ្មោះថា "នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល" ។ គឺក្នុងន័យនេះ ដើម្បីជំរុញដំណើរការសវនាការឲ្យបានឆាប់រហ័សប្រកបដោយភាពយុត្តិធម៌ ។

កិច្ចប្រជុំនេះជាឱកាសល្អមួយសម្រាប់ពិភាក្សានិងផ្លាស់ប្តូរមតិយោបល់រវាងភាគីទាំងអស់នៃរឿងក្តីនិងអង្គភាពដែលពាក់ព័ន្ធ ដើម្បីសម្របសម្រួលផងដែរក្នុងការកំណត់កាលបរិច្ឆេទសវនាការដែលនឹងត្រូវធ្វើនាពេលខាងមុខ ។

អង្គជំនុំជម្រះសាលាដំបូងសង្ឃឹមថា ឯកឧត្តម លោក លោកស្រី អ្នកនាងកញ្ញា ពិតជាចូលរួមជួយជ្រោមជ្រែងអង្គជំនុំជម្រះសាលាដំបូងឲ្យដំណើរការមានភាពរលូន និងដោះស្រាយបញ្ហាមួយចំនួនរួមគ្នា ដូចមាននៅក្នុងរបៀបវារៈដែលបានគ្រោងទុក ហើយដាក់ជូនស្រាប់ ។

ខ្ញុំសូមប្រកាសបើកនូវកិច្ចប្រជុំចាប់ពីពេលនេះតទៅ ។

ជាកិច្ចបន្តសូមអញ្ជើញលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីវត្តមាននិងអវត្តមានអ្នក

ត្រូវបានអញ្ជើញមកចូលរួមនៅក្នុងកិច្ចប្រជុំនៅព្រឹកនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពតុលាការ! ថ្ងៃនេះអ្នកដែលចូលរួមមានវត្តមានដូចខាងក្រោម៖

សហព្រះរាជអាជ្ញា ជា លាង, លោក រ៉ូបឺត ពើទីត,លោក យ៉េត ចរិយា, លោក វាលៀម ស្មីត, លោក តាន់ សេណារ៉ុង , លោក ពេជ្រ សម្បត្តិ, លោក ជីហ៊្គិន អាស្មាន, លោក បូជែន លីសាក់, និង លោក ប៉ាក ចាន់លីណូ ។

ផ្នែកមេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖

លោកមេធាវី ហុង គីមសួន, លោក គង់ ពិសី, លោក យុង ផានិត, លោក គីម ម៉េងឃី, កញ្ញា ម៉ុច សុវណ្ណារី, លោកស្រី ស៊ីលឃីស្ទួតហ្សែនស្តី, លោក ម៉ាទីន ហ្សាកឃ្វីន, កញ្ញា ទី ស្រ៊ីនណា, លោក អាឡាំង វ៉ែនណឺ, លោក ប្រែអែនន៍ មីក កូនីហ្គូល, និង ស៊ីលប៊ីយ៍ ឌីសស្ទ័រ ។

ដើមបណ្តឹងរដ្ឋប្បវេណីដែលមានវត្តមានគឺ

លោក ប៊ូ ម៉េង, លោក ជុំ ម៉ី, លោក ទូច ម៉ូនីន, លោក សៀង វ៉ាន់ឌី, លោក ឃួន សារិន, ហើយនិង មាស កេត ។

មេធាវីការពារជនជាប់ចោទគឺមានវត្តមាន៖

លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច, លោកមេធាវី ការ សាវុត្ថ, លោក ហ្វ្រង់ស្វ័រ រូ, លោក ចាន់ វ៉ាវុធ, លោកស្រី ហេឡឺន យូណាក់, លោក ហ្សង់ម៉ារី ត្រេនទូល ។

ខាងអង្គភាពជនរងគ្រោះគឺ

លោកស្រី គាត បូផល, លោក បាឡាស់ ម៉ារ, ហង្ស វណ្ណៈ ។

ផ្នែកកិច្ចការសាធារណៈ គឺ៖

លោកស្រី ហេឡែន ចារីស ហើយនិង ម៉ៅ វុត្ថា ។

ផ្នែកអង្គភាពគ្រប់គ្រងតុលាការ៖

លោក តូនី ក្រាញ់, លោក អាល់ឌុលឡាក់ ថារីក, លោកស្រី វ៉ែនឌី ឡូវ៉ែន, លោក ក្លូត ប៊ូឆាត

លោក គង់ សុភី, លោកស្រី មីសែល ឃីធីង, លោក ស្កុត បាយវ៉តធ័រ, សាន់ វ៉ាដា, អ៊ុច អរុណា, កូវ កែវរតនៈ, ឆាល ម៉ារីយ៉ា, គ្រីស្តូហ្វ័រ ហ្វៃរ៍, ញ៉ែម សំណាង, ផាន់ សុជា, នង ឧត្តរា, កើត សុខា ។

និងផ្នែកគាំពារ ការពារក្តីគឺ៖

លោក រីឆាត រ៉ូជឺ, ហើយនិង ប៉ូលីន បារ៉ែន ។

សូមគោរពតុលាការ ខ្ញុំអស់ហើយ ។

**ប្រធានអង្គជំនុំ៖**

ចុះជនជាប់ចោទមានអញ្ជើញមកទេ?

**លោកស្រី សែ កុលវុឌ្ឍី៖**

ចាស! លោកកាំង ហ្គេកអ៊ាវ ហៅឌុច គាត់អញ្ជើញមក ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត មុននឹងចាប់ផ្តើមដល់របៀបវារៈកិច្ចប្រជុំ យើងធ្វើកិច្ចមួយគឺ ការទទួលស្គាល់មេធាវីអន្តរជាតិ ដោយមេធាវីជាតិ រវាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីជនជាប់ចោទ ។

ដើម្បីអនុវត្តតាមវិធានទី ២៣(ង) ចំណុច(ក) នៃវិធានផ្ទៃក្នុង ខ្ញុំសូមអញ្ជើញមេធាវីតំណាងជាតិដើមបណ្តឹងរដ្ឋប្បវេណី ក្រុមមួយ កញ្ញា ទី ស្រ៊ីនណា ឡើងស្នើសុំធ្វើការទទួលស្គាល់មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ក្រុមមួយ ។

**កញ្ញា ទី ស្រ៊ីនណា៖**

ជាបឋមនាងខ្ញុំឈ្មោះ-- សូមគោរពលោកប្រធានក្រុមប្រឹក្សា! នាងខ្ញុំឈ្មោះ ទី ស្រ៊ីនណា ជាមេធាវីជាតិ ដែលទើបទទួលស្គាល់ពីខាងអង្គជំនុំជម្រះវិសាមញ្ញកាលពីថ្ងៃទី៦ ខែ១ ឆ្នាំ ២០០៩ ហើយនៅក្នុងក្រុមនាងខ្ញុំមានមេធាវីអន្តរជាតិឈ្មោះ ខារីម ខាន, អាឡាំង វ៉ែនណឺ, ប្រៃអែនន៍ ។ ពួកខ្ញុំធ្វើការជាមួយគ្នា ដោយលោកមេធាវី ខារីម ខាន គាត់បានចុះបញ្ជីនៅគណៈមេធាវីរួចហើយ ប៉ុន្តែគាត់អត់ទាន់បានស្បថចូលទេ ដូច្នេះហើយ មានការយឺតយ៉ាវត្រង់បញ្ហាហ្នឹង ។ ហើយចំពោះអាឡាំង វ៉ែនណឺ ហើយនិង ប្រៃអែនន៍ គាត់ក៏បានចុះឈ្មោះរួចដែរ ហើយគ្រាន់ថាគាត់មិនទាន់បានស្បថទេ ហើយគាត់នឹងសង្ឃឹមថាបានស្បថនៅអាទិត្យក្រោយនេះ ។ ក្រុមមេធាវីរបស់ខ្ញុំមានគ្នាបួននាក់ទាំងរូបនាងខ្ញុំ ។

**ប្រធានអង្គជំនុំ៖**

ចំពោះការបង្ហាញអំពីមេធាវីជាតិ មេធាវីអន្តរជាតិ ដោយមេធាវីជាតិ ចំពោះក្រុមមួយនេះ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា ដោយបញ្ញត្តិនៃនីតិវិធីរដ្ឋបាល ដែលមានការបំពេញមិនទាន់គ្រប់ អីចឹងគឺយើងមិនទាន់ធ្វើការប្រកាសទទួលស្គាល់តាមនីតិវិធីដែលមានចែងនៅក្នុងវិធាន ២៣.ង

(ក) នោះទេ គឺយើងទុកលទ្ធភាពនេះសម្រាប់ដល់ពេលចាប់ផ្ដើមនីតិវិធីបន្តទៀត នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដើម្បីជូននាងដើម្បីធ្វើការបង្ហាញនូវមេធាវីអន្តរជាតិរបស់ខ្លួន តាមដំណាក់កាលនីមួយៗ ។

ជាកិច្ចបន្តគឺសូមអញ្ជើញមេធាវីជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្រុមពីរ លោក យ៉ុង ផានិត ឬលោក ហុង គីមសួន ដើម្បីឡើងធ្វើការសូមទទួលស្គាល់មេធាវីអន្តរជាតិ តំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី ក្រុងពីរ ។

**លោក ហុង គីមសួន៖**

ខ្ញុំបាទសូមគោរពលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះនិងអង្គសវនាការជាទីគោរព! ខ្ញុំបាទឈ្មោះ ហុង គីមសួន ជាមេធាវីជាតិ លោក យ៉ុង ផានិត ជាមេធាវីជាតិ លោក គង់ ពិសី ជាមេធាវីជាតិ នៅក្នុងសំណុំរឿង០០១ ។ សូមជម្រាបជូនលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះនៅក្នុងក្រុមរបស់យើងខ្ញុំមាន កញ្ញា ស៊ីលឃី ស្ទួតហ្វ៊ីនស្គី ជាមេធាវីអន្តរជាតិ ធ្វើការនៅក្នុងសំណុំរឿង០០១ ផងដែរ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោក ហុង គីមសួន ។ អញ្ជើញលោកស្រី ស៊ីលឃីស្ទួតហ្វ៊ីនស្គី អញ្ជើញឡើងបង្ហាញ អញ្ជើញក្រោកឈរបង្ហាញអង្គប្រជុំ ។

លោកស្រី ស៊ីលឃី ស្ទួតហ្វ៊ីនស្គី ឥឡូវនេះអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់លោកស្រី ជាមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី សម្រាប់គោលបំណងនៃកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនេះ ។ ដោយយោងទៅតាមការទទួលស្គាល់នេះ លោកស្រីមានសិទ្ធិនិងបុព្វសិទ្ធិដូចគ្នានឹងមេធាវីជាតិដែរ ។

ជាបន្តគឺសូមអញ្ជើញមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបី ក្នុងនេះគឺមានពីរនាក់ខាងភាគីជាតិ គឺ លោក គីម ម៉េងឃី និងកញ្ញា ម៉ុច សុវណ្ណារី ។ ពីរនាក់នេះអ្នកណាមួយក៏បាន គឺសូមអញ្ជើញស្នើឡើងសុំការទទួលស្គាល់មេធាវីអន្តរជាតិតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់ក្រុមបី ។

**លោក គីម ម៉េងឃី៖**

សូមគោរពលោកប្រធាន! ក្រុមមេធាវីខ្ញុំមកពីក្រុមមេធាវីគ្មានព្រំដែនប្រទេសបារាំង ហើយមានមេធាវីខ្មែរចំនួនពីររូប ។ ខ្ញុំ គីម ម៉េងឃី ហើយនិងមេធាវីខ្មែរមួយរូបទៀត កញ្ញា ម៉ុច សុវណ្ណារី ហើយនិងមានមេធាវីបរទេសចំនួនពីររូប គឺលោកស្រី ម៉ាទីន ហ្សាកកាំង ហើយនិងមួយរូបទៀតមិនបានចូល

រួមទេ គឺលោក ហ្វីលីព កាណុន ហើយនិងមានមេធាវីត្រៀមមួយរូបទៀត គឺលោកស្រី ហ្វាប៊ីយែន ទ្រីស គាត់នឹងត្រៀមចូលនៅក្នុងសំណុំរឿង ០០១ ហ្នឹងដែរ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីអន្តរជាតិ ម៉ាទីន ហ្សាកហ្វ៊ីន អញ្ជើញក្រោកឈរ! អរគុណ ។

អរគុណលោកមេធាវី គីម ម៉េងឃី លោកស្រី ម៉ាទីន ហ្សាកហ្វ៊ីន ឥឡូវនេះអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់លោកស្រីធ្វើជាមេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់គោលបំណងនៃកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនេះ ។ ដោយយោងទៅតាមការទទួលស្គាល់នេះ លោកស្រីមានសិទ្ធិ និងបុព្វសិទ្ធិដូចគ្នានឹងមេធាវីជាតិដែរ ។

ជាបន្តគឺក្រុមបួន សូមអញ្ជើញមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបួន លោក ហុង គីមសួន ដដែល ដើម្បីស្នើសុំទទួលស្គាល់មេធាវីអន្តរជាតិ តំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងក្រុមបួន ។

**លោក ហុង គីមសួន៖**

ខ្ញុំបាទសូមគោរពលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះម្តងទៀត! ក្រុមទីបួនរបស់មេធាវីជាតិ និងមេធាវីអន្តរជាតិក្រុមបួន មានខ្ញុំបាទមេធាវី ហុង គីមសួន ជាមេធាវីជាតិ និងលោកមេធាវី ព្យែរអូលីវី-យែស័រ មកពីប្រទេសបារាំង ប៉ុន្តែថ្ងៃនេះគាត់អវត្តមានមិនបានចូលរួម ។ ដូច្នេះសូមប្រធានទទួលស្គាល់គាត់ជាមេធាវីនៅក្នុងសំណុំរឿង ០០១ ផងដែរ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ដោយហេតុថា នៅពេលនេះយើងអវត្តមានមេធាវីអន្តរជាតិ ហើយយើង ជានីតិវិធីយើងធ្វើចំពោះ មុខដើម្បីបង្ហាញមុខនៅអង្គជំនុំជម្រះ ។ អ៊ីចឹងអង្គជំនុំជម្រះសូមធ្វើការកត់សម្គាល់អំពីបញ្ហានេះ ហើយចំពោះកិច្ចនីតិវិធីបន្តទៅទៀត យើងនឹងធ្វើការ-- សូមអស់លោកបង្ហាញនូវមេធាវីអន្តរជាតិចំពោះនីតិវិធីដំណើរការជាបន្តបន្ទាប់ នៅពេលណាដែលគាត់មានវត្តមានអាចបង្ហាញមុខនៅចំពោះអង្គជំនុំជម្រះសាលាដំបូងបាន ។

ជាបន្តទៀតគឺសូមអញ្ជើញលោកមេធាវី ការ សាវុត្ថ មេធាវីជាតិសម្រាប់ជនជាប់ចោទ ដើម្បីឡើងធ្វើការស្នើសុំទទួលស្គាល់មេធាវីអន្តរជាតិ អនុលោមទៅតាមវិធានផ្ទៃក្នុងត្រង់វិធាន២២.២ ។

**លោក ការ សាវុត្ថ៖**

សូមគោរពលោកប្រធានអង្គជំនុំជម្រះសាលាដំបូង សូមគោរពលោកចៅក្រមជាតិនិងអន្តរជាតិនៃអង្គជំនុំជម្រះសាលាដំបូង! ដោយយោងតាមវិធាន ២២.២(ក) ខ្ញុំបាទ ការ សាវុត្ថ ជាមេធាវីជាតិសូមស្នើលោកប្រធាននិងអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សូមទទួលស្គាល់លោក ហ្វ្រង់ស្វ័រ រ៉ូ មេធាវីអន្តរជាតិ ជាសហមេធាវីការពារជនជាប់ចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចាប់ពីពេលនេះតទៅ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី ការ សាវុត្ថ ។ សូមអញ្ជើញលោក ហ្វ្រង់ ស្វ័ររ៉ូ បង្ហាញដល់អង្គពិធី ។

សូមអរគុណ ។ សូមអនុញ្ញាតអង្គុយចុះ ។

លោក ហ្វ្រង់ស្វ័រ រ៉ូ អង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់លោកធ្វើជាមេធាវីអន្តរជាតិសម្រាប់ការពារជនជាប់ចោទ ក្នុងគោលបំណងនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនេះ ដោយយោងទៅតាមការទទួលស្គាល់នេះ លោកមានសិទ្ធិ និងបុព្វសិទ្ធិដូចគ្នានឹងមេធាវីជាតិដែរ ។

ឥឡូវនេះយើងបានបំពេញកិច្ចចប់សព្វគ្រប់ហើយនៅពិធីផ្លូវការពាក់ព័ន្ធទៅនឹងការទទួលស្គាល់មេធាវីអន្តរជាតិ និងកិច្ចប្រជុំនេះនឹងចាប់ផ្តើមដំណើរការតាមរបៀបវារៈដែលបានគ្រោងទុក ។

របៀបវារៈទៅទីមួយគឺ ពិនិត្យឡើងវិញអំពីតួនាទីស្ថានភាពភាគីនីមួយៗនៅក្នុងកិច្ចដំណើរការនីតិវិធីរួមមានអង្គភាពគាំពារមេធាវី ការពារក្តី មន្ត្រីសម្របសម្រួលមន្ទីរឃុំឃាំង និងអង្គភាពជនរងគ្រោះ ។

ទី១.ក យើងនឹងពិភាក្សារបៀបវារៈអំពីស្ថានភាពសុខភាព និងព័ត៌មានផ្សេងៗពាក់ព័ន្ធទៅនឹងជនជាប់ចោទ ។

ពាក់ព័ន្ធនឹងបញ្ហានេះគឺ អង្គជំនុំជម្រះសូមសួរទៅខាងមេធាវីក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទមានចំណាប់អារម្មណ៍អ្វីដែរទេទាក់ទងទៅនឹងស្ថានភាពសុខភាពរបស់ជនជាប់ចោទ ។ ជាពិសេសនោះគឺអង្គជំនុំជម្រះសាលាដំបូងសួរទៅមេធាវីការពារក្តី ថាតើមេធាវីប្រមើលមើលឃើញបញ្ហាអ្វីខ្លះដែលជាឧបសគ្គដល់ជនជាប់ចោទក្នុងការចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីនាពេលខាងមុខដែរឬទេ? ហើយសំណួរទីបី ថាតើគាត់ត្រូវការឲ្យមានការត្រួតពិនិត្យសុខភាពណាមួយក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីដែរឬទេ? សូមអញ្ជើញលោកមេធាវី ការ សាវុត្ថ មេធាវី ហ្វ្រង់ស្វ័រ រ៉ូ អញ្ជើញមានប្រសាសន៍បញ្ហានេះ ។

**លោក ការ សាវុត្ថ៖**

សូមគោរពលោកប្រធាន! ចំពោះនីតិវិធីដែលប្រព្រឹត្តទៅនេះ និងតទៅថ្ងៃមុខទៀត គឺខាងមេធាវីយល់ស្របតាមកម្មវិធីរបស់លោកប្រធាន ហើយចំពោះបញ្ហាសុខភាពរបស់កូនក្តីខ្ញុំកាំង ហ្គេកអ៊ាវ ហៅឌុច គឺពុំមានអ្វីជាកត់សម្គាល់ទេ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី ការ សាវុត្ថ ។

លោកមេធាវី ហ្វ្រង់ ស្វ័ររូ មានអ្វីចង់បន្ថែមបញ្ហានេះទេ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

ខ្ញុំអត់មានអ្វីបន្ថែមទៀតទេ នៅពេលនេះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមន្ត្រីសម្របសម្រួលមន្ទីរឃុំឃាំង តើលោកចង់មានយោបល់អ្វីទេ?

**លោក ក្លួត ប៊ូរ៉ាត៖**

លោកចៅក្រមជាទីគោរព! នៅពេលនេះទាក់ទងទៅនឹងស្ថានភាពរបស់ជនជាប់ចោទ ទាក់ទងទៅនឹងបន្ទប់ឃុំឃាំងគឺថាយើងមានបន្ទប់បួននៅក្នុងមន្ទីរឃុំឃាំង ។ ទាក់ទងទៅនឹងការរៀបចំបន្ទប់អស់ទាំងនោះ គឺថាយើងនៅកំពុងរៀបចំនិងរង់ចាំ ។ អ៊ីចឹងហើយបានជាជនត្រូវចោទហ្នឹង គឺថាជនជាប់ចោទហ្នឹងមានវត្តមាននៅក្នុងបន្ទប់សវនាការ ហើយយើងនឹងរៀបចំនៅក្នុងអំឡុងពេលសម្រាកខាងមុខនេះ គឺថានៅពេលសម្រាកអាហារថ្ងៃត្រង់ ។ ប៉ុន្តែនៅពេលនេះ បន្ទប់សម្រាប់ឲ្យជនជាប់ចោទរង់ចាំហ្នឹង គឺមិនទាន់មានកន្លែងសម្រាប់ឲ្យគាត់អង្គុយនៅឡើយទេ ។ អ៊ីចឹងគឺថាយើងនឹងរៀបចំ ការរៀបចំកន្លែងឲ្យគាត់អង្គុយ ហើយនិងភេសជ្ជៈខ្លះសម្រាប់ពួកគាត់ ហើយនិងរៀបចំគ្រែ ហើយនិងទូរទស្សន៍ ដើម្បីឲ្យជនជាប់ចោទហ្នឹងអាចតាមដានបាននូវនីតិវិធីនៅក្នុងបន្ទប់សវនាការនេះ ។ ហើយនៅក្នុងអំឡុងពេលរង់ចាំអាហារថ្ងៃត្រង់ហ្នឹង គឺថាយើងនឹងមានផ្តល់អាហារឲ្យជនជាប់ចោទផងដែរ នៅក្នុងអំឡុងពេលសម្រាកអាហារថ្ងៃត្រង់ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

លោកមន្ត្រីជាន់ខ្ពស់នៃមន្ទីរឃុំឃាំង ដែលបានផ្តល់នូវព័ត៌មាននេះ ។

ជាបន្តទៀតដល់របៀបវារៈទី១ (ខ) អំពីសមាសភាពក្រុមមេធាវីការពារក្តី ។ នៅក្នុងរបៀបវារៈ

អង្គជំនុំជម្រះសុំសួរទៅក្រុមមេធាវីការពារក្ដីសម្រាប់ជនជាប់ចោទ អំពីសមាសភាពរបស់ខ្លួន តើក្រុមមេធាវីការពារក្ដីមានគ្នាគ្រប់គ្រាន់ហើយឬនៅ?

លោកការ សាវុត្ថ ។

**លោក ការ សាវុត្ថ៖**

សូមគោរពលោកប្រធាន! ក្រុមមេធាវីការពារក្ដីគឺបានត្រៀមអ្វីៗសម្រាប់ការពារកូនក្ដីរួចអស់ហើយ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

តើតំណាងនៃផ្នែកគាំពារមេធាវីការពារក្ដីចង់មានមតិអ្វីដែរទេ?

**លោក រីឆាត រ៉ូជ្ជឺ៖**

ខ្ញុំចង់បញ្ជាក់ថា សហមេធាវីទាំងពីរហ្នឹងឯង គឺថាបានពិភាក្សាគ្នាជាមួយអ្នកគ្រប់គ្រងករណីសម្រាប់សវនាការខាងមុខនេះ គឺខាងផ្នែកគាំពារការពារក្ដីបានចាត់ចែងហើយនិងរៀបចំពេលវេលាសម្រាប់ពេលវេលាហ្នឹង ដោយសារតែប្រាក់មានកំណត់ហ្នឹង អ៊ីចឹងអ្នកជំនាញដែលជាទីប្រឹក្សាសម្រាប់គាំទ្រសម្រាប់ក្រុមនេះ បើសិនជាមានការចាំបាច់នោះ ។ ហើយខ្ញុំក៏អាចបញ្ជាក់ផងដែរថា ក្រុមការពារការពារក្ដីហ្នឹង នឹងធ្វើការជ្រើសរើស *អ៊ិនធើន* ពីរនាក់ទៀត ដើម្បីចូលរួមនៅក្នុងក្រុមការពារក្ដីនេះសម្រាប់គោលបំណងនៃសវនាការ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកតំណាងនៃផ្នែកគាំពារមេធាវីការពារក្ដីដែលបានមានចំណាប់អារម្មណ៍នេះ ។

ជាកិច្ចបន្តគឺយើងចូលពិភាក្សានូវចំណុចទី១ (គ) ព័ត៌មានបច្ចុប្បន្នភាពស្ដីពីពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីតំណាងរបស់ពួកគាត់ ។ នៅក្នុងរបៀបវារៈនេះ អង្គជំនុំជម្រះសាលាដំបូងសូមអញ្ជើញលោកស្រីប្រធានអង្គភាពជនរងគ្រោះឡើងធ្វើបទបង្ហាញខ្លីអំពីបច្ចុប្បន្នភាពនៃស្ថានភាពនៃពាក្យសុំតាំងធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលអង្គភាពនេះទទួលបានកន្លងមក ព្រមទាំងស្ថានភាពនៃមេធាវីតំណាងរបស់ពួកគាត់ផង ឬការបង្កើតក្រុមក្នុងចំណោមភាគីនៃដើមបណ្ដឹងរដ្ឋប្បវេណី ។ ហើយ--សូមអញ្ជើញលោកស្រីប្រធាន!

**លោកស្រី គាត បូផល៖**

នាងខ្ញុំ--ជំនុំជម្រះសាលាដំបូង សូមគោរពដល់លោកចៅក្រមជាតិនិងបរទេសទាំងអស់ ហើយ

ឯកសារដើម

ក៏ដូចជាអស់លោក លោកស្រី ដែលបានមានវត្តមាននៅក្នុងកិច្ចប្រជុំសវនាការនេះ!

ខ្ញុំសូមជម្រាបជូនអំពីបច្ចុប្បន្នភាពស្ដីពីការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី និងតំណាងផ្លូវច្បាប់របស់ពួកគេ ។ ហើយទាក់ទងនឹងស្ថានភាព និងចំនួននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងករណីនេះ យើងឃើញថា មានដើមបណ្ដឹងរដ្ឋប្បវេណីចំនួន២៨រូប នៅក្នុងសំណុំរឿងនៅពេលដែលបញ្ជូនពីការិយាល័យសហចៅក្រមស៊ើបអង្កេតមកកាន់អង្គជំនុំជម្រះសាលាដំបូង ។ ជាបន្ថែមទៀត យើងមានពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន៤៨ ដែលទាក់ទងនឹងសំណុំរឿងនេះ ហើយដែលអង្គភាពជនរងគ្រោះបានទទួលចាប់តាំងពីថ្ងៃដែលមានចេញដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត រហូតដល់ត្រឹមថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩ ។ ហើយនៅក្នុងចំនួនពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី៤៨នេះ ខាងអង្គភាពជនរងគ្រោះបានបញ្ជូនពាក្យ២០ដំបូង ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី២០ដំបូង មកកាន់អង្គជំនុំជម្រះសាលាដំបូងនាពេលថ្មីៗនេះ ។ ហើយយើងខ្ញុំកំពុងតែរៀងចំបញ្ជូនពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលនៅសេសសល់ទាំងប៉ុន្មានដើម្បីជូនមកអង្គជំនុំជម្រះសាលាដំបូងនៅសប្ដាហ៍ក្រោយ ។

ដូច្នេះយើងឃើញថា ដើមបណ្ដឹងរដ្ឋប្បវេណីនិងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងនេះ ដែលទទួលបានដោយអង្គភាពជនរងគ្រោះមានចំនួនសរុប៧៦ គិតត្រឹមថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩ ។

អង្គភាពជនរងគ្រោះក៏បានពិគ្រោះយោបល់ជាមួយនឹងអង្គការអន្តរការី ដែលបានជួយជនរងគ្រោះកន្លងមក អំពីពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីថ្មីៗ ដែលអាចទាក់ទងនឹងសំណុំរឿងនេះ ហើយអង្គការអន្តរការីទាំងអស់បានបង្ហាញ បានប្រាប់មកអង្គភាពថា ហាក់ដូចជាមិនមានពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីថ្មីៗទៀតដែលពួកគេបានទទួលនោះទេ ។ ហើយអាចនឹងមិនមានពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីថ្មីទៀត ។

ទោះបីជាយ៉ាងណាក៏ដោយ ក៏អង្គភាពជនរងគ្រោះនាពេលបច្ចុប្បន្ននេះ គឺថាបានត្រៀមខ្លួនរួចជាស្រេច ដើម្បីធ្វើយ៉ាងណា ធ្វើការពិនិត្យ ឬក៏ធ្វើតាមនីតិវិធីនៅក្នុងការទទួលនូវពាក្យបណ្ដឹងថ្មីៗ ឬពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីថ្មីៗទៀត ដោយយើងទទួលចាប់ពីពេលនេះតទៅ ។

ហើយឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំសូមអនុញ្ញាតដើម្បីជម្រាបជូនដល់លោកប្រធានអង្គជំនុំជម្រះសាលាដំបូង ក៏ដូចជាអស់លោក លោកស្រី ចៅក្រមទាំងអស់ឲ្យបានជ្រាបផងដែរថា អង្គភាពជនរង

គ្រោះបានដឹងអំពីការប្រើពេលវេលាយូរ ដែលអង្គភាពជនរងគ្រោះបានធ្វើចំណាត់ការទៅលើពាក្យបណ្ដឹង និងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលយើងបានទទួលកន្លងមក ហើយដែលប្រការនេះ បណ្ដាលមកពីការខ្វះខាតធនធានសម្រាប់អង្គភាពផងដែរ ។

ហើយក៏ខ្ញុំសូមជម្រាបជូនផងដែរថា កិច្ចសន្យាផ្នែកហិរញ្ញវត្ថុរវាងអង្គជំនុំជម្រះវិសាមញ្ញជាមួយនឹងរដ្ឋាភិបាលអាល្លឺម៉ង់ ដែលបានផ្ដល់មកអង្គភាពជនរងគ្រោះតាមរយៈទីភ្នាក់ងារអនុវត្ត *ជីធីហ្សិត* ដែលចុះហត្ថលេខាកាលពីខែវិច្ឆិកា ។ ហើយថវិកាដែលយើងមានអាចប្រើប្រាស់បាននោះ គឺមានកាលពីខែមុន ។ អ៊ីចឹងថវិកានេះ គឺថាសម្រាប់បំពេញបន្ថែមទៅនឹងថវិកាដែលផ្ដល់ជូនដោយតុលាការមកដល់អង្គភាពជនរងគ្រោះដើម្បីយើងអាចដំណើរការពេញលេញ ។ ហើយអង្គភាពនឹងចាប់ផ្ដើមជ្រើសរើសបុគ្គលិក ដើម្បីអនុវត្តការងាររបស់ខ្លួនឲ្យមានប្រសិទ្ធភាព ។

នាពេលថ្មីៗនេះ ខ្ញុំសូមជម្រាបផងដែរថា អង្គភាពយើងបាន-- ទើបតែបានជ្រើសរើសបានអ្នកគ្រប់គ្រងខាងពាក្យបណ្ដឹង និងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ និងអ្នកបញ្ចូលទិន្នន័យ៦នាក់ ។ ហើយដែលទើបតែចាប់ផ្ដើមចូលបម្រើការនៅក្នុងសប្ដាហ៍នេះ ។ អ៊ីចឹងអង្គភាពជនរងគ្រោះនឹងកំពុងតែជ្រើសរើសមន្ត្រីសម្របសម្រួលព័ត៌មានម្នាក់ និងបុគ្គលិកសម្របសម្រួលព័ត៌មានចំនួន៦នាក់ទៀត ហើយអង្គភាពនេះ នឹងធ្វើការជ្រើសរើសផងដែរ នូវក្រុមមេធាវីសម្រាប់ករណីលេខសូន្យ-- ករណីលេខមួយនេះ ដែលជារួមនឹងមានសហមេធាវីជាតិ មេធាវីអន្តរជាតិម្នាក់ ។ ក្រុមប្រឹក្សាច្បាប់ខាងអន្តរជាតិនិងមន្ត្រីទទួលបន្ទុកខាងសំណុំរឿង ។

នេះខ្ញុំសូមបញ្ចប់អំពីស្ថានភាពទាក់ទងទៅនឹងចំនួន និងស្ថានភាពនៃការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ។ ហើយទាក់ទងនឹងតំណាងផ្លូវច្បាប់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដូចខាងក្រុមមេធាវីគាត់បានធ្វើការឡើងបង្ហាញរួចហើយ ប៉ុន្តែខ្ញុំសូមបញ្ជាក់ដើម្បីឲ្យបានដឹងថា តើក្រុមណាតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីចំនួនប៉ុន្មាននាក់ថែមទៀត ។

អ៊ីចឹងមានមេធាវីបួនក្រុមហ្នឹង ដែលតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងនេះ ។ មេធាវីបួនក្រុម គឺក្រុមទីមួយគាត់តំណាងឲ្យជនរងគ្រោះចំនួន៣១រូប ។ មេធាវីក្រុមនេះនឹងមានកញ្ញា ទី ស្រ៊ីនណា ជាសហមេធាវីជាតិ និងសហមេធាវីបរទេសបីរូបរបស់គាត់ ដែលគាត់បានរៀបរាប់ពីខាងដើមរួចមកហើយ ។ ហើយពួកគាត់ត្រូវបានគណៈមេធាវីទទួលស្គាល់និងចុះឈ្មោះរួចរាល់អស់ហើយ តែនៅរង់ចាំធ្វើពិធីសម្បថដើម្បីអាចមកតំណាងឲ្យ

ដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញបាន ។

អ៊ីចឹងក្រុម-- មេធាវីក្រុមទីមួយនេះគាត់ធ្វើការសហប្រតិបត្តិការជាមួយនឹងគម្រោងការចូលរួមរបស់ជនរងគ្រោះនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ចំណែកក្រុមទីពីរ គាត់តំណាងឲ្យជនរងគ្រោះចំនួន ១៨នាក់ ហើយក្រុមគាត់មាន លោក ហុង គឹមសួន លោក យ៉ុង ផានិត និង លោក ពិសី ដែលជាសហមេធាវីជាតិ និងលោកស្រី ស៊ីលការ គាត់ជាសហមេធាវីបរទេស ។

អ៊ីចឹងពួកគាត់ដែលជាសហមេធាវីជាតិនៅក្នុងក្រុមនេះ ក៏គាត់បម្រើការនៅអង្គការគម្រោងអ្នកការពារក្ដីកម្ពុជា *ស៊ីឌីភី* ហើយចំណែកលោកស្រី ស៊ីលការ ជាសហមេធាវីបរទេសក៏គាត់បម្រើការឲ្យអង្គការអន្តរការីមួយគឺសមាគមអាដហុកផងដែរ ។

ចំណែកឯក្រុមទីបី គឺគាត់តំណាងឲ្យជនរងគ្រោះចំនួន១៥រូប ដែលក្រុមនេះ-- ដែលក្រុមគាត់មាន កញ្ញា ម៉ុច សុវណ្ណារី និង លោក គឹម ម៉េងឃី ជាសហមេធាវីជាតិ និងសហមេធាវីបរទេសរបស់គាត់ គឺលោកស្រី ម៉ាទីន ហ្សាកកាំង និង លោក ហ្វីលីព កាណុន ដែលជាសហមេធាវីបរទេសដែលមាននៅក្នុងបញ្ជីរបស់អង្គភាពយើង ហើយពួកគាត់នៅក្នុងក្រុមទីបីនេះ គឺបម្រើការឲ្យអង្គមេធាវីគ្មានព្រំដែនរបស់បារាំង *អេអេសអេស* ។

ចំណែកក្រុមទីបួនគឺគាត់តំណាងឲ្យជនរងគ្រោះចំនួន១០រូប ដែលមានលោក ហុង គឹមសួន ជាសហមេធាវីជាតិ មកពីអង្គការ *ស៊ីឌីភី* ហើយនិងលោកសហមេធាវីបរទេស លោក ព្យែរអូលីវី-យ៉ែស័រ ជាសហមេធាវីបរទេសមកពីបារាំង ។

ហើយចំពោះអ្នកដែលដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់នេះ គឺថា មាននៅសល់១០នាក់ទៀតដែលគាត់កំពុងតែរៀបចំដាក់លិខិតតែងតាំងមេធាវីមកកាន់អង្គភាពជនរងគ្រោះ ដែលយើងកំពុងតែរង់ចាំដើម្បីទទួលនូវលិខិតតែងតាំងមេធាវីពីពួកគាត់ ។

ទាក់ទងនឹងតួនាទីរបស់អង្គភាពជនរងគ្រោះ ក្រោមវិធាន២៣ អនុវិធាន៨ អំពីមេធាវីរួមតំណាងឲ្យក្រុមដើមបណ្ដឹងរដ្ឋប្បវេណីនោះ យើងខ្ញុំសូមធ្វើការកត់សម្គាល់ថា សម្រាប់អង្គភាពជនរងគ្រោះគឺថា នៅពេលដែលយើងធ្វើការពិនិត្យទៅលើពាក្យបណ្ដឹងនិងនៅលើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ហើយរៀបចំរបាយការណ៍អំពីពាក្យទាំងអស់នោះទៅកាន់អង្គជំនុំជម្រះ គឺថាអង្គភាពក៏បានធ្វើការ *រីវ្យូ* ធ្វើការពិនិត្យផងដែរ ថាតើអង្គភាពត្រូវតែធ្វើ ឬមិនធ្វើអនុសាសន៍ ឬមិនផ្ដល់អនុសាសន៍អំពីថា តើត្រូវឲ្យមានមេធាវីរួមតំណាងឲ្យក្រុម ឬក៏ក្រុមដើមបណ្ដឹងរដ្ឋប្បវេណីនោះ ។

ចំពោះស្ថានភាពនាពេលបច្ចុប្បន្នេះ អង្គភាពជនរងគ្រោះអាចផ្តល់អនុសាសន៍ថា ល្អិតណាអង្គជំនុំជម្រះសាលាដំបូង គឺថាគាត់ធ្វើសេចក្តីសម្រេចទៅលើស្ថានភាពនៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ ហើយនោះទើបយើងអាចដឹងអំពីចំនួនពិតប្រាកដ អំពីប្រភេទនៃជនរងគ្រោះដែលយើងអាចផ្តល់អនុសាសន៍បានយ៉ាងណា ។

ប៉ុន្តែនៅក្នុងសំណុំរឿងនេះ យើងមិនមើលឃើញអំពីហេតុផលថា តើយើងត្រូវតែផ្តល់អនុសាសន៍ដើម្បីធ្វើយ៉ាងណាឲ្យជម្រើសរបស់ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីហ្នឹង មិនគួរទទួលយកនោះទេ ។ យើងមិនមើលឃើញអំពីហេតុផលដែលថា ត្រូវតែឲ្យមានមេធាវីរួមសម្រាប់តំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកាលៈទេសៈនាពេលបច្ចុប្បន្ននេះទេ ។

អ៊ីចឹងខ្ញុំសូមបញ្ចប់បទបង្ហាញរបស់ខាងអង្គភាពជនរងគ្រោះតែត្រឹមហ្នឹង ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកស្រីប្រធានអង្គភាពជនរងគ្រោះដែលបានធ្វើបទបង្ហាញយ៉ាងក្បោះក្បាយដែលធ្វើឲ្យអង្គពិធីយើងអាចយល់បានជាច្រើននូវហេតុផលទាំងឡាយនៃការវិវឌ្ឍន៍ពាក្យដើមបណ្តឹងរដ្ឋប្បវេណី ដែលបានដាក់ចូលមកតាមរយៈអង្គភាពជនរងគ្រោះ និងរបៀបចាត់ចែងកិច្ចការរបស់អង្គភាពជនរងគ្រោះកន្លងមក ។ ហើយនិងលទ្ធភាពដែលអាចសម្របសម្រួលនូវដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ហ្នឹងបានរលូន និងអាចដំណើរការបាននៅពេលអនាគតមិនមានអីបង្កការលំបាកច្រើន ដោយសារមានការអះអាងមួយបញ្ជាក់ថា ការព្យាករណ៍ហ្នឹងប្រហែលជាមិនមានពាក្យបណ្តឹងថ្មីទេ មានតែបណ្តឹងដែលនៅចូលមកហើយ ដែលកំពុងពិនិត្យ ដែលបម្រុងត្រៀមដើម្បីបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូងដើម្បីពិនិត្យសម្រេចលើបណ្តឹងថ្មី ។

ជាបន្តទៅនេះ ដើម្បីឲ្យកាន់តែច្បាស់លាស់លើចំណាត់ការរបស់អង្គភាពជនរងគ្រោះ លើបទបង្ហាញដែលពាក់ព័ន្ធនឹងដំណើរការប្រព្រឹត្តទៅនៃអង្គភាពជនរងគ្រោះ សកម្មភាពចុងក្រោយនេះ ខ្ញុំសូមអញ្ជើញ ប្រគល់តួនាទីនេះទៅចៅក្រមអង្គជំនុំជម្រះសាលាដំបូង តើមានសំណួរអ្វីចង់សួរពាក់ព័ន្ធទៅនឹងបទបង្ហាញរបស់លោកស្រីប្រធានអង្គភាពជនរងគ្រោះនេះដែរឬទេ? បើមានសូមអញ្ជើញ ។

សូមអញ្ជើញលោក ហ្សង់ ម៉ាកឡាវែន៍។

**ចៅក្រម ហ្សង់ ម៉ាកឡាវែន៍៖**

អរគុណលោកចៅក្រម ខ្ញុំចៅក្រម ឡាវែន៍ នៅក្នុងអង្គជំនុំជម្រះនេះខ្ញុំមានសំណួរមួយទៅប្រធាន

អង្គភាពជនរងគ្រោះ តើលោកស្រីអាចជម្រាប់ប្រាប់យើងមកបានទេ ថាតើជនទាំងអស់នេះ ដែលបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនេះ គឺទាំងអស់ហ្នឹងសុទ្ធតែនឹងមានមេធាវីតំណាង ឬក៏យ៉ាងម៉េច? សូមឲ្យលោកស្រីបញ្ជាក់ឲ្យបានច្បាស់ជាងហ្នឹងបន្តិច ហើយថាតើស្ថានភាពនៅក្នុងបញ្ហានេះវាយ៉ាងម៉េចទៅហើយ? ហើយទាក់ទងជាមួយនឹងការទទួលស្គាល់ ដោយអនុលោមទៅតាមសំណើដែលសុំឲ្យទទួលស្គាល់ដើមបណ្ដឹងរដ្ឋប្បវេណី សូមលោកស្រីជួយបង្ហាញផង--បកស្រាយ ។

**លោកស្រី គាត បូផល៖**

សូមអរគុណចំពោះចៅក្រមចំពោះសំណួរនេះ ។ ខ្ញុំសូមជម្រាបបានថា ទាក់ទងនឹងដើមបណ្ដឹងរដ្ឋប្បវេណីដែលយើងទទួលបានសរុបមកដល់ថ្ងៃនេះមាន៧៦រូបនេះគឺថា គាត់សុទ្ធតែជ្រើសរើសមេធាវីហើយនៅសល់-- ដូចខ្ញុំបានជម្រាបនៅសល់ចំនួនប្រហែល១០នាក់ដែលគាត់មិនទាន់បានធ្វើការតែងតាំងតាមរយៈលិខិតតែងតាំងមេធាវីនៅឡើយ ហើយដែលបុគ្គលិករបស់អង្គភាពជនរងគ្រោះកំពុងតែមានបេសកកម្មទៅកាន់កន្លែងរស់នៅរបស់គាត់នៅតាមខេត្ត ដើម្បីជួយសម្រួលដល់ជនរងគ្រោះទាំងអស់នោះឲ្យគាត់បានជ្រើសរើសមេធាវីពីក្នុងក្រុមមេធាវីទាំងបួនក្រុមនេះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ។

**ចៅក្រម ហ្សង់ ម៉ាកឡាវែន៖**

ប្រសិនបើខ្ញុំយល់ដឹងច្បាស់លាស់ហ្នឹង អ៊ីចឹងក្នុងចំណោមដើមបណ្ដឹងរដ្ឋប្បវេណីទាំង៧៦ហ្នឹង អ៊ីចឹងគឺថាមានមេធាវីស្របច្បាប់គ្រប់គ្រាន់ហើយ ដែលជាអ្នកតំណាង តើ *ស៊ីវិល ផាតធី* ទាំងអស់ហ្នឹងគាត់មានលិខិតតែងតាំងមេធាវីត្រឹមត្រូវទេ សម្រាប់មេធាវីដែលមានបំណងជាអ្នកធ្វើការតំណាងស្របច្បាប់នោះ?

**លោកស្រី គាត បូផល៖**

សូមអរគុណ ។ ខ្ញុំសូមបញ្ជាក់ថា ដើមបណ្ដឹងរដ្ឋប្បវេណីដែលគាត់-- ដែលនៅក្នុងចំណោម៧៦រូប ដែលយើងបានជម្រាបជូនតុលាការនេះ គឺថាមាននៅសល់១០នាក់ដែលគាត់ត្រូវជ្រើសរើសមេធាវី ។ អ៊ីចឹងក្នុងចំណោមដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់នោះគឺថា គាត់ជ្រើសរើសមេធាវីគ្រប់ទាំងអស់គ្នាសុទ្ធតែមេធាវីដែលចេញពីបញ្ជីរបស់អង្គភាពជនរងគ្រោះ ហើយសុទ្ធតែជាមេធាវីដែលគាត់បានទទួលស្គាល់តាមនីតិវិធីច្បាប់រួចអស់ហើយ នៅសល់តែក្រុមទីមួយដែលគាត់រង់ចាំតែពិធីស្បថដែលអង្គភាព

00285865



ជនរងគ្រោះនឹងជួយសម្រួលជាមួយនិងខាងគណៈមេធាវី ធ្វើយ៉ាងណាឲ្យគាត់អាចបានទទួលបាននូវពិធីសម្បថនៅសាលាឧទ្ធរណ៍នេះ នៅក្នុងពេលឆាប់ៗនេះ ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណចំពោះការឆ្លើយ ដោះស្រាយទៅនឹងសំណួររបស់លោកស្រីប្រធាន ។

**លោក បាឡាស៍ ម៉ារ៖**

លោកប្រធាន ខ្ញុំចង់ធ្វើការបញ្ជាក់បន្តិចទាក់ទងទៅនឹងការ-- លិខិតតែងតាំងមេធាវី លិខិតប្រគល់សិទ្ធិមេធាវីនោះ ។ ដូចជាយើងបាននិយាយបញ្ជាក់អ៊ីចឹង គឺថាយើងមានជនរងគ្រោះ១០នាក់ដែលមិនទាន់បានបំពេញនីតិវិធីនេះនៅឡើយទេ ។ ពួកគេកំពុងតែនឹងទទួលបញ្ជូនទម្រង់មកខាងផ្នែកអង្គភាពជនរងគ្រោះនេះ ហើយឥឡូវហ្នឹងគឺថាយើងបានធ្វើបេសកកម្មទៅតាមខេត្តនានា ដើម្បីពិភាក្សាជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីអស់ទាំងនេះ ដើម្បីឲ្យពួកគេធ្វើការជ្រើសរើសតែងតាំងមេធាវី ជាមួយនឹងក្រុមមេធាវីដែលថាយើងមាន ។ ហើយពួកគេនឹងធ្វើការជ្រើសរើសពីបញ្ជីឈ្មោះទាំងហ្នឹង ហើយក្នុងអំឡុងពេលពីរបីថ្ងៃខាងមុខទៀតនេះ យើងនឹងអាចមានមេធាវីមួយចំនួនដែលនឹងអាចត្រូវបានជ្រើសរើសដើម្បីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីអស់ទាំងនោះ ។

**ប្រធានអង្គជំនុំ៖**

អរគុណតំណាងខាងអង្គភាពជនរងគ្រោះអន្តរជាតិដែលបានធ្វើការបទបង្ហាញនេះ ហើយបន្ថែមទៅនឹងលោកស្រីប្រធានបានលើកឡើង គឺកាន់តែច្បាស់លាស់អំពីបញ្ហាជនរងគ្រោះ នឹងប៉ុនប៉ងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមានចំនួន១០នាក់ទៀតដែលមិនទាន់មានមេធាវី មិនទាន់បានជ្រើសរើស និងតែងតាំងមេធាវីជូនគាត់ ។ ហើយជាលទ្ធផលឃើញថា កិច្ចប្រឹងប្រែងក្នុងរយៈពេលប៉ុន្មានថ្ងៃខាងមុខនេះ យើងសង្ឃឹមថា នឹងទទួលបានលទ្ធផលល្អជាមិនខាន ។

តើលោកចៅក្រមអង្គជំនុំជម្រះតើមានសំណួរអ្វីចង់សួរទៅបន្ថែមទៀតទេ ដល់ប្រធាន ដល់អង្គភាពជនរងគ្រោះ? ប្រសិនបើមិនមានម្នាក់ទេ ខ្ញុំសូមប្រគល់វេទិកានេះជូនទៅដល់ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ ដើម្បីលើកឡើងនូវបញ្ហាបច្ចេកទេសនានា ប្រសិនបើមាន សូមគោរពអញ្ជើញ ។

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ សូមអញ្ជើញលោកមេធាវី ហុង គឹមសួន ។

**លោក ហុង គឹមសួន៖**

00285866



ខ្ញុំបាទសូមអរគុណលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះ និងសូមគោរពអង្គសវនាការ-- អង្គប្រជុំទាំងអស់ជាទីគោរពម្តងទៀត ។ ខ្ញុំបាទ ហុង គឹមសួន ជាមេធាវីជាតិ សូមជម្រាបលោកប្រធានក្រុមប្រឹក្សាជ្រាបថា សព្វថ្ងៃខាងមេធាវីជាតិ ដែលមានខ្ញុំបាទ ហុង គឹមសួន លោកមេធាវី គង់ ពិសី លោក យ៉ុង ផានិត ដែលជាមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០១ នេះ បានធ្វើការជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីតាំងពីចុងឆ្នាំ២០០៧មកទល់សព្វថ្ងៃនេះ តាំងពីខាងអង្គភាពជនរងគ្រោះមិនទាន់មានលោកស្រីប្រធានមកដល់ម្ល៉េះ ។

ហើយក្នុងពេលធ្វើការងារនេះដែរ ខាងយើងខ្ញុំជាមេធាវីជាតិបានទទួលការឧបត្ថម្ភជាប្រាក់ធ្វើការពី *ឌីអ៊ីឌី* របស់អាល្លឺម៉ង់រយៈពេល៦ខែ ដែលជាប្រាក់ឧបត្ថម្ភបន្តិចបន្តួចសម្រាប់ដំណើរការងារចូលរួមធ្វើការជាមួយនឹងតុលាការនេះ ។ ប៉ុន្តែ ខាងមេធាវីជាតិយើងខ្ញុំបានសន្សំប្រាក់បានថែមដល់មួយខែទៀត ប្រើប្រាស់រហូតដល់ខែប្រាំពីរនៃឆ្នាំ២០០៨ ។ ចាប់ពីពេលនោះមកទល់សព្វថ្ងៃនេះ ខាងមេធាវីជាតិក្រុមយើងខ្ញុំនេះ គឺគ្មានប្រាក់មួយសេនណាទេដែលឧបត្ថម្ភសម្រាប់ធ្វើការងារ ។ នេះជាផលវិបាកមួយយ៉ាងធ្ងន់ធ្ងរសម្រាប់មេធាវីជាតិនៃក្រុមរបស់យើងខ្ញុំចំនួន៣នាក់ ដែលធ្វើការនៅក្នុងសំណុំរឿង០០១ នេះ ។ ផលវិបាកទាំងនោះគឺ វាទាក់ទងជាមួយនឹងការធ្វើដំណើររបស់យើងខ្ញុំទៅមកចូលរួមនីតិវិធី ទាំងការបើកការប្រជុំរវាងមេធាវីអន្តរជាតិនៅទីឯក្រុងភ្នំពេញ ទាំងការបកប្រែឯកសារទាំងឡាយ ដោយសារការបកប្រែស្នើសុំមកខាង *អ៊ីស៊ីស៊ីស៊ី* គាត់ក៏មានការជាប់រវល់ អ៊ីចឹងយើងខ្ញុំត្រូវការបកប្រែដោយខ្លួនឯងចំណាយប្រាក់កាស់ដោយខ្លួនឯង ឬស្វែងរកអ្នកដែលជួយដោយស្ម័គ្រចិត្តមិនយកកម្រៃដោយខ្លួនឯង ។

ហើយសព្វថ្ងៃយើងខ្ញុំបាន មេធាវីអន្តរជាតិ គឺកញ្ញា ស៊ីលឃីស្ទួតហ្សីនស្គី ដែលគាត់បានតាំងនៅក្នុងភ្នំពេញ ឬនៅក្នុងប្រទេសកម្ពុជាជាប់លាប់រហូតមកជួយគ្នាក្នុងបួននាក់នេះ ធ្វើការងារ ។ ហើយទាំងឧបករណ៍ធ្វើការងារ ដោយយើងខ្ញុំខ្វះខាតតាំងពីកុំព្យូទ័រ ម៉ាស៊ីនព្រីន ក្រដាស ទឹកថ្នាំទាំងឡាយទាំងពួងគឺបានអង្គការក្រៅរដ្ឋាភិបាលដែលជាអង្គការអ្នកច្បាប់ការពារសិទ្ធិកម្ពុជាផង អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា ឬហៅកាត់ថា *អ៊ិលអ៊ីស៊ី* ផង បានជួយគ្នាសម្រាប់ឲ្យកន្លែងប្រជុំ ប្រើទឹក ប្រើភ្លើង ប្រើក្រដាសស្នាមទាំងអស់ ហើយមកទល់សព្វថ្ងៃនេះគឺអង្គការទាំងពីរនេះនៅតែជួយរំលែកថវិកាសម្រាប់ឲ្យពួកយើងខ្ញុំធ្វើការងារប្រជុំ ឬក៏វាយឯកសារ ឬក៏ការបកប្រែ ឬក៏ស្រាវជ្រាវឯកសារ ក្រៅអំពីទីតាំងនៅ *អ៊ីស៊ីស៊ីស៊ី* នេះ ។ ហើយពេលម្តងម្កាលដែរ យើងខ្ញុំក៏បានទៅធ្វើការនៅកន្លែងអង្គភាពជនរងគ្រោះ

00285867



នៅទីក្រុងភ្នំពេញផងដែរ សម្រាប់ឆែកមើលឯកសារ ដោយសារការធ្វើដំណើរពីទីក្រុងភ្នំពេញមកទីនេះត្រូវការថវិកា ។

អ៊ីចឹងមកទល់សព្វថ្ងៃនេះ ខាងក្រុមរបស់មេធាវីជាតិយើងខ្ញុំមានកូនក្តីដែលជាដើមបណ្តឹងរដ្ឋប្បវេណី មានចំនួន១៨ដើមបណ្តឹង ហើយដែលមានអ្នកបន្ថែមតាមក្រោយទៀត ដោយសារតុលាការមិនទាន់ទទួលស្គាល់នៅឡើយនោះ គឺបើបូកសរុបប្រហែលជាចូល៣០ដើមបណ្តឹង ។ អ៊ីចឹងខ្ញុំបាទសូមជម្រាបលោកប្រធាន និងអង្គប្រជុំថា កូនក្តីរបស់ខាងក្រុមយើងខ្ញុំមានជាង២០នាក់ហើយ ដែលត្រូវបានតុលាការទទួលស្គាល់រួចហើយ ។ ប៉ុន្តែផលវិបាករបស់យើងខ្ញុំគឺ សូមឱ្យលោកប្រធានមេត្តាជួយយកចិត្តទុកដាក់ និងជួយសម្រួលដល់ក្រុមយើងខ្ញុំដែលខ្វះខាតទាំងស្រុង នូវថវិកាសម្រាប់បន្តការងារចូលរួមនីតិវិធីតទៅមុខទៀត ។ ប៉ុន្តែ ទោះយ៉ាងណាក៏យើងខ្ញុំនៅខំប្រឹងប្រែងជួយធ្វើការងារការពារ ឬក៏តំណាងឱ្យកូនក្តីឱ្យអស់ពីចិត្តពីថ្លើមតទៅទៀត ។ ប៉ុន្តែ សំខាន់គឺសុំទទូចហើយទទូចទៀតថា បើគ្មានការឧបត្ថម្ភការធ្វើការងារនេះ ខ្ញុំបាទមិននិយាយពីប្រាក់ខែទេ គឺនិយាយពីប្រាក់ឧបត្ថម្ភសម្រាប់ធ្វើការងារ បើមិនទេនោះ យើងខ្ញុំនឹងពិបាកទៅចូលរួមបម្រើការងារនេះតទៅទៀត ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណនូវចំណាប់អារម្មណ៍ និងការផ្តល់ព័ត៌មានអំពីបញ្ហានេះដោយរបស់លោកមេធាវី ហុង គឹមសួន ហើយអង្គជំនុំជម្រះសាលាដំបូងសូមធ្វើការកត់សម្គាល់នូវបញ្ហានេះ នៅក្នុងកំណត់ហេតុ ដើម្បីយកទៅពិនិត្យពិភាក្សា និងអាចរិះរកមធ្យោបាយ រកដំណោះស្រាយនាពេលក្រោយ ។

ជាកិច្ចបន្តសូមអញ្ជើញអស់លោក លោកស្រី នាងកញ្ញាជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត សូមអញ្ជើញ អាចលើកឡើងនូវបញ្ហាបច្ចេកទេសនានាប្រសិនបើមាន ។ សូមអញ្ជើញកញ្ញា!

**កញ្ញា ម៉ុច សុវណ្ណារី៖**

ជាដំបូង នាងខ្ញុំសូមគោរពដល់អង្គជំនុំជម្រះសាលាដំបូងជាទីគោរព! ខាងនាងខ្ញុំមានកំណត់សម្គាល់ មួយដែលចង់ជម្រាបជូនដល់អង្គជំនុំជម្រះសាលាដំបូង ហើយនិងអង្គប្រជុំទាំងមូលថា ខាងក្រុមមេធាវីយើងខ្ញុំ កំពុងតែរៀបចំនៅក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះពីរនាក់ទៀត ដែលខាងយើងខ្ញុំកំពុងត្រៀមរៀបចំ ហើយមិនទាន់បានបញ្ជូនចូលទៅខាងអង្គភាពជនរងគ្រោះនៅឡើយទេ ។ ហើយយើងនឹងមានដើមបណ្តឹងរដ្ឋប្បវេណីពីរនាក់ទៀត ហើយនិងមានការចូលធ្វើអន្តរាគមន៍របស់មេធាវីជនជាតិបារាំងចំនួនពីរនាក់ទៀតដែលគាត់បានចូលស្បថរួចហើយ

ហើយយើងកំពុងតែរៀបចំសំណុំឯកសារនៅក្នុងហ្នឹងមានលោកស្រីមេធាវី អារីអានីដីឡា អេ មួយ និង លោកស្រី មេធាវី អេលីហ្សាប៉ែត មួយទៀត ដែលគាត់នឹងធ្វើការសហការជាមួយនឹងក្រុមមេធាវីរបស់យើងខ្ញុំ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសាលាដំបូងក៏នឹងធ្វើការកត់សម្គាល់នៅក្នុងកំណត់ហេតុអំពីបញ្ហានេះ ហើយនេះជាបញ្ហាថ្មីមួយទៀតដែលពុំមាននៅក្នុងរបាយការណ៍របស់ប្រធានអង្គភាពជនរងគ្រោះទេ ព្រោះថ្មីបន្ថែមទៀត ។ មានន័យថាថ្មីបន្ថែមលើ១០រូប ព្រោះនេះមិនទាន់បានផ្តល់ព័ត៌មាននេះដល់អង្គភាពជនរងគ្រោះនៅឡើយទេ ។

អញ្ជើញមេធាវីផ្សេងទៀតនៃដើមបណ្តឹងរដ្ឋប្បវេណីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនេះ តើមានអ្វីចង់លើកឡើងទេ? សូមអញ្ជើញលោកស្រី ។

**លោកស្រី ស៊ីលឃី ស្ទួតហ្សឺនស្គី៖**

ខ្ញុំចង់ជម្រាបលោកចៅក្រមថា ពួកយើងខ្ញុំនឹងបញ្ជូននូវលិខិតប្រគល់សិទ្ធិសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានដាក់ជូនមកហើយនោះ រួមបញ្ចូលទាំងចំណុចចំនួនពីរទៀត ដែលយើងបានទាន់ពិភាក្សាគ្នារួចមកហើយនោះ ដែលលោកចៅក្រមនឹងបានទទួលនូវលិខិតប្រគល់សិទ្ធិនេះ ក្នុងពេលឆាប់ៗនេះ គឺសង្ឃឹមថា នឹងទទួលបានមុននឹងសវនាការចាប់ផ្តើម ដើម្បីសម្របសម្រួលនៅពេលដែលទទួលបានលិខិតប្រគល់សិទ្ធិនោះ គឺថាមានរួមទាំងនិងលទ្ធភាពដែលលោកចៅក្រមបានធ្វើការជូនដំណឹងដល់មេធាវីអស់ទាំងនោះឬក៏បើធ្វើការកោះអញ្ជើញមេធាវីអស់ទាំងនោះមកក្នុងសវនាការ ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកស្រី ស៊ីលឃី ស្ទួតហ្សឺនស្គី ដែលបានផ្តល់ព័ត៌មាននេះដល់អង្គពិធីទាំងមូលក៏ដូចជាដល់អង្គជំនុំជម្រះសាលាដំបូងបានជ្រាប ។ មានទៀតទេ? ខាងមេធាវីតំណាងដើមបណ្តឹងរដ្ឋ-ប្បវេណី ដែលមានបំណងលើកឡើងអំពីបញ្ហាបច្ចេកទេសនានា ពាក់ព័ន្ធនឹងបញ្ហានេះ? សូមអញ្ជើញកញ្ញា ទី ស្រ៊ីនណា អញ្ជើញ ។

**កញ្ញា ទី ស្រ៊ីនណា៖**

ជាបឋមនាងខ្ញុំសូមគោរពអង្គជំនុំជម្រះនិងសូមគោរពអង្គប្រជុំទាំងមូល! នាងខ្ញុំជាមេធាវីដែលទើបនឹងបានតែងតាំងពីដើមបណ្តឹងរដ្ឋប្បវេណី ហើយក៏ទើបតែទទួលស្គាល់ក្នុងពេលថ្មីៗនេះដែរ ហើយ

អ៊ីចឹងទៅនាងខ្ញុំក៏ពុំទាន់បានសិក្សាទៅលើសំណុំរឿងក្តី ០០១ហ្នឹង ឲ្យបានមុននៅឡើយទេ ។ អ៊ីចឹងហើយនាងខ្ញុំមានសំណូមពរសុំឲ្យខាងអង្គជំនុំជម្រះមេត្តាជួយសម្របសម្រួលពីបញ្ហាហ្នឹង ហ្នឹងជាចំណុចមួយ។ ហើយចំណុចមួយទៀត នាងខ្ញុំគ្រាន់តែមានករណីមួយដែលកូនក្តីនាងបានតាំងនាងខ្ញុំជាដើមបណ្តឹងរដ្ឋប្បវេណីហើយ ហើយក្នុងហ្នឹងកូនក្តីខ្ញុំហ្នឹងមានសរុបចំនួន៣១នាក់ ។ នៅក្នុង៣១នាក់ហ្នឹងមាន-- អ្នកដែលបានទទួលស្គាល់ហ្នឹងមានចំនួន៧រូប ។ ៧រូបហ្នឹងនាងខ្ញុំបានដាក់ចូលរួចហើយ ហើយនៅចំនួន២២រូបទៀត គឺស្ថិតនៅក្នុងការដាក់ស្នើសុំជាដើមបណ្តឹងរដ្ឋប្បវេណី ។ ហើយអ៊ីចឹងខាងអង្គជំនុំជម្រះពុំទាន់បានសម្រេចពីបញ្ហានេះទេ ។ នាងខ្ញុំគ្រាន់តែចង់ដឹងថា តើពេលណានឹងសម្រេចឲ្យខាងដើមបណ្តឹងរបស់នាងខ្ញុំហ្នឹង សម្រេចថាទទួលស្គាល់ថាពួកគាត់ជាដើមបណ្តឹងរដ្ឋប្បវេណី? នាងខ្ញុំចង់ដឹងពីពេលវេលាមួយជាក់លាក់ទៅលើបញ្ហាហ្នឹង ។

ហើយចំណុចមួយទៀត នៅក្នុងចំណោមកូនក្តីនាងខ្ញុំដែលបានទទួលស្គាល់នាងខ្ញុំទាំង៧នាក់ហ្នឹង នៅក្នុងចំណោមហ្នឹងមានម្នាក់បានទទួលមរណភាពកាលពីថ្ងៃ២៦ ខែ១២ នេះ ។ អ៊ីចឹងនាងខ្ញុំសូមឲ្យជួយសម្រេចពីបញ្ហាហ្នឹង ថាតើគាត់-- ខ្ញុំអត់ដឹងថា តើគាត់មានសិទ្ធិនៅក្នុងការតាំងខ្លួនជាដើមបណ្តឹងដដែល ឬមួយក៏យ៉ាងម៉េច? ហើយមួយវិញទៀតគាត់ក៏បានផ្ទេរសិទ្ធិហ្នឹងទៅឲ្យគ្រួសាររបស់គាត់ជំនួសគាត់ដែរ តើខាងអង្គជំនុំជម្រះគិតយ៉ាងម៉េចដែរចំពោះករណីហ្នឹង?

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណ កញ្ញា ទី ស្រ៊ីនណា ដែលបានផ្តល់ព័ត៌មានដ៏ល្អនេះ ពាក់ព័ន្ធនឹងបញ្ហាមួយចំនួនទាក់ទិននឹងរឿងដើមបណ្តឹងរដ្ឋប្បវេណី ។ ហើយបញ្ហាទីមួយគឺថា ដើមបណ្តឹងរដ្ឋប្បវេណីដែលបានដាក់ជូនមកសាលាដំបូងរួចហើយ ហើយតើសាលាដំបូងនឹងសម្រេចទទួលស្គាល់នៅពេលណា? សំណួរនេះអ្នកដែលភ្ជាប់នឹងសំណួរដែលបានសួររួចមកហើយដោយលោកស្រី ស៊ីលឃី ស្ទួតហ្សឹនស្គី ។

ហើយនៅក្នុងរបៀបវារៈនៃកិច្ចប្រជុំនេះ ក៏យើងមានរបៀបវារៈមួយធ្វើការបកស្រាយ ធ្វើការរកដំណោះស្រាយមួយដ៏សមរម្យ សម្រាប់ឆ្លើយតបជូនអង្គប្រជុំ ជូនភាគីដែលពាក់ព័ន្ធ ។ ហើយបញ្ហានេះនឹងលើកនៅរបៀបវារៈក្រោយៗទៀត ដែលនឹងបង្ហាញដោយលោកចៅក្រម ដែលនឹងតំណាងឲ្យខ្ញុំនឹងបង្ហាញនូវរបៀបវារៈបន្តបន្ទាប់ ។

ហើយចំណែកឯបញ្ហាមួយទៀតក៏យើងទទួលដែរ ហើយកត់សម្គាល់ទុកយ៉ាងត្រឹមត្រូវនូវដើម

00285870



បណ្ដឹងម្នាក់ដែលបានទទួលមរណភាពនៅក្នុងអំឡុងពេលដំណើរការនីតិវិធី ។ ហើយបញ្ហានេះ គាត់បានផ្ទេរសិទ្ធិឱ្យគ្រួសារគាត់ហើយ ។ បញ្ហានេះក៏ជារឿងមួយផ្នែកខាងបច្ចេកទេសច្បាប់ ថាតើត្រូវទទួលស្គាល់អ្នកដែលទទួលបន្តពីអ្នកមរណភាពហ្នឹងតាមរបៀបណា? ដោយសេចក្ដីសម្រេច ឬក៏ដោយមិនបាច់ធ្វើ? អានេះជាបច្ចេកទេសដែលយើងនឹងធ្វើបន្តទៀត ។

ហើយតាមការគិតរបស់ខ្ញុំប្រហែលជាមានដំណោះស្រាយ ពីព្រោះដោយសារនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាថ្មីនេះបានបញ្ញត្តិដល់បញ្ហាមរណភាពនៅក្នុងដំណាក់កាលពាក់កណ្ដាលទីនៃដំណើរការនីតិវិធីរួចហើយ ។ បើយើងយកស្មារតីនៃបទប្បញ្ញត្តិទាំងនោះ យកមកវិភាគពិចារណា យើងនឹងរកដំណោះស្រាយបាន ។ ប៉ុន្ដែ ទោះបីជាយ៉ាងណាក៏ដោយគឺអង្គជំនុំជម្រះសាលាដំបូងមិនទាន់តបបញ្ហានេះទេ នឹងរកដំណោះស្រាយនៅពេលក្រោយ ។ សូមអរគុណ ។

ជាបន្តទៀតសូមអញ្ជើញមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងៗទៀត ដែលមិនទាន់មានយោបល់សូមអញ្ជើញ ។ ឃើញថា ការចាប់អារម្មណ៍នេះឃើញមានបញ្ហាផ្ដល់ព័ត៌មានល្អៗជាច្រើន ដល់អង្គជំនុំជម្រះ ហើយបញ្ហាមួយចំនួនគឺបើយើងដឹងមុន យើងនឹងរិះរកមធ្យោបាយដើម្បីរកដំណោះស្រាយល្អៗសមស្របដើម្បីពន្លឿននូវដំណើរការប្រព្រឹត្តទៅនៃនីតិវិធីសវនាការរបស់យើងឱ្យបានឆាប់រហ័ស ហើយនិងប្រកបដោយភាពរលូន និងយុត្តិធម៌នោះ ។ សូមអញ្ជើញ មានទេ?

លោកមេធាវី ហុង គីមសួន នៅមានបញ្ហាមួយខ្ញុំមើលកត់សម្គាល់ឃើញដូច្នេះ លើការងារបច្ចេកទេសក្នុងការចំណាត់ក្រុមនេះ ខ្ញុំឃើញឈ្មោះលោកមេធាវីមាននៅក្នុងក្រុមពីរផង ហើយនៅក្នុងក្រុមបួនផង បញ្ហានេះមានបញ្ហាអីទេ ឬក៏នៅក្នុងកិច្ចការដែលប្រតិបត្តិការរបស់លោកបច្ចុប្បន្នអត់មានបញ្ហាអីទេ?

**លោក ហុង គីមសួន៖**

សូមអរគុណលោកប្រធាន ។ សព្វថ្ងៃនេះមិនមានបញ្ហាអីទេ ចេះតែដំណើរការទៅមុនទៀតប្រឹងប្រែងអ៊ីចឹងទៅ ។ តែបើសិនថា ពេលទៅមុខទៀត ដូចខ្ញុំបានជម្រាបមិញអ៊ីចឹង បើថាយើងខ្វះការឧបត្ថម្ភពីម្ចាស់ជំនួយណាមួយនោះ គឺយើងខ្ញុំមានផលវិបាកខ្លាំង ដោយសារមេធាវីបរទេសត្រូវការមេធាវីជាតិធ្វើការរួមគ្នា ។ អ៊ីចឹងក្រុមខ្ញុំបាទទីមួយគឺជាមួយនឹងកញ្ញា ស៊ីលឃី ស្ទូតហ្វីនស្គី ក៏កំពុងដំណើការសព្វថ្ងៃ ។ ហើយក្រុមទីពីររបស់យើងខ្ញុំគឺលោក ព្យែរអូលីវីយែស័រ នៅប្រទេសបារាំងនោះលោកមិនបានចូលរួមមែន ក៏ប៉ុន្ដែព័ត៌មានដែលយើងខ្ញុំធ្វើការបានបញ្ជូនទៅគាត់ ឬគាត់បានផែកទៅតាម

00285871



វេបសាយ ឬអ៊ីម៉ែល អ៊ីចឹងធម្មតា ។ ផលវិបាកមានតែមួយទេ គឺខ្វះខាតថវិកាធ្វើការងារតែប៉ុណ្ណឹង ។

**ប្រធានអង្គជំនុំ៖**

អរគុណ ។ បញ្ហាខ្វះលទ្ធភាព ខ្វះថវិកា ឬមធ្យោបាយធ្វើការងារនេះ គឺអង្គភាពអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ កត់ត្រាទុកនៅក្នុងកំណត់ហេតុរួចហើយ ។ បញ្ហាមិញនេះគឺយើងខ្ញុំចង់ដឹងពីបញ្ហាបច្ចេកទេសទេ ដោយសារនៅក្នុងចំណោមចំណាក់ការបែងចែកជាក្រុមនេះ ឃើញមេធាវីទាំងអស់មានលក្ខណៈដាច់ដោយឡែក មានតែលោកមេធាវីមួយទេ ដែលមានឈ្មោះតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីរហូតទៅដល់ពីរក្រុម តែប៉ុណ្ណឹងទេ ។

ហើយបើគ្រាន់តែលោមមានបញ្ហាទេ គឺជាការល្អណាស់ យើងនឹងដំណើរការប្រព្រឹត្តទៅតាមបែបនេះតទៅទៀត។ ដោយសារនេះជាសិទ្ធិភាគីដើមបណ្ដឹងរដ្ឋប្បវេណី ដែលគេអាចជ្រើសរើសមេធាវីតាមឆន្ទៈរបស់គេ ។ អ៊ីចឹងយើងមិនមានអីទៅរាំងនូវរបៀបក្នុងការចូលរួម ឬក៏ទទួលសុំចាត់តាំងជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងពីរក្រុមរបស់លោកទេ ។ ក៏ប៉ុន្តែ បច្ចេកទេសយើងនឹងប្រឹងប្រែងធ្វើយ៉ាងណា ចំណាត់ការនៅក្នុងការសម្របសម្រួលដឹកនាំសវនាការឲ្យបានសមស្របនិងប្រុងប្រយ័ត្នពីបញ្ហានេះ ចៀសវាងការភ័ន្តច្រឡំ ។ លោកមេធាវីនៅតំណាងឲ្យក្រុមទីមួយ ស្រាប់តែអាចផ្ដល់សក្ខីកម្ម ឬក៏ធ្វើអំណះអំណាងសម្រាប់ក្រុមបីអ៊ីចឹង។ អ៊ីចឹង យើងនឹងប្រុងប្រយ័ត្ននូវបញ្ហានេះនៅពេលដែលដំណើរការនីតិវិធីជាក់ស្ដែង ។

មានទេ មានបញ្ហាអីទៀតទេ ខាងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី? ខ្ញុំសួរបញ្ហាក់ដដែលៗនេះ ដោយសារខ្ញុំកត់សម្គាល់ឃើញថា អ្វីដែលបាន-- មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីលើកឡើងពាក់ព័ន្ធនឹងបច្ចេកទេសនានាឃើញថា មានការផ្ដល់ព័ត៌មានល្អណាស់ ដែលព័ត៌មាននេះខាងអង្គជំនុំជម្រះសាលាដំបូងអត់ទាន់បានទទួលទេ ទើបទទួលព័ត៌មាននៅពេលនេះទេ ដែលជាមធ្យោបាយមួយដែលនឹងផ្ដល់លទ្ធភាពអង្គជំនុំជម្រះសាលាដំបូងយើងអាចធ្វើការសិក្សា ហើយនិងរិះរកមធ្យោបាយ ឬក៏សម្របសម្រួលជាមួយនឹងអង្គភាពជនរងគ្រោះ ដើម្បីរៀបរយយ៉ាងណាឲ្យដំណើរការប្រព្រឹត្តទៅក្នុងការដាក់ពាក្យបណ្ដឹង ឬពិនិត្យពាក្យបណ្ដឹងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនេះ គឺឲ្យបានឆាប់បំផុតដែលអាចធ្វើទៅបាន ដើម្បីចៀសវាងនូវការយឺតពេលនៅក្នុងដំណើរការប្រព្រឹត្តទៅ ដូចជាសវនាការបឋមជាដើម ។

បើមិនមានអីទេ ជាកិច្ចបន្តគឺខ្ញុំសូមបន្តនូវការពិភាក្សាបន្តទៀតនូវចំណុច កថាខណ្ឌទី៩ នៃ

របៀបវារៈ ដែលអនុលោមទៅតាមបញ្ញត្តិនានានៃវិធាន២៣.៤ ដើម្បីទទួលយកបានជនរងគ្រោះ ត្រូវដាក់ពាក្យស្នើសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណី នៅអង្គភាពជនរងគ្រោះយ៉ាងតិចរយៈពេល១០ថ្ងៃ នៃថ្ងៃធ្វើការ មុនការបរិច្ឆេទសវនាការបឋម ។ បញ្ហានេះអង្គជំនុំជម្រះសាលាដំបូងសុំសួរទៅប្រធានអង្គភាពជនរងគ្រោះ ថាតើបានធ្វើអ្វីខ្លះ ហើយក្នុងការជម្រាបដំណឹងដល់សាធារណជនជាទូទៅអំពីពេលវេលាកំណត់សម្រាប់ដាក់ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ ។ សូមអញ្ជើញលោកស្រីប្រធាន។

**លោកស្រី គាត បូផល៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមជម្រាបជូនថា កន្លងមកខាងអង្គភាពជនរងគ្រោះធ្លាប់បានជម្រាបជូនទៅដល់អង្គការអន្តរការីដែលធ្វើការជាមួយជនរងគ្រោះទាំងអស់ អំពីវិសោធនកម្ម ទាក់ទងនឹងមាត្រានេះ អំពីរយៈពេល១០ថ្ងៃ ដែលជនរងគ្រោះ ដែលមានបំណងចង់ដាក់ពាក្យបណ្តឹងនេះ ត្រូវដាក់ឱ្យទាក់ពេលវេលា ។ ហើយយើងក៏បានដាក់បញ្ចូលនៅក្នុងការផ្សព្វផ្សាយព័ត៌មានរបស់យើង ដូចជាក្នុងកម្មវិធីផ្សព្វផ្សាយផ្សេងៗ ឬក៏ក្នុងការជួបប្រជុំផ្សេងៗ ទាំងជាមួយនឹងក្រុមជនរងគ្រោះនៅក្នុងប្រទេសកម្ពុជា ក៏ដូចជាមួយនឹងក្រុមជនរងគ្រោះដែលគាត់មានទំនាក់ទំនងជាមួយអង្គភាពយើង ដែលរស់នៅបរទេស អំពីការកំណត់កាលបរិច្ឆេទនេះដែរ ។

ដូច្នេះ កន្លងមក អ្វីដែលយើងចង់ថាជា សំណូមពររបស់អង្គភាពជនរងគ្រោះដែរ ថាបើសិនជាការកំណត់ឱ្យបានច្បាស់លាស់អំពីកាលបរិច្ឆេទនេះឱ្យបានកាន់តែឆាប់នោះ ក៏ជាការមួយជួយសម្រួលដល់ការងាររបស់អង្គភាពជនរងគ្រោះ ។ ដោយអង្គភាពជនរងគ្រោះ នឹងអាចធ្វើការជាមួយផ្នែកកិច្ចការសាធារណៈ ដើម្បីធ្វើយុទ្ធនាការមួយផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយថែមទៀតអំពីកាលបរិច្ឆេទនេះ ។ អង្គភាពជនរងគ្រោះក៏បានលើកឡើងផងដែរជាមួយនឹងខាងអង្គការអន្តរការីផ្សេងៗ ហើយក៏ជាមួយនឹងខាងក្រុមជនរងគ្រោះ ឬក៏ជនរងគ្រោះដែលតែងតែមានទំនាក់ទំនងជាមួយនឹងខាងអង្គភាពយើង ឱ្យគាត់បានដឹងអំពីថាពេលវេលាអាចនឹងឆាប់ៗនេះ ។ ប៉ុន្តែ កន្លងមកយើងអត់ទាន់បាន យើងអត់អាចជម្រាបជូនគាត់ច្បាស់លាស់អំពីកាលបរិច្ឆេទនោះនៅឡើយ ។ ដូច្នេះ បើសិនជាយើងអាចបានដឹងនៅពេលឆាប់ៗនេះ ខាងយើងខ្ញុំនឹងអាចធ្វើការផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយ ដូចដែលខ្ញុំបានជម្រាបជូនជាមួយនឹងផ្នែកកិច្ចការសាធារណៈ ក៏ដូចជាមួយអង្គការក្រៅរដ្ឋាភិបាល ដែលគាត់មានកម្មវិធីខាងគាំទ្រសាលាក្តីខ្មែរក្រហម ។

00285873



**ប្រធានអង្គជំនុំ៖**

ខ្ញុំសូមអរគុណលោកស្រីប្រធាន ដែលបានធ្វើការបកស្រាយបញ្ជាក់ពាក់ព័ន្ធនឹងសំណួរ ដែលយើងខ្ញុំបានសួរនេះ ។ ហើយបញ្ហាគឺ បានសេចក្តីថាយើងមិនទាន់បានជ្រះស្រឡះ ឬច្បាស់លាស់នៅឡើយទេ បានន័យថាការធ្វើហ្នឹង គឺយើងបានធ្វើហើយ ប៉ុន្តែមិនទាន់បានទូលំទូលាយទេ អ៊ីចឹងទេ?

**លោកស្រី គាត ប៊ូផល៖**

ចាស ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងគឺការប៉ុនប៉ងនេះ យើងនឹងដំណើរការរៀបរយបន្ថែមទៀត ប្រសិនបើគោលបំណងនេះយើងមានការប៉ុនប៉ងដូច្នេះមែន ក្នុងការផ្តល់ព័ត៌មានអំពីកាលបរិច្ឆេទជាក់លាក់នេះដល់សាធារណជន។

សូមអញ្ជើញលោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកចៅក្រម ។ ខ្ញុំសូមធ្វើការបញ្ជាក់ថាបើសិនជាធ្វើកាន់តែឆាប់បាននោះ ទាក់ទងទៅនឹង ការដាក់ពាក្យនោះ គឺនឹងជាការប្រសើរ ពីព្រោះថាបើសិនយើងដាក់ពាក្យនៅជិតកាលបរិច្ឆេទកំណត់បែបនោះ នឹងមានការលំបាក ពីព្រោះអាចបង្ការនឹងផលវិបាក សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនិងសម្រាប់ឲ្យតុលាការផងដែរ ។ ដូច្នេះ កុំរង់ចាំពេលវេលា ដើម្បីរង់ចាំជិតដល់ផុតកាលកំណត់នោះទើបដាក់ពាក្យនោះ ពីព្រោះនេះគឺជារឿងមួយដែលប្រញាប់ ដែលយើងគួរត្រូវតែធ្វើ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកស្រីចៅក្រម ដែលបានបញ្ជាក់បន្ថែមលើបញ្ហានេះ ។

ទាក់ទិនជាមួយនឹងអង្គភាពជនរងគ្រោះនេះដែរ គឺសាលាដំបូងមានសំណួរមួយទៀតសួរថាដោយផ្អែកលើព័ត៌មានដែលអង្គភាពជនរងគ្រោះមាន តើអង្គភាពជនរងគ្រោះហ្នឹងអាចនឹងរំពឹងទុកថា នឹងអាចមានដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណីថ្មីៗបន្ថែមទៀតដែរឬទេ ក្នុងអំឡុងពេលមុនកិច្ចដំណើរការ ផ្តើមកិច្ចដំណើរការនីតិវិធីអង្គជំនុំជម្រះ ជាពិសេសផ្តើមសវនាការបឋម?

**លោកស្រី គាត ប៊ូផល៖**

ខ្ញុំសូមជម្រាបជូនលោកប្រធាន ហើយនិងអង្គកិច្ចប្រជុំពិភាក្សាទាំងមូលថា ដូចដែលនៅក្នុងបទបង្ហាញខ្ញុំពីខាងដើមថា យើងបានពិគ្រោះ ហើយក៏ដូចជាពិភាក្សាជាមួយអង្គការអន្តរការីនានា ដែល

គាត់បានធ្វើការជួយជនរងគ្រោះហ្នឹង ភាគច្រើនពួកគាត់មិនបានលើកឡើងថា នឹងមានថ្មីច្រើនទៀតទេ ។ ប៉ុន្តែ ដូចជាខាងអង្គការ *អេអេសអេស* គាត់បាន-- ខាងមេធាវីគ្មានព្រំដែនរបស់បារាំង គាត់បានលើកឡើងមិញថា អាចមានមួយ ឬក៏មានពីរពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៀត ។ ហើយយើងបានដឹងថាអាចនឹងមានចំនួនតិចតួច ដែលនឹងអាចដាក់មកអង្គភាពយើងនៅក្នុងសប្តាហ៍ៗខាងមុខនេះ ។

ប៉ុន្តែ ខ្ញុំសូមជម្រាបជូនដែរថា ដូចខ្ញុំលើកឡើងអម្បាញ់មិញថា បើសិនជាខាងអង្គជំនុំជម្រះសាលាដំបូង អាចកំណត់ពីកាលបរិច្ឆេទនេះឲ្យបានច្បាស់លាស់ ក៏ជាការមួយដែលងាយស្រួលសម្រាប់អង្គភាពយើង នៅក្នុងការធ្វើចំណាត់ការ ទៅលើពាក្យសុំទាំងអស់នោះ ដែលយើងនឹងអាចទទួល ។ បើក្នុងកាលៈទេសៈថា យើងនឹងអាចទទួលច្រើន ដែលហួសពីសមត្ថភាពដែលខាងអង្គភាពជនរងគ្រោះអាចនឹងធ្វើចំណាត់ការបាននោះ យើងនឹងត្រូវជម្រាបមកខាងអង្គជំនុំជម្រះសាលាដំបូង ដើម្បីអាចពិភាក្សាគ្នាថា រកយន្តការអីណាមួយ ដើម្បីអាចឲ្យអង្គភាពយើងអាចធ្វើចំណាត់ការទៅលើពាក្យបណ្តឹងទាំងអស់នោះបាន ។

ហើយដោយសារថាថ្មីៗនេះ យើងមានបុគ្គលិកដែលអាចជួយដល់ការងារហ្នឹង ដែលយើងបាន-- ដែលគាត់បានចូលធ្វើការហើយ ខាងបញ្ចូលទន្និន័យហ្នឹង ដូច្នេះយើងសង្ឃឹមថាយើង-- ការងារលើចំណាត់ការទៅលើពាក្យបណ្តឹង និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនឹងអាចធ្វើទៅប្រកបដោយប្រសិទ្ធភាព និងបានទាន់ពេលវេលា ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីប្រធាន ។ ជាបន្តទៀត អង្គជំនុំជម្រះសាលាដំបូងប្រគល់វេទិការនេះជូនទៅ៖ ១) គឺមេធាវីដើមបណ្តឹងរដ្ឋប្បវេណី តើមានសំណួរអ្វីចង់សួរទៅអង្គភាពជនរងគ្រោះដែរឬទេ? ប្រសិនបើមានសូមអញ្ជើញ ។ សូមអញ្ជើញលោកស្រី ។

**លោកស្រី ម៉ាទីន ហ្សាកហ្វ៊ីន៖**

សូមអរគុណ ។ ដោយសារតែយើងបានធ្វើការជាមួយក្រុមមេធាវី ដែលជាក្រុមមេធាវីបារាំង គឺថាយើងបានដាក់សំណុំរឿងហើយ ពីព្រោះការពិត គឺថាក្នុងការផ្សព្វផ្សាយនោះ គឺបាននិយាយប្រាប់ថាក្រុមណាត្រូវទាក់ទងជាមួយយើង ។ ទាក់ទងទៅនឹងលិខិតប្រគល់សិទ្ធិ គឺថាយើងត្រូវដាក់បញ្ចូលនូវលិខិតប្រគល់សិទ្ធិនៅក្នុងប្រទេសខ្មែរយើង ហើយវាស៊ីពេលណាស់ក្នុងការធ្វើដូច្នោះ ។

ហើយខ្ញុំចង់និយាយប្រាប់លោកប្រធានដែរថា ខាងមេធាវីបារាំងនោះ គឺថាមិនយល់ដឹងឲ្យច្បាស់

លាស់ទេ ឬក៏មិនបានដឹងឲ្យបានដឹងច្បាស់ថា សវនាការនឹងចាប់ផ្តើមក្នុងពេលឆាប់ៗនេះ ហើយគឺថាសំណុំពាក្យហ្នឹង គឺត្រូវដាក់ឲ្យបានឆាប់បំផុតនោះ ។ ពីព្រោះព័ត៌មានជាក់លាក់ទាក់ទងទៅនឹងរឿងនេះគួរតែបញ្ជូនទៅឲ្យមេធាវីអស់ទាំងនោះ។ សូមអរគុណ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី ម៉ាទីន ហ្សាកហ្សីន ។ សូមអញ្ជើញ កញ្ញាមេធាវី។

**កញ្ញា ទី ស្រ៊ីនណា៖**

អរគុណលោកចៅក្រម ។ ចំពោះក្រុមនាងខ្ញុំ នាងខ្ញុំពុំមានសំណួរអីសួរទេ ក៏ប៉ុន្តែនាងខ្ញុំសូមបញ្ជាក់ និងជូនជាព័ត៌មានដល់ខាងអង្គជំនុំជម្រះ នៅខាងក្រុមការងារនាងខ្ញុំ យើងនឹងមានដើមបណ្តឹងរដ្ឋប្បវេណីប្រហែលជាមានចំនួន៥នាក់ទៀត ដែលនឹងត្រូវដាក់បញ្ចូលទៅក្នុងអង្គជំនុំជម្រះ ។ ឥឡូវនេះយើងកំពុងតែធ្វើការទំនាក់ទំនងជាមួយគាត់ ដោយសារតែក្រុមយើងទើបតែបង្កើតឡើងអ៊ីចឹងទើបបានជារាងមានបញ្ហាយឺតយ៉ាវបន្តិច ។ អ៊ីចឹងនាងខ្ញុំគ្រាន់តែសូមជូនព័ត៌មានដល់អង្គជំនុំជម្រះ ដើម្បីជ្រាប ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណកញ្ញាមេធាវី ដែលបានផ្តល់ព័ត៌មាននេះ ។

ជាបន្តទៅទៀត តើសហព្រះរាជ អាជ្ញាមានសំណួរអ្វីចង់សួរទៅអង្គភាពជនរងគ្រោះដែរឬទេ?

**លោក គង់ ពិសី៖**

លោកចៅក្រម ខ្ញុំសូមសំណូមពរបន្តិច។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងសូមលោកព្រះរាជអាជ្ញាកុំទាន់ នៅចាំផុតពីសំណូមពររបស់លោកមេធាវីសិន ។ សូមអញ្ជើញលោកមេធាវី ។

**លោក គង់ ពិសី៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមខ្លីទេ គឺថាសំណូមពរទៅឲ្យដល់អង្គភាពជនរងគ្រោះ គឺនៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណី គាត់ដាក់ពាក្យបណ្តឹងទៅអង្គជំនុំជម្រះក្តី ឬក៏ទៅអង្គបុរេជំនុំជម្រះក្តី គឺគាត់តែងតែដាក់ទៅតាមរយៈអង្គភាពជនរងគ្រោះ ហើយនៅពេលដែលគាត់ដាក់ទៅដល់អង្គភាពជនរងគ្រោះហ្នឹង គាត់បានគិតខ្លួនគាត់ថា គាត់ហ្នឹងត្រូវបានតុលាការទទួលស្គាល់ហើយ គាត់រំពឹង គិតថា

អ៊ីចឹង។ ប៉ុន្តែ អង្គភាពជនរងគ្រោះហ្នឹង ទៅរុញពាក្យសុំហ្នឹងទៅដល់តុលាការទៀត បើតុលាការហ្នឹងទទួលស្គាល់ បានមានពាក្យទទួលស្គាល់ហ្នឹងត្រឡប់មកវិញៗ ដល់ទៅគាត់ ដល់ដៃគាត់ ផ្តល់ព័ត៌មានដល់គាត់ អាហ្នឹងទើបគាត់ចាត់ថា ទទួលស្គាល់ទៅតាមផ្លូវច្បាប់ ។ ប៉ុន្តែ គាត់មានការភ័ន្តច្រឡំ ។ មួយចំនួនទេ មានការភ័ន្តច្រឡំថា ឲ្យតែគាត់បានដាក់ពាក្យហ្នឹងទៅដល់អង្គភាពជនរងគ្រោះ គឺគាត់យល់ថាគាត់ត្រូវបានតុលាការទទួលស្គាល់ហើយ ហេតុអីបានជាមេធាវីមិនអញ្ជើញគាត់ឲ្យចូលរួមទៅនេះទៅនោះអ៊ីចឹង? អាហ្នឹងសូមបញ្ជាក់ ហើយចំណុចត្រង់ហ្នឹងទៅដល់អង្គភាពជនរងគ្រោះ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ។ បញ្ហានេះក៏ជាបញ្ហាបច្ចេកទេស នៃនីតិវិធីដំណើរការប្រព្រឹត្តទៅក្នុងការចំណាត់ការលើពាក្យបណ្តឹងសុំរបស់ជនរងគ្រោះដែលតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីដែលថ្មីៗនោះ គឺក៏មានបញ្ហាដែរ ដូចដែលខ្ញុំបានជម្រាបជូនអ៊ីចឹងការកត់សម្គាល់របស់សាលាដំបូងឃើញថា ពាក់ព័ន្ធនឹងសំណួរផង ហើយការសិក្សាស្រាវជ្រាវ ក៏មានបញ្ហានេះ ។

ហើយព័ត៌មាននេះ គឺយើងនឹងធ្វើការកត់ត្រាទុក ដើម្បីធ្វើការសិក្សាស្រាវជ្រាវបន្ថែមទៀត ។ ប៉ុន្តែ ព័ត៌មាននៅខាងក្រោយ លើរបៀបវារៈទី៣ បន្តបន្ទាប់នេះ ប្រហែលជានឹងមានដំណោះស្រាយខ្លះពីបញ្ហានេះ ។ ក៏ប៉ុន្តែ ក៏ប្រហែលជាមិនឆ្លើយតបទៅនឹងការភ័ន្តច្រឡំរបស់ដើមបណ្តឹងរដ្ឋប្បវេណីទេ ដែលគាត់ថាដាក់ត្រឹមតែអង្គភាពជនរងគ្រោះនោះ គឺគាត់ត្រូវបានសន្មតខ្លួនគាត់ថា ចាត់ទុកដូចថាតុលាការហ្នឹងបានទទួលស្គាល់រួចហើយនោះ ដោយសារវាខុសជាមួយនឹងបទប្បញ្ញត្តិនៃវិធាន ។

វិធាននៅក្នុង--វិធាននៃវិធានផ្ទៃក្នុងរបស់យើង ដែលប្រើប្រាស់សព្វថ្ងៃនេះ ការទទួលស្គាល់ជាផ្លូវការនូវដើមបណ្តឹងរដ្ឋប្បវេណីនោះ គឺយើងធ្វើនៅក្នុង--ជាលទ្ធផលនៃដំណោះស្រាយនៅក្នុងអំឡុងពេលនៃសវនាការបឋម ។ ទាល់តែឆ្លងកាត់ពិនិត្យនៅក្នុងសវនាការបឋម ទើបយើងចេញសេចក្តីសម្រេចថាទទួល ឬក៏ច្រានចោល មិនទទួលស្គាល់គាត់ជាភាគីដើមបណ្តឹងរដ្ឋប្បវេណី ។ នេះជាបញ្ហា ។

ហើយបញ្ហាដែលយើងបានកត់ស្គាល់ឃើញថាលំបាកនោះ ដោយសារអំឡុងពេលនៃផុតកំណត់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺមានត្រឹមតែ១០ថ្ងៃមុនថ្ងៃសវនាការបឋមប៉ុណ្ណោះ ។ ប៉ុន្តែ បើលទ្ធភាពរយៈវាខ្លីនេះ វាអាចនាំឲ្យមានបញ្ហានូវហេតុផលទាំងឡាយ នៅក្នុងការដាក់នូវឯកសារបញ្ជីសាក្សី ឬក៏បញ្ជីភស្តុតាងជាដើម ដើម្បីឲ្យមានមូលដ្ឋានក្នុងការសម្រេច ឬការគោរពជូនទៅភាគីពាក់ព័ន្ធផ្សេងទៀត ដើម្បីឲ្យបានជ្រាបអំពីហេតុផលនៃទំនាក់ទំនងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និង

ភស្តុតាងដែលដាក់នោះ ។

អ៊ីចឹងក៏មានបញ្ហាដែរ ប៉ុន្តែដោយសារបញ្ហានេះ ខ្ញុំបានជម្រាបមិញហើយ យើងនឹងធ្វើការរកដំណោះស្រាយនៅក្នុងរបៀបវារៈជាបន្តបន្ទាប់ទៀត ដែលគ្រោងរួចហើយ ។ ហើយបើមានបញ្ហាអ្វី គឺចាំរបៀបវារៈក្រោយសូមយើងពិភាក្សាបន្តបន្ទាប់ឱ្យបានស៊ីជម្រៅលើបញ្ហានេះ។

សូមអញ្ជើញសហព្រះរាជអាជ្ញា តើមានសំណួរអ្វីចង់សួរដល់អង្គភាពជនរងគ្រោះឬទេ?

សូមអញ្ជើញលោកស្រី ជា លាង ។

**លោកស្រី ជា លាង៖**

សូមអរគុណលោកប្រធាន ។ ហើយសូមគោរពអង្គសវនាការទាំងមូល! ខ្ញុំមិនមានសំណួរអ្វីដែលជាក់លាក់ទៅខាងការិយាល័យជនរងគ្រោះទេ ។ ប៉ុន្តែ ជាការព្រួយបារម្ភរបស់ខ្ញុំផ្ទាល់ទេ ដោយសារខ្ញុំគិតថា នៅក្នុងរឿងនេះមានជនរងគ្រោះច្រើនណាស់ ហើយក្នុងករណីដែលជនរងគ្រោះទាំងនោះ គាត់នឹងបន្ថែមចំនួនការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីកាន់តែច្រើននៅក្នុងដំណាក់កាលមួយដែលជិតដល់បើកពេលសវនាការអង្គសេចក្តីរបស់យើង ។

ដូច្នេះខ្ញុំគិតថា តើយើងគួររកវិធានការ ឬមួយរកការដំណោះស្រាយរបៀបណាដើម្បីដោះស្រាយនៅលើចំណុចនេះ? ហើយនេះជាការព្រួយបារម្ភរបស់ខ្ញុំទេ ហើយខ្ញុំសូមឱ្យចៅក្រមជំនុំជម្រះពិចារណានៅលើចំណុចនេះផង ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

លោកស្រីសហព្រះរាជអាជ្ញាជាតិ ដែលបានកត់សម្គាល់អំពីបញ្ហានេះជូនដល់អង្គជំនុំជម្រះសាលាដំបូង ក៏ដូចជាអង្គប្រជុំដែលយើងបានដឹងដែរ ហើយយើងខាងអង្គជំនុំជម្រះសាលាដំបូង ការប្រជុំពិភាក្សាកន្លងមកក៏មានបញ្ហាដែលយើងរិះរកទៅ ឃើញថាមានលទ្ធភាពក្នុងការកើតហេតុនូវបញ្ហាលំបាកៗនេះខ្លះដែរ ។ ប៉ុន្តែ ក៏មានចំណាងមួយដែរនៅក្នុងវិធានផ្ទៃក្នុង យើងបានកំហិតនូវដំណោះស្រាយនៃការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺបាននៅក្នុងរយៈពេល១០ថ្ងៃ នៃថ្ងៃធ្វើការ មុនថ្ងៃបើកសវនាការបឋម ។

អ៊ីចឹងមានន័យថា ប្របើសិនជាគាត់ដាក់ក្រោមនេះ យើងនឹងមិនទទួលគាត់ជាដើមបណ្តឹងរដ្ឋប្បវេណីទេ ។ យើងមិនពិនិត្យលើបណ្តឹងនោះទេ ។ នេះជាបទប្បញ្ញត្តិនៃវិធាន ដើម្បីយើងសម្រួលបញ្ហានេះ ។ បញ្ហានេះក៏ពាក់ព័ន្ធនឹងបញ្ហាមិញដែរ ដែលបទបង្ហាញរបស់ប្រធានអង្គភាពជនរង

គ្រោះ ដែលបានលើកឡើងពីបញ្ហាការដែលផ្សព្វផ្សាយនូវព័ត៌មានស្តីពីកាលបរិច្ឆេទចុងក្រោយនៃការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានចែងនៅក្នុងវិធាននេះ គ្រាន់តែបានធ្វើហើយ ប៉ុន្តែគ្រាន់តែមិនបានទូលំទូលាយប៉ុណ្ណោះ ។

ហើយបញ្ហាដូចខ្ញុំលើកឡើងមិញថា បញ្ហាដែលកង្វល់របស់អង្គភាព--អង្គជំនុំជម្រះសាលាដំបូងនោះ ដោយសារហេតុផលនៃបទប្បញ្ញត្តិវិធាន ដែលចែងវិធានផ្ទៃក្នុង បានកំណត់ឱ្យអង្គជំនុំជម្រះសាលាដំបូង កម្រិតត្រឹមតែពិនិត្យសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនានា ក្រៅពីបានតាំងខ្លួននៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬក៏សហព្រះរាជអាជ្ញានោះគឺ យើងអាចធ្វើបានតែក្នុងសវនាការបឋមប៉ុណ្ណោះ ។

អ៊ីចឹងបញ្ហាមិញនេះគឺ ខាងមេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើងហើយ គឺដូចជា២២បណ្តឹង ដែលបានរុញមកអង្គភាពសាលាដំបូង មិនទាន់បានធ្វើការសម្រេចនូវឡើយទេ អំពីបញ្ហានេះ ធ្វើឱ្យមានបញ្ហាស្មុគស្មាញ ឬក៏មិនច្បាស់លាស់ ។ នេះគឺកញ្ញាមេធាវី ទី ស្រ៊ុនណា ដែលបានលើកឡើង ។

ហើយបញ្ហានេះគឺ ដូចខ្ញុំបានជម្រាបអ៊ីចឹងនឹងដំណោះស្រាយនៅរបៀបវារៈក្រោយ ដែលបញ្ហានេះត្រូវបានផ្តល់ជាសំណួរ ដោយលោកស្រីមេធាវី ស៊ីលយ៉ស្ទូតហ្សីនស្កី ។ ហើយយើងនឹងមានដំណោះស្រាយហើយ ហើយនឹងពិភាក្សាគ្នាជាបន្តទៀតលើដំណោះស្រាយ ដែលបានគិតគូរវាងចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ។

មានអ្វីទៀតទេ? សហព្រះរាជអាជ្ញាមានអ្វីទៀតទេ?

ឥឡូវនេះ សមាជិក សមាជិការអង្គប្រជុំ ខ្ញុំគិតថាដូចជាមានការនឿយហត់ណាស់ហើយ ហើយដូច្នេះគឺ ខ្ញុំសូមប្រកាស អនុញ្ញាតសម្រាក១៥នាទី រហូតដល់ម៉ោង១០និង៣០នាទី សូមអញ្ជើញឯកឧត្តម លោក លោកស្រី នាងកញ្ញា ចូលសាលប្រជុំវិញ ដើម្បីបន្តកិច្ចប្រជុំរបស់យើងតទៅទៀត ។ សូមសម្រាក។

*(កិច្ចប្រជុំសម្រាកពីម៉ោង ១០:១៩នាទី ដល់ម៉ោង១០:៤៥នាទី )*

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ។ ជាបន្តទៀតនេះគឺ អង្គជំនុំជម្រះសាលាដំបូងតើមានសំណួរអ្វីសួរដល់មេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីដែរឬទេ?

សូមអញ្ជើញលោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំចង់សួរសំណួរមួយទៅលើលោកមេធាវី ហុង គឹមសួន ថាតើគាត់មានអាចមានរកមើលឃើញលទ្ធភាពទាក់ទងទៅនឹងជម្លោះអត្ថប្រយោជន៍ ចំពោះក្រុមទាំងពីរដែលគាត់ជាអ្នកតំណាងនោះ?

**លោក ហុង គឹមសួន៖**

សូមអរគុណលោកស្រីចៅក្រម ។ នៅក្នុងក្រុមទីពីរខ្ញុំបាទដើមដំបូងមានមេធាវីអន្តរជាតិ កញ្ញា ស៊ីលឃី ស្ទូតហ្សិនស្គី មិនមានបញ្ហានឹងទំនាស់ផលប្រយោជន៍ទេ ។ ហើយនិយាយអំពីទំនាស់ផលប្រយោជន៍រវាងក្រុមទីពីរនិងក្រុមទីបួនដែលខ្ញុំបាទជាមេធាវីជាតិជាមួយនឹងមេធាវីអន្តរជាតិលោក ព្យែរ អូលីវីយែស័រ ក៏អត់មានបញ្ហាអីដែរ ។

ដោយសារការប្រជុំជាទូទៅយើងខ្ញុំជាមេធាវីជាតិ មេធាវីអន្តរជាតិទាំងប៉ុន្មានក្រុមនេះតែងតែផ្តល់ដំណឹងជូនទៅគ្នា និងផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមក ។ អ៊ីចឹងបើទោះបីជាមានការបើកអង្គសវនាការពេញអង្គសេចក្តីក៏ដោយគឺ យើងមុននឹងធ្វើការ យើងធ្វើការប្រជុំគ្នាសិន និងផ្តល់ឱកាស និងប្តូរយោបល់គ្នាទៅវិញទៅមកសិនដែរ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី ដែលបានឆ្លើយតបនឹងសំណួរនេះ ។

លោកចៅក្រម មានសំណួរអ្វីសួរទៀតទេ?

បើមិនមានទេ គឺយើងបន្តនូវរបៀបវារៈមួយទៀតគឺចំណុច១.ឃ អំពីសមាសភាពរបស់ក្រុមព្រះរាជអាជ្ញា ។ នៅក្នុងរបៀបវារៈនេះ អង្គជំនុំជម្រះសូមសួរទៅសហព្រះរាជអាជ្ញាអំពីសមាសភាពរបស់ក្រុមព្រះរាជអាជ្ញា តើសមាសភាពរបស់ក្រុមព្រះរាជអាជ្ញាដែលត្រូវចូលរួមសវនាការហ្នឹងមានអ្នកណាខ្លះ? សូមអញ្ជើញលោកសហព្រះរាជអាជ្ញា ។

**លោកស្រី ជា លាង៖**

សូមអរគុណ ។

ចំពោះការិយាល័យសហព្រះរាជអាជ្ញា គឺបានរៀបចំនិងត្រៀមខ្លួនជាស្រេចក្នុងការចូលរួមក្នុងសវនាការនៅពេលខាងមុខនេះ ។ ហើយសមាសភាពនោះ គឺមានខាងព្រះរាជអាជ្ញាជាតិនិងអន្តរជាតិ

គឺសហព្រះរាជអាជ្ញាទាំងពីរ សហព្រះរាជអាជ្ញារងទាំងពីរ ហើយនិងមានជំនួយការជាន់ខ្ពស់នៅក្នុងការិយាល័យសហព្រះរាជអាជ្ញា ។

ខ្ញុំសូមបញ្ជាក់បន្តិចដែរអំពីបញ្ហាជំនួយការជាន់ខ្ពស់ ដែលចូលរួមនៅពេលសវនាការនេះដោយ-សារ វាមានការឯកភាពពីអង្គការសហប្រជាជាតិ ឲ្យគាត់ប្រគល់សិទ្ធិនិងអំណាចឲ្យគាត់ក្នុងចូលរួមក្នុងសវនាការ ។ ហើយខាងជាតិនេះក៏ខ្ញុំបានស្នើទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសុំតែងតាំងគាត់ជាព្រះរាជអាជ្ញារងហើយ ទៅតាមផ្លូវច្បាប់នៃនីតិវិធីកម្ពុជានោះ គឺគាត់មានសិទ្ធិពេញលេញក្នុងការឡើងសវនាការនេះដែរ ។

ដូច្នេះ សមាសភាពយើងនៅពេលនេះ ខ្ញុំនៅក្នុងសំណុំរឿង០០១នេះ ខ្ញុំប្រហែលជាមិនបាច់អានឡើងវិញទេ ហើយក៏ត្រូវអានឡើងវិញក៏មិនជាបញ្ហាបន្តិចបន្តួចដែរទេ ។ ហើយខ្ញុំគិតថាមានរូបខ្ញុំផ្ទាល់ ហើយមានលោកសហការីរបស់ខ្ញុំគឺ លោក រ៉ូប៊ីត ពើទីត លោក យ៉េត ចរិយា លោក វាលៀម ស្មីត ដែលជាសហព្រះរាជអាជ្ញារង ហើយមាន លោក តាន់ សេណារ៉ុង លោក អាឡិចសាន់ដឺ ប៊េត ហ្វីង គាត់ជាជំនួយការជាន់ខ្ពស់ខាងអន្តរជាតិក៏មានសិទ្ធិឡើងដែរ ។ ហើយក្រៅពីនេះមាន លោក ជីហ្គិន អាស្មាន ហើយនិង ពេជ្រ សម្បត្តិ ដែលជាអ្នករៀបចំឯកសារ វិភាគឯកសារនោះ ហើយនិងមានលោកក្រឡាបញ្ជីដែរនៅក្នុងការចូលរួមនៅក្នុងសវនាការខាងមុខ ។

ដូច្នេះ ខ្ញុំគិតថាខាងយើងខ្ញុំមិនមានបញ្ហាអីទេ ហើយសមាសភាពនៅក្នុងសំណុំរឿង០០១ នេះគឺមានតែប៉ុណ្ណឹងឯង ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណ លោកស្រីចៅក្រម ដែលបានផ្ដល់ព័ត៌មាននេះដល់អង្គប្រជុំ ក៏ដូចជាដល់អង្គជំនុំជម្រះសាលាដំបូង ។

អស់លោក លោកស្រី ចៅក្រមអង្គជំនុំជម្រះសាលាដំបូង មានសំណួរអ្វីពាក់ព័ន្ធទៅនឹងបញ្ហានេះទេ? បើមិនមានទេ គឺយើងបន្តនូវរបៀបវារៈ-- សូមអញ្ជើញលោកមេធាវី!

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

លោកប្រធាន នេះមិនមែនជាសំណួរទេ ប៉ុន្តែជាសេចក្ដីអធិប្បាយរបស់ខ្ញុំ ខាងក្រុមការពារក្ដីហ្នឹងគឺមានការកត់សម្គាល់ថា-- គឺថាយើងមានៗក្រុមបួននៅទល់មុខយើងនៅក្នុងបន្ទប់សវនាការនេះជាក្រុមតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី ដែលក្រុមនីមួយៗមានមេធាវីជាច្រើន ហើយនៅក្នុងក្រុម

មួយមានមកពីខាងការិយាល័យសហព្រះរាជអាជ្ញា យ៉ាងហោចណាស់ក៏មានមេធាវីប្រាំបីនាក់ដែរនៅក្នុងក្រុមនោះ ។ ចំណែកខាងក្រុមមេធាវីការពារក្ដីរបស់ខ្ញុំឯនេះវិញនេះ ដូចដែលខ្ញុំបាននិយាយប្រាប់លោកប្រធានអ៊ីចឹងគឺថាយើងមាននូវសហមេធាវីតែពីរនាក់ទេ ហើយនិងអ្នកជំនួយការតែពីរនាក់ប៉ុណ្ណោះ ហើយប្រហែលជាអាចមានកម្មសិក្សាការីប្រហែលជាពីរនាក់ទៀត ។ អ៊ីចឹងគឺ នេះអាស្រ័យទៅលើលោកចៅក្រម ដើម្បីចាប់ពិចារណាទៅលើអ្នកដែលបានចូលរួមនៅក្នុងសំណុំរឿងនេះ ។

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណ លោកមេធាវីដែលបានមានចំណាប់អារម្មណ៍លើបញ្ហានេះ ។ ហើយខាងសាលាដំបូងនឹងកត់ត្រាទុកនូវបញ្ហានេះនៅក្នុងកំណត់ហេតុរបស់ខ្លួន ហើយនឹងពិចារណានៅពេលក្រោយ ។

ជាកិច្ចបន្តគឺឈានដល់ការពិភាក្សាលើរបៀបវារៈទីពីរ ដែលពាក់ព័ន្ធទៅនឹងសាក្សីជាមួយនឹងអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ និងផ្នែកគ្រប់គ្រងតុលាការ ។

ហើយខ្ញុំ សូមជម្រាបជូនអស់លោក លោកស្រីថា នៅក្នុងរបៀបវារៈនេះ យើងខ្ញុំសូមប្រគល់តួនាទីនេះជូនទៅលោកស្រីចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ ជាចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះសាលាដំបូង ដើម្បីធ្វើការសម្របសម្រួលនិងបង្ហាញក្នុងនាមខ្ញុំជាប្រធានអង្គជំនុំជម្រះសាលាដំបូង ។

ហើយ របៀបវារៈនេះគឺមានបីចំណុចធំគឺ ចំណុច ២(ក) ២(ខ) និង ២(គ) ។

សូមអញ្ជើញ លោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

អរគុណលោកប្រធាន ។ ខ្ញុំឈ្មោះ ស៊ីលយ៉ា ខាតវ៉ាយថ៍ ។

ចំណុចទីមួយ ក្នុងរបៀបវារៈយើងនៅទីនេះគឺ ពាក់ព័ន្ធជាមួយនឹងវិធានការការពារ ហើយនិងបញ្ហាបច្ចេកទេសខាងផ្នែកភស្តុភារមួយចំនួនក្នុងការគ្រប់គ្រងសាក្សី ក្នុងការមកធ្វើសក្ខីកម្មនៅក្នុងសវនាការ ។ ហើយខ្ញុំចង់ឲ្យនាទីនេះទៅប្រធានអង្គភាពសាក្សី និងគាំពារសាក្សី និងអ្នកជំនាញ ដើម្បីបង្ហាញអំពីបញ្ហាបច្ចេកទេស និងការដឹកជញ្ជូនសាក្សីមកកាន់សវនាការ និងមកធ្វើសក្ខីកម្ម ។

ជាមួយគ្នាផងដែរ ខ្ញុំក៏ចង់ឲ្យលោកស្រីបង្ហាញអំពីធនធានដែលយើងមានទាក់ទងជាមួយនឹងការអនុវត្តវិធានការការពារ ។ ហើយខ្ញុំសូមប្រគល់វេទិកានេះជូនលោកស្រី វ៉ែនឌី ឡូវីន ។ ហើយកុំធ្វើលើសពីម្ភៃនាទី ហើយក្រោយមកអង្គជំនុំជម្រះនឹងសួរសំណួរមួយចំនួនជូនទៅលោកស្រី ហើយខ្ញុំនឹង

00285882



ផ្តល់ឱកាសនេះឲ្យភាគីផ្សេងៗ សួរសំណួរលោកស្រីបានផងដែរ ។ សូមអញ្ជើញលោកស្រី ។

**លោកស្រី វ៉ែនឌី ឡូវីន៖**

សូមអរគុណលោកចៅក្រម ។ ហើយខ្ញុំសូមសម្តែងនូវសេចក្តីរីករាយទាក់ទងជាមួយការបង្ហាញអំពីការរៀបចំសាក្សី ហើយយើងរៀបចំបានល្អ ហើយយើងមានគោលការណ៍មួយដែលយើងធ្វើយ៉ាងម៉េចដើម្បីឲ្យពេលវេលាដែលប្រើនៅក្នុងសវនាការហ្នឹង គឺប្រើឲ្យបានអស់ពីលទ្ធភាពហើយបានត្រឹម-- បានប្រយោជន៍ ។ អ៊ីចឹងទេ យើងក៏នឹងចង់ឲ្យមានសាក្សី យើងដឹកជញ្ជូនគាត់ឲ្យបានជិតសវនាការដើម្បីងាយស្រួលនឹងពេលកោះហៅគាត់ចូលមកធ្វើសក្ខីកម្ម ។

ហើយនៅក្នុងហ្នឹងគឺយើងក៏មិនចង់-- ពេលដែលយើងមានកាលវិភាគច្បាស់លាស់គឺយើងមិនចង់ឲ្យយកសាក្សីមកឆ្ងាយពីផ្ទះច្រើនថ្ងៃពីក្រុមគ្រួសារនោះគាត់ទេ ។ យើងទាក់ទងជាមួយនឹងការរៀបចំកាលវិភាគដើម្បីឲ្យគាត់មកបង្ហាញខ្លួននេះ គឺមានការសំខាន់ណាស់ ។ ព្រោះនៅពេលដែលយើងមានកាលវិភាគនេះ គឺយើងអាចនឹងចាប់ផ្តើមទំនាក់ទំនងជាមួយពួកគាត់ទាក់ទងជាមួយនឹងការដែលត្រូវបង្ហាញខ្លួន ។

ហើយនៅក្នុងនេះគឺយើងនឹងអាចសិក្សាអំពីថាតើសាក្សីនីមួយៗគាត់ត្រូវការការការពារ ឬក៏អ្វី ឬក៏-- ព្រោះអីដើម្បីកុំឲ្យគាត់មានការប៉ះពាល់នៅក្នុងកាលវិភាគមួយចំនួនទៀត ដែលគាត់ត្រូវចូលរួមក្នុងពិធីពិសេសៗនៅក្នុងក្រុមគ្រួសារគាត់ ដូចពិធីអាពាហ៍ពិពាហ៍ ឬពិធីអ្វីផ្សេងៗ ។ ឧទាហរណ៍ ដូចពេលខ្លះអាចនឹងមានការដែលយើងយកគាត់មកឆ្ងាយពីផ្ទះសម្បែងអ៊ីចឹងគាត់មានក្រុមគ្រួសារណាទទួលមរណភាព គាត់ត្រូវរៀបចំពិធីអ៊ីចឹងៗគាត់-- បើសិនជាយើងដឹងកាលវិភាគនេះច្បាស់យើងអាចនឹងមិនឲ្យមានបញ្ហាខ្វាស់នេះទេ ។

ហើយអ្វីដែលយើងមើលទាក់ទងជាមួយនឹងកិច្ចការសាក្សីនេះ គឺយើងបានរៀបចំគាត់ចេញជាពីរក្រុម ។ គឺមួយក្រុម គឺមានលំនៅឋាននៅស្រុកខ្មែរ មួយក្រុមទៀតលំនៅឋាននៅបរទេស ។ ចំពោះអ្នកនៅស្រុកខ្មែរហ្នឹង គឺយើងចែកចេញជាបីទៅទៀត ។ ទីមួយគឺ គាត់រស់នៅក្នុងក្រុងភ្នំពេញ អ៊ីចឹងបានន័យថា គឺមិនពិបាកទេ យើងចំណាយពេលពីរម៉ោងតែប៉ុណ្ណោះ មុននឹងយកគាត់មកធ្វើសក្ខីកម្ម ។ ឯអ្នកទីពីរ អាចថារស់នៅឆ្ងាយដែរ យើងត្រូវការចំណាយពេលមួយថ្ងៃទើបតែអាចដឹកជញ្ជូនគាត់មកដល់ ។ អ៊ីចឹងបានន័យថា ពួកគាត់អាចយើងទៅដឹកគាត់ផ្ទាល់ ឬក៏អាចមកដោយខ្លួនគាត់ក៏បាន ក្នុងរយៈពេលមួយថ្ងៃ ។ ចំណែកឯអ្នកទីបីដែរ គឺអ្នកនៅស្រុកខ្មែរដែលនៅឆ្ងាយចុងកាត់មាត់ញកដែរ បានន័យថា

ឆ្ងាយពីក្រុងភ្នំពេញ ដែលត្រូវការប្រើពេលពីរ-បីថ្ងៃឯណោះទម្រាំដឹកបានមកដល់ ។ ហើយនៅក្នុងនេះ គឺយើងក៏ព្យាយាមទំនាក់ទំនងគាត់ ដើម្បីឲ្យដឹងថា តើយើងធ្វើយ៉ាងម៉េចដើម្បីដឹកគាត់មកកាន់សវនាការបានទាន់ពេល? ហើយយើងក៏សួរអំពីការធ្វើដំណើរ ហើយថាតើបើក្នុងករណីចាំបាច់ គឺយើងត្រូវយកគាត់មកស្នាក់នៅចាំមុន ។

នៅក្នុងនេះគឺទាក់ទងជាមួយនឹងការដែលគ្រប់គ្រងផ្នែកសេវាកម្មទូទៅ គឺយើងមានការរៀបចំអ្នកបើកបរ និងឡានដើម្បីដឹកជូនពួកគាត់ ហើយយើងមានរៀបចំរួចហើយដើម្បីត្រៀមខ្លួននឹងប្រើប្រាស់ ហើយទាក់ជាមួយអ្នកដែលរស់នៅខាងស្រុកក្រៅវិញ គឺយើងក៏ជួយសម្របសម្រួលនូវជើងយន្តហោះដែលគាត់ត្រូវហោះហើរមកកាន់សវនាការដើម្បីធ្វើសក្ខីកម្ម ។

អ៊ីចឹងនៅក្នុងនេះ គឺបានន័យថាបើយើងមានកាលវិភាគច្បាស់លាស់ចំពោះអ្នកដែលនៅស្រុកក្រៅដូចនេះគឺយើងត្រូវតែជម្រាបគាត់មុន ដើម្បីឲ្យគាត់មានពេលបានត្រៀមខ្លួនមកមុន ។ ហើយនៅក្នុងនេះគឺយើងមាន នៅក្នុងកាលវិភាគយើង គឺយើងមានសាក្សីដែលនៅស្រុកក្រៅ ដែលត្រូវមកធ្វើសក្ខីកម្មក៏ប៉ុន្តែនៅក្នុងទាំងអស់នោះ គឺមិនមែនទាំងអស់សុទ្ធតែអាចមកបានទេ ។

សម្រាប់ទាក់ទងជាមួយនឹងកិច្ចការ រឿងដែលយើងត្រូវធ្វើប្រចាំថ្ងៃដែលផ្អែកទៅលើកាលវិភាគសវនាការដែលយើងចាប់នៅម៉ោងប្រាំបីសាបសិបពេលព្រឹកហ្នឹង គឺជាទូទៅក្នុងពេលហ្នឹងគឺប្រហែលជាម៉ោងប្រាំពីរ ទៅម៉ោងប្រាំបីហ្នឹង មុនហ្នឹង គឺយើង--បានន័យថាប្រាំពីរព្រឹក ទៅដល់ប្រាំបីល្ងាច យើងនឹងដឹកពួកគាត់មកហើយ យើងរកសន្តិសុខដើម្បីត្រៀមរៀបចំការពារពួកគាត់ ជាពិសេស គឺនៅពេលដែលជូនគាត់មករកចាំកន្លែងបន្ទប់ដើម្បីធ្វើសក្ខីកម្មហ្នឹង គឺយើងមានមន្ត្រីសន្តិសុខការពារ ។

នៅក្នុងបន្ទប់ការពារ--រង់ចាំធ្វើសក្ខីកម្មនេះ គឺយើងមាននៅក្នុងបន្ទប់ខាងក្រោមនេះគឺជិតទ្វារដើរនេះ គឺជាមានបន្ទប់មួយធំដែលជិតនឹងបន្ទប់សវនាការ ហើយស្រួលនឹងឲ្យគាត់មកធ្វើសក្ខីកម្មភ្លាម ។ បានន័យថា នេះគឺជាកន្លែងដែលស្រួលទុកដាក់គាត់ មុននឹងឲ្យគាត់ឡើងមកធ្វើសក្ខីកម្ម ។

ហើយចំពោះសាក្សីមួយចំនួនទៀតដែលយើងគិតថាគាត់យើងដឹកមកភ្នំពេញ គឺយើងមានបន្ទប់សណ្ឋាគារមួយចំនួនដែលយើងដឹងអំពីសុវត្ថិភាពដែលអាចទុកពួកគាត់ឲ្យស្នាក់នៅទីនោះបាន ។ ហើយនៅក្នុងនេះ លើកលែងតែមានការណែនាំពីភាគី ឬក៏អង្គជំនុំជម្រះ ឬក៏តាមការសម្រេចរបស់យើង យើងចង់ទុកឲ្យសាក្សីហ្នឹងគឺស្នាក់នៅក្នុងមួយ*អូតែល*រួមគ្នា ។ ព្រោះអីយើងមានបុគ្គលិកដើម្បីជួយមើលការងារនៅក្នុងកន្លែងតែមួយបែបនេះ ព្រោះយើងមិនចង់ឲ្យគាត់ជជែកពីរឿងបញ្ហាអីមួយក្នុងចំណោម

គ្នាគាត់នោះទេ ។ ព្រោះឧទាហរណ៍ បើសិនជាសាក្សីដែលត្រូវធ្វើសក្ខីកម្មក្នុងថ្ងៃណាមួយ នៅក្នុងមួយថ្ងៃនោះគឺយើងនឹងយកគាត់ឲ្យដាក់ដាច់ពីសាក្សីមួយក្រុមទៀត ដែលត្រូវធ្វើសក្ខីកម្មនៅថ្ងៃបន្ទាប់អ៊ីចឹង។

ហើយនៅក្នុងនេះ គឺទាក់ទងជាមួយនឹងធនធានរបស់យើង គឺអាចនឹងមានការពិបាកតិចតួចដែរនៅក្នុងការរៀបចំពួកគាត់បន្ទាប់ពីការធ្វើសក្ខីកម្មរួច ។

ខ្ញុំគិតថានេះគឺជាព័ត៌មាននិយាយអំពីបញ្ហាបច្ចេកទេស ឥឡូវខ្ញុំសុំទៅជជែកបន្ទាប់ទាក់ទងជាមួយនឹងសមត្ថភាពរបស់តុលាការរបស់យើងក្នុងការរៀបចំសាក្សីនេះ ។ ដូច្នេះ ឥឡូវយើងមានសាក្សីមួយចំនួន ដែលត្រូវធ្វើសក្ខីកម្មដែលមិនត្រូវទទួលការការពារ បានន័យថាសំឡេងរបស់គាត់ ក៏ដូចជារូបភាពនឹងត្រូវបានកាត់ឬក៏កែ សាក្សីទាំងអស់នេះគឺយើងមានឧបករណ៍រួចទៅហើយ រៀបចំដើម្បីកែសម្រួលក្នុងកិច្ចការងារនេះ ។

ហើយនៅក្នុងដំណាក់កាលនេះ ខ្ញុំឃើញថា សាក្សីទាំងអស់នឹងត្រូវធ្វើសក្ខីកម្មហ្នឹង គឺនៅក្នុងបន្ទប់សវនាការតែម្តង មិនមែនចេញមកពីបន្ទប់ពីចម្ងាយ កន្លែងដែលគាត់រង់ចាំទេ ។ ខ្ញុំមើលមិនទាន់មានសំណើ ដែលសុំឲ្យមានសវនាការជាអសាធារណៈទេ នៅពេលដែលគាត់ត្រូវធ្វើសក្ខីកម្មហ្នឹង ។ ឥឡូវនេះគឺ ខ្ញុំមានសំណើដែលសុំឲ្យធ្វើការកែសំឡេង ឬក៏កែរូបភាពសាក្សី ឬក៏ការប្រើឈ្មោះរហស្សនាមអីជាដើម ។ ល។ នេះ ទាក់ទងជាមួយនឹង-- ហើយសូមឲ្យជួយការពារសាក្សីនៅពេលដែលគាត់ចេញពីបន្ទប់សវនាការ សុំកុំឲ្យមានគេឯងបានឃើញអី ។ នេះគឺជាសំណើដែលខ្ញុំធ្វើកន្លងមក ក៏ប៉ុន្តែយើងមិនទាន់មានសំណើអ្វីផ្សេងទៀតទេ លើកលែងតែភាគីផ្សេងៗលោកលើកឡើងផ្សេងពីហ្នឹង ។

ទាក់ទងជាមួយនឹងអ្វីដែលមិនមានក្នុងរបៀបវារៈទេ ក៏ប៉ុន្តែ វាស្ថិតនៅក្រោមការទទួលខុសត្រូវរបស់យើងដែរ គឺផ្នែកការគាំពារសាក្សីរបស់យើង គឺយើងមានផ្នែកមួយដែលមកពីខាងអង្គការ *ធីភីអូ* ខាងផ្នែកខាងចិត្តសាស្ត្រ ដែលជួយសាក្សីរបស់យើងក្នុងការជួយប្រឹក្សា ឬក៏ពិគ្រោះយោបល់ផ្នែកចិត្តសាស្ត្រទាក់ទងជាមួយនឹងថ្ងៃដែលគាត់ត្រូវឡើងធ្វើសក្ខីកម្ម បើសិនជាយើងចង់បានមន្ត្រីទាំងអស់នោះមកពិគ្រោះយោបល់ ។

ហើយលើកលែងតែអង្គជំនុំជម្រះស្នើខុសពីហ្នឹង ឬក៏ភាគីគាត់ស្នើខុសពីហ្នឹង យើងនឹងណែនាំឲ្យបុគ្គលិកទាំងអស់នោះជួយអង្គុយនៅជាមួយនឹងសាក្សី ដែលត្រូវធ្វើសក្ខីកម្មនោះតែម្តង នៅថ្ងៃដែលគាត់ឡើងមកធ្វើសក្ខីកម្ម ។ បើមិនអ៊ីចឹងទេ លោកខាងអង្គជំនុំជម្រះអាចស្នើអ្វីផ្សេងពីហ្នឹង លោកអាចជម្រាបយើងខ្ញុំបាន ។

ហើយទាក់ទងជាមួយនឹងការដែលជំនួយក្នុងការជួយគាំពារសាក្សី គឺយើងត្រូវការចាំបាច់ឲ្យមានការការពារ ជាពិសេសគឺទាក់ទងជាមួយសំណើសុំឲ្យមានវិធានការការពារ វិធានការស្នើសុំឲ្យមានការធ្វើសក្ខីកម្មតាមរយៈវីដេអូ ឬក៏មិនចាំបាច់បង្ហាញខ្លួនផ្ទាល់ ។ ហើយអ៊ីចឹងទាក់ទងជាមួយនឹងការដែលចង់មានសំណើនេះ ខ្ញុំចង់ឲ្យភាគីទាំងអស់ហ្នឹង ឬក៏សុំស្នើមកខ្ញុំឲ្យបានមុន ចៀសវាងការដែលយើងមិនបានត្រៀមរៀបចំ ហើយនាំឲ្យមានការពន្យារដល់សវនាការ ។ ហើយខ្ញុំគិតថាប៉ុណ្ណឹងអស់ល្មមហើយ ។

សូមអរគុណចំពោះការផ្តល់ឱកាសនេះ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណអ្នកស្រី ឡូវីន ។ មុនពេលភាគីដទៃទៀតនិងមេធាវីមានឱកាសដើម្បីនឹងសួរសំណួរជាក់លាក់នោះ សវនាការនឹងពិចារណាទៅលើសំណើរបស់ខាងក្រុម*វេស្ស* ហើយយើងនឹងអនុញ្ញាតឲ្យអ្នកតំណាងរបស់ខាងផ្នែក*វេស្ស* ទាក់ទងទៅនឹងសាក្សីនីមួយៗ គឺថាអាចអង្គុយផ្ទាល់ជាមួយនឹងសាក្សីអ្នកនោះខ្លះ ប៉ុន្តែគឺថាអ្នកតំណាងនឹងឯងមិនអាចពិភាក្សាបញ្ហានានា ទាក់ទងទៅនឹងសវនាការបានទេ គឺថាអាចផ្តល់ការគាំទ្រទៅតាមតម្រូវការជាក់ស្តែងចាំបាច់ ។

តើលោកប្រធានចង់មានឱកាសដើម្បីនឹងនិយាយ ឬក៏ថ្លែងអ្វីទៀតទេ?

**ប្រធានអង្គជំនុំ៖**

ខ្ញុំមិនមានអីទេ ។

សូមអញ្ជើញ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ខ្ញុំគិតថាអ្នកស្រី ឡូវីន បាននិយាយជាច្រើនទាក់ទងទៅនឹងបញ្ហាទូទៅ អំពីនីតិវិធីក្នុងការដឹកសាក្សី ។ ខ្ញុំចង់ដឹងថា តើលោកស្រីអាចពន្យល់បានទេ ទាក់ទងនឹងនីតិវិធីជាក់ស្តែងក្នុងការផ្តល់ព័ត៌មាន ឬក៏អំពីដីកាមកបង្ហាញខ្លួនដល់សាក្សីទាំងហ្នឹង ដើម្បីមកតុលាការ ជាពិសេសថាតើពេលណាទៅដែលអង្គភាពគាំពារសាក្សីនឹងអាចទាក់ទង ឬក៏ទៅដល់លំនៅឋានរបស់សាក្សីអស់ទាំងហ្នឹង ដែលធ្វើទៅតាមការបែងចែកប្រភេទនៅក្នុងទីក្រុងភ្នំពេញនេះ? សូមអរគុណ ។

**លោកស្រី វ៉ែនឌី ឡូវីន៖**

សូមអរគុណអ្នកស្រីតុលាការ ។ នេះជាបញ្ហាសំខាន់មួយ ហើយខ្ញុំអាចធ្វើការរាយការណ៍ថា

00285886



ខាងផ្នែកគ្រប់គ្រងតុលាការហ្នឹង បានធ្វើការចរចាជាមួយខាងភ្នាក់ងារប៉ូលិសកម្ពុជា ហើយបានស្នើឲ្យពួកគេផ្តល់ជំនួយក្នុងលក្ខណៈជាសមត្ថភាពក្នុងការផ្តល់នូវដីកាឲ្យចូលបង្ហាញខ្លួនហ្នឹងដល់សាក្សីអស់ទាំងនោះ ។ ការចង្អុលបង្ហាញគឺថា ពួកគេមានលទ្ធភាពដើម្បីនឹងធ្វើកិច្ចការនេះ ហើយពួកគេក៏មានឆន្ទៈដើម្បីនឹងធ្វើកិច្ចការនេះដែរ ។

ហើយអ៊ីចឹងក្នុងអំឡុងពេលខាងមុខនេះ គឺថាយើងនឹងប្រៀបធៀបសេចក្តីព្រាងទាក់ទងទៅនឹងនីតិវិធីប្រតិបត្តិការ ហើយដែលយើងនឹងបញ្ជូនទៅខាងផ្នែកប៉ូលិសរបស់រដ្ឋាភិបាលដើម្បីឲ្យពួកគេផ្តល់នូវបទជំនួយទាក់ទងទៅនឹងក្នុងការរៀបចំនេះ ។ ពួកគេមានសមត្ថភាពក្នុងការយកដីកាបង្ហាញហ្នឹងទៅឲ្យសាក្សី ហើយនិងពេលវេលាសម្រាប់ធ្វើដំណើរផងដែរ ។

អ៊ីចឹងខ្ញុំគិតថា ទាក់ទងទៅនឹងវិធាន៤១ ជាវិធានជាក់លាក់ ដែលនិយាយអំពីការប្រើប៉ូលិសយុត្តិធម៌នោះ ។ នេះជាវិធីមួយដែលមានប្រសិទ្ធភាពបំផុត ហើយនេះជាការថែរក្សានូវធនធានមានកម្រិតរបស់យើង ។ ហើយខាងផ្នែកគាំពារសាក្សីនេះក៏នឹងមានធ្វើការស្នើ និងសុំការអនុញ្ញាតសម្រាប់គោលបំណងនេះដែរ សម្រាប់សាក្សីណាមួយដែលត្រូវការវិធានការការពារ ហើយនិងចំនួនអ្នកដែលពាក់ព័ន្ធទៅនឹងសាក្សីជាក់លាក់ណាមួយនោះ ។

ចំណុចមួយដែលជាគំនិតរបស់ខ្ញុំ គឺថាជាការលំបាកណាស់សម្រាប់ខាងតុលាការ ដើម្បីចេញដីកាបង្ហាញខ្លួន សម្រាប់កំណត់កាលបរិច្ឆេទជាក់លាក់ដើម្បីបង្ហាញខ្លួននៅក្នុងសវនាការនោះ ។ ខ្ញុំគិតថាវាអាចជាការប្រយោជន៍មួយដល់ខាងតុលាការ ដើម្បីចេញដីកាមួយដែលមានកំនត់ពេលវេលាជាក់លាក់វែងឆ្ងាយជាង ។ ឧទាហរណ៍ថា មួយសប្តាហ៍ ឬក៏មួយខែដើម្បីឲ្យពួកគេរៀបចំខ្លួន ក្នុងការផ្តល់នូវសក្ខីកម្មនៅក្នុងតុលាការ និងដើម្បីធ្វើការជូនដំណឹងដែលជាក់លាក់ណាមួយ ទាក់ទងទៅនឹងខាងផ្នែកគាំពារការពារសាក្សីនេះ ។ សូមអរគុណ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ ។ អ៊ីចឹងខាងសាលាក្តីសាលាដំបូងនេះ នឹងធ្វើការពិចារណាទៅលើចំណុចដែលអ្នកស្រីបានលើកឡើង ។

អង្គជំនុំជម្រះសាលាដំបូង នឹងស្នើឲ្យខាងភាគីទាំងឡាយទាក់ទងទៅនឹងការគ្រប់គ្រង ការធ្វើសម្បថ ដោយយកចិត្តពិចារណាជាក់លាក់ទៅលើខាងផ្នែកសាសនាព្រះពុទ្ធ និងដោយគិតគូរវិធានការការពារណាមួយដែលមានជាធរមាន ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ដែលថាគ្រប់សាក្សីទាំងអស់

ដែលត្រូវមានមុខនៅចំពោះមុខតុលាការ នឹងត្រូវបានស្នើឲ្យធ្វើសម្បថមុននឹងអាចធ្វើសក្ខីកម្មបាន ។ នេះទោះបីជាសាក្សីទាំងអស់ហ្នឹង បានធ្វើការស្បថរួចទៅហើយនោះ នៅក្នុងដំណាក់កាលពីមុនណាមួយនៅក្នុងសវនាការក៏ដោយ ។

អ៊ីចឹងគ្រប់សាក្សីដែលជាអ្នកកាន់សាសនាព្រះពុទ្ធ នឹងត្រូវធ្វើការស្បថស្បែជារៀងរាល់ព្រឹកមុននឹងផ្តល់សក្ខីកម្ម គឺនៅពីម៉ោងប្រាំបី ទៅម៉ោងប្រាំបីព្រឹកកន្លះ លើកលែងតែសាក្សីដែលបានទទួលវិធានការការពារ នឹងមានការរៀបចំពិសេសមួយសម្រាប់ឲ្យពួកគេនោះ ។ អ៊ីចឹងការធ្វើពិធីសម្បថនោះនឹងធ្វើឡើងនៅចំពោះមុខរូបសំណាកលោកតាដំបងដែក ។ ហើយអ្នកតំណាងឲ្យភាគីនឹងបានទទួលនូវការជូនដំណឹងនេះ នឹងអាចឲ្យចូលរួមនៅក្នុងពិធីសម្បថនេះបាន បើសិនជាបើពួកគេត្រូវបានជម្រាបទៅខាងអង្គការគាំពារសាក្សី និងអ្នកជំនាញឲ្យបានដឹងជាមុន ។ ចំពោះសាក្សីផ្សេងទៀត ដែលមិនមែនជាអ្នកកាន់សាសនាព្រះពុទ្ធនោះ នឹងអាចធ្វើការសម្បថហ្នឹងផ្ទាល់នៅក្នុងតុលាការតែម្តង មុនពេលពួកគេផ្តល់នូវសក្ខីកម្ម ។

តើខាងផ្នែកគាំពារសាក្សី និងអ្នកជំនាញហ្នឹង មានអ្វីបន្ថែមទៀតទេទាក់ទងនឹង ការធ្វើសម្បថនោះ?

**លោកស្រី វ៉ែនឌី ឡូវីន៖**

ខ្ញុំចង់ប្រាប់ទៅលោកស្រីតុលាការថា--ចៅក្រមថា យើងនឹងត្រូវមានអត្ថបទណាទាក់ទងទៅនឹងពាក្យសម្បថសម្រាប់សាក្សីអស់ទាំងនោះ? ហើយត្រូវមាននៅក្នុងបន្ទប់តុលាការផង ហើយយើងត្រូវមានធនធានគ្រប់គ្រាន់សម្រាប់រយៈពេលពីម៉ោងប្រាំបី ទៅម៉ោងប្រាំបីសាមសិបនាទី ។ ប្រហែលជាអាចត្រូវមានក្រឡាបញ្ជីដើម្បីរៀបចំសម្រួលនៅក្នុងការធ្វើសម្បថនេះ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណអ្នកស្រី ។ តើមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមានសំណួរអ្វីទេ ទាក់ទងទៅនឹងខាងផ្នែកគាំពារសាក្សី និងអ្នកជំនាញ?

មេធាវី ស៊ីលឃី ស្ទួតហ្សីនស្គី មានសំណួរអ្វីទេ?

**លោកស្រី ស៊ីលឃី ស្ទួតហ្សីនស្គី៖**

លោកស្រីចៅក្រម ខ្ញុំចង់ផ្តល់ព័ត៌មានមួយដែលអ្នកស្រី-- ឬក៏ដែលខាងផ្នែកគាំពារសាក្សីមិនមាននោះ គឺទាក់ទងទៅនឹងឯកសារមួយ ឬក៏បទសម្ភាសន៍ដែលបានកើតឡើងជាមួយនឹងសាក្សីក្នុងករណី

នៅក្នុងសំណុំរឿងទីពីរ ដែលមាននៅក្នុងសំណុំរឿងនៅថ្ងៃទី៥ ខែមករានេះ ។ ហើយខ្ញុំចង់ឲ្យអ្នកស្រីចៅក្រមត្រូវបញ្ចូលឯកសារហ្នឹង-- ផ្តល់ជាព័ត៌មានទៅឲ្យផ្នែកខាងគាំពារសាក្សីនិងអ្នកជំនាញ ពីព្រោះសាក្សីនេះបាននិយាយអំពីភាពផ្សេងគ្នានៃស្ថានភាពទូទៅ។ ពីព្រោះរឿងនេះនៅក្នុងសំណុំរឿងទីពីរ ខ្ញុំមិននិយាយបញ្ហាជាក់លាក់ទេ គឺនិយាយតែពីបញ្ហាទូទៅ គឺទាក់ទងពីវិធីដែលអ្នកទាំងនោះបានធ្វើទៅលើគ្រួសារ និងនីតិវិធីផ្សេងទៀត ជានីតិវិធីផ្ទាល់ ទាក់ទងទៅនឹងសាក្សីខ្លួនឯងផ្ទាល់ ។

ដូច្នេះហើយ-- អ៊ីចឹងជាលទ្ធផលនោះ សាក្សីនេះបាននិយាយថា គេបានផ្តល់ការណែនាំមកឲ្យខ្ញុំបញ្ជាឲ្យខ្ញុំហ្នឹងធ្វើដូច្នេះ ។ ហើយខ្ញុំចង់ឲ្យផ្នែកគាំពារសាក្សី និងអ្នកជំនាញត្រូវធ្វើការពិចារណា ហើយពិចារណាម្តងទៀត ទៅលើសំណួរទាក់ទងទៅនឹងវិធានការការពារ ដែលសម្រាប់សាក្សីដែលមានប្រវត្តិបែបនេះ មុននឹងធ្វើការផ្តល់នូវសក្ខីកម្ម ។

ខ្ញុំអាចធ្វើការផ្តល់ឯកសារនេះទៅឲ្យខាងបាន ឬក៏ឲ្យលេខឯកសារទៅខាងផ្នែកគាំពារសាក្សីនឹងបាន ដើម្បីឲ្យបញ្ចូលឯកសារនេះនៅក្នុងសេចក្តីសម្រេចដែលធ្លាប់បានធ្វើពីមុនហើយជាមួយនឹងផ្នែកខាងគាំពារសាក្សីនោះ ។

**លោកស្រី វ៉ែនឌី ឡូវីន៖**

ខ្ញុំចង់ជម្រាបសួរថា តើអាចឲ្យយើងដឹងបានច្បាស់ដែរឬទេ ទាក់ទងជាមួយនឹងសាក្សីដែលយើងនឹងត្រូវធ្វើសវនាការនោះ គឺយើងធ្វើនៅក្នុងសំណុំរឿងលេខមួយដែរឬក៏យ៉ាងម៉េច?

**លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី៖**

បើតាមខ្ញុំដឹង ចំណុចនេះគឺមិននៅក្នុងសំណុំរឿងលេខមួយទេ គ្រាន់តែថានេះជាបញ្ហារឿងសុវត្ថិភាពៗដល់សាក្សីដែលគេបានធ្វើសវនាការរួចទៅហើយប៉ុន្មានខែមុនហ្នឹង ហើយដែលមានគេទៅរកគាត់ ។ នៅក្នុងនេះហើយដែលយើងគិតថាវាជាការពាក់ព័ន្ធមួយដែរសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ហើយគាត់អាចនឹងប៉ះពាល់នៅក្នុងសំណុំរឿងលេខមួយដែរ បានន័យថា ឈ្មោះនេះគឺខាងសហព្រះរាជអាជ្ញាមិនបានដាក់ឈ្មោះ ហើយភាគីក៏មិនបានដាក់ឲ្យថាមានពាក់ព័ន្ធនឹងរឿងលេខមួយដែរ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៍៖**

ខ្ញុំគិតថាលោកស្រីគួរតែផ្តល់ព័ត៌មាននេះទៅលោកស្រី ឡូវីន ហើយសង្ឃឹមថាលោកស្រី នឹងពិចារណាអ្វីដែលលោកស្រីបានលើក ។ សូមអរគុណ ។

ឥឡូវនេះ ខ្ញុំជម្រាបសួរថាតើខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីលោកមានចម្ងល់ ឬក៏មានបញ្ហា

អីផ្សេងទៀតត្រូវដាក់ជូនទៅខាងអង្គភាពគាំពារសាក្សី និងអ្នកជំនាញដែរទេ?

ឥឡូវសំណួរបន្តទៅទៀត ខ្ញុំចង់សួរទៅខាងសហព្រះរាជអាជ្ញាម្តង ថាតើលោកមានចម្ងល់អីចង់ដាក់ទៅខាង *វេស្ស* ទេ? សូមឱ្យលោក ពើទីត ។

**លោក រ៉ូប៊ីត ពើទីត៖**

អរុណសួស្តីលោកចៅក្រមទាំងអស់! តាមពិតខ្ញុំមានសំណួរពីរ ។ ទីមួយគឺខ្ញុំចង់សួរគឺជាសំណួរទូទៅទេ ទាក់ទងជាមួយនឹងគោលបំណងនៃការទទួលបានព័ត៌មាននេះ ឬក៏គោលបំណងនៃព័ត៌មាននេះ ។ ទាក់ទាក់ទងជាមួយថាតើនរណាគេប្រាប់ខាងសាក្សីអំពីវិធានការការពារនេះ ព្រោះថាតើជាការងាររបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ឬក៏ភាគីជាអ្នកដែលត្រូវជម្រាបទៅដល់សាក្សី ឬក៏--នោះ?

ហើយទីពីរ យើងធម្មតាយើងធ្វើសក្ខីកម្មនៅក្នុងសវនាការចំហនិយាយពីបញ្ហានេះ ។ អ៊ីចឹងបើសិនជាយើងធ្វើសក្ខីកម្មក្នុងលក្ខណៈចំហដូច្នេះ គឺយើងត្រូវតែមើលទាក់ទងជាមួយនឹងសាក្សី អ៊ីចឹងបានន័យថាវិធានការការពារអីផ្សេងៗដែលយើងចង់បានហ្នឹង គឺទាល់តែយើងជូនជម្រាបដំណឹងនេះទៅអង្គភាពការពារសាក្សី និងអ្នកជំនាញឱ្យបានដឹងមុនសិន មុននឹងគាត់នឹងយល់មកដល់ ។ ហើយ-- ព្រោះយើងមិនអាចនឹងលើកសំណើនេះនៅក្នុងពេលដែលធ្វើសវនាការតែម្តងនោះទេ ។ សូមអរគុណ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

លោកស្រី ឡូវីន លោកស្រីចង់ឆ្លើយតបជាមួយនឹងលោក រ៉ូប៊ីត ពើទីត ឬយ៉ាងម៉េច?

**លោកស្រី វ៉ែនឌី ឡូវីន៖**

សូមអរគុណលោកស្រីចៅក្រម ។ តាមពិតទាក់ទងជាមួយនឹងការផ្តល់វិធានការការពារទៅដល់សាក្សីនោះ គឺយើងមានវិធីច្រើនដែលបានទទួលព័ត៌មាន បានន័យថាគេអង្គភាពយើងគឺក្នុងការផ្តោតព័ត៌មានទៅសាក្សីហ្នឹង គឺបានន័យថាវិធានការការពារហ្នឹងយើងជម្រាបពួកគាត់បានជាមុន ហើយពួកគាត់ត្រូវតែទាមទារឱ្យមានវិធាការការពារបែបនេះ គឺគាត់ត្រូវតែជម្រាបមក *វេស្ស* ឱ្យបានមុនផងដែរ មុននឹងយើងយកគាត់មកធ្វើសក្ខីកម្មនៅក្នុងសវនាការ ហើយខ្ញុំក៏ស្នើសុំទៅខាងសហព្រះរាជអាជ្ញាផងដែរ ក៏ដូចជាសហចៅក្រមស៊ើប ចំពោះសាក្សីទាំងឡាយណាដែលគាត់បានធ្វើសក្ខីកម្ម-- ធ្វើសវនាការហើយៗ ដែលបានស្នើសុំឱ្យវិធានការការពារ យើងចង់ឱ្យមានសួរសំណួរទៅពួកគាត់ថា តើពួកគាត់ធ្លាប់មានបញ្ហាសុវត្ថិភាពយ៉ាងម៉េច? ដោយការប្រមើលមើលតាមស្ថានភាពជាក់ស្តែងរបស់គាត់ដោយ

00285890



ខ្លួនគាត់ហ្នឹង ។ ហើយខ្ញុំចង់ដឹងដែរថាតើ យើងដែលបានជួបសាក្សីទាំងអស់នោះ ហើយជជែកពិគ្រោះជាមួយគាត់ពីបញ្ហាហ្នឹងដែរឬទេ? ពីព្រោះនៅក្នុងដំណាក់ស៊ើបអង្កេតហ្នឹង គឺយើងមែនទែនទៅពឹងពាក់ទៅលើ តែសំណួរនិងការសម្ភាសន៍របស់ខាងសហចៅក្រមស៊ើប ដែលគាត់មកផ្តល់ដំណឹងឱ្យយើង ជាពិសេសពេលដែលគាត់កង្វល់ ខ្លាចក្រែងសាក្សីហ្នឹង មានបញ្ហាសន្តិសុខអ៊ីចឹង។ ហើយទាក់ទងជាមួយនឹងសហចៅក្រមស៊ើបនិងអ្នកស៊ើបអង្កេតហ្នឹង បន្ទាប់ពីកិច្ចពិភាក្សាជាមួយគាត់ទើបបានយើងអាចទៅជម្រាបសាក្សី ជាពិសេសទាក់ទងជាមួយនឹងកង្វល់នៃបញ្ហាសន្តិសុខហ្នឹង ។ អ៊ីចឹងនៅក្នុងនេះ ជាសង្ខេបទៅ អ្វីដែលយើងប្រាប់សាក្សីអំពីវិធានការការពារកន្លងមកនេះ គឺវាជាការពិបាកដែរក្នុងការដែលយើងថា យើងត្រូវជូនវិធានការការពារទៅដល់គាត់ ។ ជាទូទៅអ្វីដែលយើងចង់ធ្វើដើម្បីផ្តល់វិធានការការពារបាន យើងត្រូវពិភាក្សាជាមួយគាត់ ហើយវាយតម្លៃទៅលើស្ថានភាពសន្តិសុខ ហើយជាពិសេស និងផែនការដែលគាត់ចង់បានឱ្យគេការពារយ៉ាងម៉េច? ពីព្រោះជាទូទៅ គឺគាត់ចង់ឱ្យមានវិធានការការពារមួយដែលគាត់ថាមិនចង់ឱ្យគាត់ហ្នឹងនៅក្នុង ឬជួបមន្ត្រីតុលាការនៅស្រុកភូមិរបស់គាត់ ហើយឱ្យគាត់ទៅ យកគាត់ទៅភូមិថ្មី ព្រោះគាត់មិនចង់ឃើញអ្នកធ្វើដំណើរអីទៅជិះឡានទៅឃើញដូចជាសម្បើមអ៊ីចឹង។

អ៊ីចឹងនៅក្នុងនេះ គឺខ្ញុំថា បើសិនជាភាគីគាត់ចង់ស្នើមកខាងអង្គជំនុំជម្រះតាមរយៈអង្គជម្រះ គឺស្នើសុំឱ្យមានការវាយតម្លៃទៅលើហានិយភ័យ ទៅលើសន្តិសុខផ្ទាល់ខ្លួនរបស់សាក្សីទាំងនោះ គឺបើសិនជាយើងបានដឹងមុន គឺយើងនឹងអាចធ្វើបានវាស់វែងអំពីភាពរងគ្រោះនេះ និងការដែលត្រូវផ្តល់វិធានការការពារ ។

ទាក់ទងជាមួយសំណួរទីពីរ នេះគឺអ្វីដែលខាងអង្គភាពគាំពារសាក្សីនិងអ្នកជំនាញកំពុងតែពិនិត្យមើលហើយ ជាពិសេសទាក់ទងជាមួយនឹងថ្ងៃដែលត្រូវធ្វើសវនាការតែម្តង ហើយនៅក្នុងនេះយើងកំពុងតែរៀបចំធ្វើឱ្យមានគោលការណ៍ដើម្បីពិនិត្យមើល ថាតើនៅក្នុងថ្ងៃដែលសាក្សីឡើងមកសវនាការ ហ្នឹងគាត់នឹងស្ថានភាពជាក់ស្តែងនៅក្នុងបន្ទប់សវនាការយ៉ាងម៉េច? ហើយនៅពេលនោះឯង ដែលយើងនឹងវិភាគមើលថាតើយើងគួរធ្វើយ៉ាងម៉េចដើម្បីការពារសាក្សីនោះ? យើងដឹងហើយថា មានមេធាវីរបស់សាក្សីបានផ្តល់ប្រឹក្សាយោបល់ផ្នែកច្បាប់ទៅសាក្សីមួយចំនួនកន្លងមកហើយទាក់ទងជាមួយកិច្ចការនេះ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៍៖**

តើមានសំណួរអីទៀតទេ ពីខាងសហព្រះរាជអាជ្ញា ។ អត់មានទេ? សូមអរគុណអ៊ីចឹង។

តើសហមេធាវីរបស់ជនជាប់ចោទហ្នឹងមានសំណួរអីទេ ឬក៏មានសេចក្តីអធិប្បាយអ្វីទេ ទៅលើបញ្ហាទាក់ទងទៅនឹងអង្គភាពការពារសាក្សី និងអ្នកជំនាញ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណអ្នកស្រីចៅក្រម ។ ខ្ញុំចង់ឆ្លៀតឱកាសនេះ ដើម្បីនិយាយអំពីបញ្ហាទាក់ទងទៅហ្នឹងសាក្សីដែលត្រូវមកតុលាការនេះ ។ ខ្ញុំជឿជាក់ថា គឺជាបញ្ហាសំខាន់បំផុត សម្រាប់ដូចជាក្នុងករណីផ្សេងៗសំខាន់ៗរបស់តុលាការដទៃទៀតដែរ ។ ខាងផ្នែកគាំពារសាក្សី ត្រូវធ្វើការផ្តល់សេវាដល់សាក្សីនីមួយៗដែលចូលរួមផ្តល់សក្ខីកម្មនៅក្នុងតុលាការនេះ និងត្រូវនៅជាមួយក្នុងអំឡុងពេលសម្រាកសម្រាប់ឲ្យដើម្បីឲ្យសាក្សីនោះបានយល់ដឹងច្បាស់លាស់ពីទីតាំងនិងទីកន្លែងរបស់តុលាការនេះ មុននឹងផ្តល់នូវសក្ខីកម្ម ។ ខាងផ្នែកគាំពារការពារក្តីក៏បានផ្តល់ព័ត៌មាននេះទៅខាងផ្នែកគាំពារសាក្សីដែរ ថានេះជាចំណុចមួយក្នុង-- បើសិនសាក្សីណាមួយដែលមានបំណងចង់ផ្តល់នូវសក្ខីកម្មតាមរយៈតាមវីដេអូ ។ ហើយបន្ទាប់មកទៀត ខ្ញុំក៏យល់ដែលថាក្នុងដំណាក់កាលនេះ និងកំណត់សម្គាល់ថា បើទីកន្លែងអង្គុយ ហើយនិងកន្លែងអង្គុយសម្រាប់ភាគីដទៃៗទៀតនោះ គឺថាដូចជាអត់មានវីដេអូសម្រាប់មើលឃើញទេ ។ អ៊ីចឹងខ្ញុំយល់ថា ជាការចាំបាច់ណាស់ដើម្បីធ្វើការកត់សម្គាល់នេះ ដើម្បីឲ្យផ្តល់នូវ បើកអេក្រង់វីដេអូរអំពីសវនាការដែលកំពុងដំណើរការក្តីនោះ ជាពិសេសសំខាន់បំផុតសម្រាប់នៅពេល ដែលសាក្សីផ្តល់សក្ខីកម្មតាមរយៈវីដេអូនោះ ។ ហើយខ្ញុំនឹងមានសំណួរបន្ថែមទៀតនៅពេលក្រោយ ទាក់ទងទៅនឹងសាក្សីខ្ញុំប្រកាសនៅពេលក្រោយ ។ សូមអរគុណ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោក រូ ។ តើមានលោកចៅក្រមណាចង់លើកបញ្ហាអ្វីទេ សម្រាប់សួរទៅខាងផ្នែកវិធានការ ផ្នែកគាំពារសាក្សី?

**ចៅក្រម ហ្សង់ ម៉ាកឡាវែន៍៖**

អ្នកស្រីបាននិយាយថា អ្នកអាចមានលទ្ធភាពដែលសាក្សីនឹងអាចចូលរួមប្រជុំជាមួយខាងផ្នែកត្រូវការគាំទ្រពីអង្គការផ្សេងៗនោះ ទាក់ទងទៅនឹងផ្នែកផ្លូវចិត្តរបស់គេ ។ តើពួកគេមានសមត្ថភាព ឬក៏មានការលំបាកយ៉ាងណានោះទាក់ទងទៅនឹងផ្នែករៀងកាយក្តី ឬក៏ខាងផ្នែកផ្លូវចិត្តក្តី? ថាតើមានសេចក្តីថ្លែងការណ៍ជាក់លាក់ ឬអធិប្បាយជាក់លាក់ណាមួយទាក់ទងទៅនឹងសាក្សីណាមួយ ឬក៏សំណើជាក់លាក់ណាមួយទាក់ទងទៅនឹងតម្រូវការដើម្បីផ្តល់ការគាំទ្របែបនេះ?

00285892



E1/1.1

**លោកស្រី វ៉ែនឌី ឡូវីន៖**

សូមអរគុណលោកចៅក្រម ។ ខ្ញុំដឹងថា មានការពិភាក្សាគ្នាទាក់ទងទៅនឹងបញ្ហាបច្ចេកទេសដើម្បីសម្រួលដល់ដំណើរការពេលឡើងជណ្ដើរសម្រាប់សាក្សីដែលមានបញ្ហារាងកាយ ខ្ញុំអាចយល់ដែរថា មានសាក្សីខ្លះដែលទាក់ទងនៅក្នុងតុលាការ ដែលខ្លះអាចមានបញ្ហាជាប្រចាំ ជំងឺជាប្រចាំផ្ទាល់ខ្លួនហើយយើងអាចមានជំនួយខ្លះដែរពីដែលយើងមានបន្ទប់រង់ចាំទីបីនៅក្នុងពេលនេះ សម្រាប់សាក្សីនោះស្នាក់នៅបណ្ដោះអាសន្ន ហើយប្រហែលជាខ្ញុំមិនចាំបាច់និយាយប្រាប់អ្នកចូលរួមនៅក្នុងកម្មវិធីទេ គឺយើងមានលទ្ធភាពដើម្បីនឹងផ្ដល់នោះ ។ហើយជាបច្ច័យអាក្រក់គឺថាបន្ទប់ហ្នឹង គឺថាវាមិននៅជិតជណ្ដើរយើងឡើងទេ អ៊ីចឹងយើងបាននិយាយខាងផ្នែកក្រុមវិជ្ជបណ្ឌិតហើយ ទាក់ទងទៅនឹងការជួយសាក្សីដែលត្រូវការជំនួយបែបនេះ ពីខាងក្រុមវេជ្ជបណ្ឌិតនោះ ។ ហើយយើងនឹងពិនិត្យពិចារណា ពិភាក្សាទៅលើបញ្ហានេះដែរ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

តើមានសំណួរអីទៀតទេ? សូមអរគុណទៀតអ៊ីចឹង។ ឥឡូវហ្នឹង គឺយើងនឹងបន្តទៅ លើបញ្ហាទាក់ទងទៅនឹងបញ្ជីសាក្សី ឈ្មោះសាក្សី ហើយនឹងទាក់ទងនឹងភ័ស្តុភារក្នុងការរៀបចំបញ្ជីសាក្សីនោះ ។ ខាងអង្គជម្រះសាលាដំបូងនេះ បាននិយាយអំពីការ-- បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ ដែលខាងសហព្រះរាជអាជ្ញាចង់ហៅនៅពេលជំនុំជម្រះ ព្រមទាំងឯកសារបន្ថែមដែលខាងផ្នែកអង្គជំនុំជម្រះបានដាក់ឲ្យស្នើកាលពីថ្ងៃទី១១ ខែធ្នូ ២០០៨ នោះ ។ បើតាមវិធាន៨០ស្ទួនហ្នឹង អង្គជំនុំជម្រះនឹងពិចារណាបញ្ជីទាំងនោះ និងបញ្ជីបន្ថែមទៀតនៅក្នុងអំឡុងពេលសវនាការបឋម ប៉ុន្តែដើម្បីការដឹកនាំកិច្ច ដំណើរការនីតិវិធីប្រព្រឹត្តដោយយុត្តិធម៌និងឆាប់រហ័ស អង្គជំនុំជម្រះបានពិនិត្យឡើងវិញលើបញ្ជីនោះ និងឯកសារដែលភាគីបានដាក់នៅពេលកន្លងមក ដើម្បីវាយតម្លៃអំពីការអនុវត្តជាផ្លូវការតាមដីកា ដែលអង្គជំនុំជម្រះបានចេញកាលពីថ្ងៃទី១១ ធ្នូ ឆ្នាំ២០០៨ ។

ទាក់ទងទៅនឹងបញ្ជីរបស់សហព្រះរាជអាជ្ញានិងឯកសារបន្ថែមនោះ សហព្រះរាជអាជ្ញាបានដាក់បញ្ជីបន្ថែមកាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៨ ជាភាសាខ្មែរនិងភាសាអង់គ្លេស ។ លើសពីនេះទៀតសហព្រះរាជអាជ្ញាក៏បានដាក់សេចក្ដីសង្ខេបអង្គហេតុ ដែលក្នុងអង្គហេតុនោះ គឺអ្វីដែលពួកគេរំពឹងថាសាក្សី និងអ្នកជំនាញហ្នឹងធ្វើសក្ខីកម្ម និងបញ្ជីឯកសារថ្មីៗទៀតដែលពួកគេចង់ផ្ដល់នៅក្នុងសំណុំរឿងនេះផងដែរ ។

ចំណែកខាងមេធាវីការពារក្ដីជនជាប់ចោទ ត្រូវបានជូនដំណឹងអំពីបញ្ជីសាក្សី និងឯកសារបន្ថែមទៀតជាភាសាបារាំង ។ ខាងសហព្រះរាជអាជ្ញាបានបញ្ជាក់ថា ពួកគាត់ពុំមានបំណងផ្ដល់ជូនជាភស្តុតាងណាមួយដែលមានទម្រង់ជាវត្ថុជាក់ស្ដែងទេ គឺពួកគាត់គ្រាន់តែឯកសារភស្តុតាងដែលបានស្កេនរួចហើយដូចមាននៅក្នុងសំណុំរឿងបច្ចុប្បន្ននេះ ដែលរួមមាន ឯកសារ រូបភាព និងវីដេអូ ។ ព្រះរាជអាជ្ញាក៏បានបញ្ជាក់ផងដែរថា នៅក្នុងដំណាក់កាលនេះពួកគាត់មិនទាន់អាចបញ្ជាក់អំពីបញ្ហាច្បាប់ ដែលពួកគាត់មានបំណងលើកនៅក្នុងសវនាការបឋមបាននៅឡើយទេ ។ ប៉ុន្ដែ បន្ទាប់ពីកិច្ចប្រជុំនៅថ្ងៃនេះពួកគាត់នឹងអាចផ្ដល់ព័ត៌មានដល់អង្គជំនុំជម្រះ អំពីបញ្ហាសំខាន់ៗដែលបំណងចង់លើកឡើង ។

ចំណែកបញ្ជីឈ្មោះដែលខាងសហព្រះរាជអាជ្ញាបានដាក់ជូននោះ គឺមានឈ្មោះសាក្សីចំនួន៣៥រូប ដែលពួកគាត់មានបំណងកោះហៅនៅពេលជំនុំជម្រះ ក្នុងនោះគឺមានសាក្សីពីរនាក់ ដែលពួកគាត់ចាត់ថា ជាអ្នកជំនាញ ពាក់ព័ន្ធនឹងបញ្ហានេះអង្គជំនុំជម្រះសូមបញ្ជាក់ថា វាជាការមួយល្អនៅពេលខាងមុខ ដែលគួរឲ្យមានការបែងចែងមួយឲ្យបានច្បាស់លាស់រវាងសាក្សីនិងអ្នកជំនាញ ។ នេះគឺយោងទៅតាមបញ្ញត្តិនៃវិធាន២៤ និង ៣១ ។ ពីរនាក់ក្នុងចំណោមសាក្សីដែលស្នើនោះ គឺបច្ចុប្បន្នជាភាគីដើមរដ្ឋប្បវេណីនៅក្នុងដំណើរការនៃនីតិវិធីនេះ ហើយបើតាមព័ត៌របស់សហព្រះរាជអាជ្ញា ឈ្មោះពួកគាត់ត្រូវបានបញ្ចូលទៅក្នុងបញ្ជីនោះ ដោយហេតុថា ពួកគាត់បានសម្រេចចិត្តបោះបង់ចោលពាក្យទាមទារសំណងរដ្ឋប្បវេណីរបស់ខ្លួនផ្ទាល់ ។ សាក្សីដែលបានស្នើទាំងអស់ហ្នឹងឯង ត្រូវបានសម្គាល់ដោយឈ្មោះពិតប្រាកដនិងរហស្សនាមរបស់ពួកគាត់ ។ បច្ចុប្បន្ននេះ អង្គជំនុំជម្រះកំពុងតែពិគ្រោះជាមួយខាងផ្នែកអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ដើម្បីធ្វើការវាយតម្លៃថា តើមានតម្រូវការចាំបាច់ណាមួយដើម្បីឲ្យមានវិធានការពារសម្រាប់សាក្សីដែលបានស្នើនោះ? វិធានការការពារ ជាវិធានការការពារពាក់ព័ន្ធនឹងសាធារណជន និង/ឬ ក៏គូភាគីណាមួយ ។ ដូច្នេះ ដើម្បីជាសម្រួលកុំឲ្យមានឯកសារយោងច្រើននិងដើម្បីយើងកំពុងរង់ចាំទទួលយោបល់ពីអង្គការគាំពារសាក្សីនិងអ្នកជំនាញ បើយើងនឹងយោងសាក្សី និងអ្នកជំនាញទាំងអស់នោះ ដោយប្រើរហស្សនាមរបស់ពួកគាត់ ។

សហព្រះរាជអាជ្ញាក៏បានបញ្ជាក់ផងដែរថា លំដាប់លំដោយក្នុងបញ្ជីឈ្មោះដែលបានស្នើឡើងដូចដែលរៀបចំក្នុងបញ្ជីនោះស្រាប់ គឺជាលំដាប់លំដោយដែលសាក្សីនិងអ្នកជំនាញ គួរយកបង្ហាញក្នុងពេលសវនាការ ។ ជាសរុបនោះឯង គឺខាងសហព្រះរាជអាជ្ញាបានធ្វើការប៉ាន់ប្រមាណថា នឹងមានថ្ងៃជំនុំជម្រះប្រហែលជា៤០ថ្ងៃ ដែលចាំបាច់សម្រាប់ការផ្ដល់សក្ខីកម្មរបស់សាក្សីនិងអ្នកជំនាញ ដែល

បានជម្រាបមកខាងលើនេះ ។ ថិរវេលានៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ នឹងយកមកពិភាក្សាបន្ថែមទៀតនៅថ្ងៃស្អែក ឬក៏នៅពេលក្រោយនៅក្នុងរបៀបវារៈពិសេសមួយ ។ អ៊ីចឹងគឺថា រយៈពេល៤០ថ្ងៃនោះឯង ខ្ញុំចង់បញ្ជាក់ថា សម្រាប់តែសាក្សីដែលខាងសហព្រះរាជអាជ្ញាបានលើកឡើងប៉ុណ្ណោះ ។ គឺមានបញ្ហាខ្លះដែលខាងអង្គជំនុំជម្រះចង់លើកឡើង ទាក់ទងជាមួយខាងសហព្រះរាជអាជ្ញា គឺថាមានភាពខុសគ្នាបន្តិចបន្តួចក្នុងការផ្តល់ឈ្មោះ ក្នុងការប្រកបឈ្មោះ ដែលសាក្សីដែលបានស្នើឡើងនោះ ។

អ៊ីចឹងខ្ញុំនឹងអានឡើងខ្លីៗ គឺឈ្មោះ KW០៣ ហើយនិង KW១១ និង KW១២, KW១៤, KW១៩, KW២២, KW២៨ និង KW៣០ ពីព្រោះភាពខុសគ្នាបន្តិចបន្តួចនេះឯង គឺកើតមានរវាងសាក្សីដែលបានលើកឡើងនិងបានពិនិត្យមើលឃើញ នៅពេលដែលសហចៅក្រមស៊ើបអង្កេត ដែលបានធ្វើនៅក្នុងដំណាក់កាលនៃការស៊ើបអង្កេត ហើយដែលបានបញ្ចូលនៅក្នុងសំណុំរឿងរួចហើយនោះ ។ អ៊ីចឹងមានន័យថា យើងត្រូវធ្វើការបញ្ជាក់ថា តើសាក្សីនោះជាសាក្សីដូចគ្នាដែលឬក៏យ៉ាងម៉េច? អ៊ីចឹងតើខាងសហព្រះរាជអាជ្ញាហ្នឹង អាចផ្តល់អំពីចំណុចនេះថា តើសាក្សីនេះជាសាក្សីតែមួយឬក៏យ៉ាងម៉េច? ឲ្យបានកាន់តែឆាប់ កាន់តែរហ័សជាការប្រសើរ ។ ហើយថាតើសាក្សីដែលខ្ញុំលើកឡើងហ្នឹង ត្រូវបានផ្តល់បទសម្ភាសន៍ហើយ នៅក្នុងដំណាក់កាលស៊ើបអង្កេតនោះឬក៏យ៉ាងម៉េច? តើខាងសហព្រះរាជអាជ្ញាអាចផ្តល់ឥឡូវនេះបានទេ?

**លោក រ៉ូប៊ីត ពើទីត៖**

សូមអរគុណ។ លោកចៅក្រម ខ្ញុំមែនទែនមិនទាន់អាចឆ្លើយដោយជាក់លាក់ទៅលើសំណួរនិងទេ ។ ពីព្រោះអីយើងកំពុងពិគ្រោះជាមួយនឹងសំណុំរឿងជាងមួយខែហើយ យើងឃើញវាមានការប្រកបឈ្មោះខុសអី នៅក្នុងឈ្មោះដដែលៗ ។ ខ្ញុំជឿថា មួយថ្ងៃពីរទៀតយើងអាចនឹងដាក់ឯកសារជូនទៅអង្គជំនុំជម្រះដើម្បីពិនិត្យជាពិសេសទាក់ទងជាមួយលេខ *អ៊ុអ័រអ៊ិនណាំប៊ី* ដែលត្រឹមត្រូវ ហើយនិងសេចក្តីថ្លែងដែលត្រឹមត្រូវទៅតាមលក្ខណៈបច្ចេកទេស ។ នៅក្នុងនេះគឺខ្ញុំជឿថា ប៉ុណ្ណឹងអាចនឹងជួយបានប្រសិនជាយើងរៀបចំសារថ្មីបញ្ជូនទៅ ហើយទាក់ទងជាមួយភស្តុតាងថ្មី ក្រែងលោចង់ឲ្យខ្ញុំបង្ហាញដាក់ជូន ឬពេលក្រោយយ៉ាងម៉េច ខ្ញុំនឹងរីករាយ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ខ្ញុំអរគុណ ដោយសារលោកដឹងរឿងនេះហើយ លោកអាចយោងទៅចំណុចហ្នឹងតែម្តងទៅ ។

00285895





**លោក រ៉ូបឺត ពេទីត៖**

សូមអរគុណ។ ខ្ញុំសូមស្នើទៅខាងអង្គជំនុំជម្រះថា យើងនឹងស្នើសុំឲ្យមានការបោះបង់ចោលនៅក្នុងការពន្យារពេលនៅក្នុងការដាក់សេចក្ដីតបទៅនឹងអង្គជំនុំជម្រះ ព្រោះនៅក្នុងនេះគឺយើងមានភស្តុតាង ហើយដែលយើងគិតថា មានសារសំខាន់ណាស់សម្រាប់អង្គជំនុំជម្រះក្នុងការដែលពិនិត្យមើល បញ្ចូលក្នុងសំណុំរឿងនេះ ។ អ៊ីចឹងដូចមានបានរាយការណ៍នៅក្នុងសារព័ត៌មានហើយ គឺខាង *ឌីស៊ីខេម* និងអង្គការដែលជាអង្គការក្នុងស្រុកមួយហ្នឹង គឺពីរថ្ងៃមុនហ្នឹង គឺមានវីដេអូដែលបានថត ដែលទាក់ទងជាមួយនឹងព្រឹត្តការណ៍ក្នុងសម័យនោះ ដែលបង្ហាញអំពី ស-២១ ទីតាំង ស-២១ គឺពី-- អ៊ីចឹងបើតាមខ្ញុំដឹង គឺវីដេអូនេះកាលពីមុនមិនដែលមានអ្នកណាបានឃើញទេ ដូច្នេះហើយ ទាក់ទងជាមួយនឹងសារ-សំខាន់សម្រាប់សាក្សី ក៏ដូចជាអង្គជំនុំជម្រះ និងភាគី គឺគេគួរតែមើលវីដេអូហ្នឹង ដើម្បីឲ្យដឹងព្រឹត្ត-ការណ៍ពិត ។ ហើយអ៊ីចឹងនេះគឺ កាលពីមុនមកខ្ញុំមិនដឹងអំពីថាមានវីដេអូបែបហ្នឹងទេ ហើយយើងទើបតែនឹងដឹងនៅចំណុចនេះតាមរយៈប្រព័ន្ធផ្សព្វផ្សាយប៉ុណ្ណោះ ។ ហើយខ្ញុំសូមស្នើឲ្យមានការថតចម្លងវីដេអូនោះ ហើយយើងបានមើលហើយៗ គឺមើលទៅវាមិនយូរទេ ប្រហែល២០នាទីទេ ថិរវេលានៃវីដេអូនេះ ។ អ៊ីចឹងខ្ញុំគិតថាយើង-- វាពាក់ព័ន្ធជាមួយហ្នឹងទីតាំងរបស់មន្ទីរស-២១ អ៊ីចឹងបានថា ខ្ញុំក្នុងសប្ដាហ៍នេះនឹងដាក់សំណើរទៅខាងអង្គជំនុំជម្រះ ទោះជាយើងគិតថា កាលវិភាគដាក់ហ្នឹងវាហួសហើយក៏ដោយ គឺចង់ដាក់នូវឯកសារភស្តុតាងថ្មីនេះ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោក ពេទីត ដែលលោកលើកមិញមានពីរចំណុច ។ ពីរចំណុចនេះ គឺធ្វើឲ្យខ្ញុំមានការរំឭកទៅលើបញ្ហាប្រកបឈ្មោះដែរ អង្គជំនុំជម្រះក៏ចង់ជម្រាបទាក់ទងជាមួយនឹងការដែលឈ្មោះសាក្សីប្រកបខុសគ្នាហ្នឹង ខ្ញុំគិតថាជាការល្អ ។ សុំឲ្យធ្វើការប្រកបឈ្មោះហ្នឹង គឺបានន័យថា សូមឲ្យមើលទៅតាមឈ្មោះនៃភាគីដែលដាក់មក ដែលឈ្មោះសាក្សីនៅក្នុងបញ្ជីដែលបានដាក់មកហ្នឹងឲ្យស៊ីគ្នា។ ព្រោះអីឈ្មោះសាក្សីដែលដាក់ស្នើមកជាមួយនិងសាក្សីជំនាញ ជាពិសេស KW២ ដូចជា KW០៥, KW២៥, KW២៦, KW៣៣ និង KW៣៤ និង KW៣៥ ។ ទាំងនេះគឺពុំមានថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើតនិងអាសយដ្ឋានពិតប្រាកដទេ សូមពិនិត្យឡើងវិញផង ។ ហើយអ៊ីចឹងក្នុងករណីនេះ គឺឯកសារទាំងអស់នេះទាំងទងជាមួយគាត់ដាច់ខាតត្រូវតែមាន។ អ៊ីចឹងទេ បានអង្គជំនុំជម្រះសូមស្នើសហព្រះរាជអាជ្ញាមេត្តាពិនិត្យព័ត៌មាននោះឡើងវិញក្នុងបញ្ជីរបស់ខ្លួន ហើយបើអាចធ្វើបានហ្នឹង សូមជួយរៀបចំវា

បញ្ចូលគ្នាជាមួយ នឹងបញ្ជីដែលបានស្នើឡើងនោះឲ្យរួចស្រេចតែម្តង ។

សូមអរគុណហើយ នៅក្នុងផ្នែកនៃរបៀបវារៈនេះ គឺបើតាមសហព្រះរាជអាជ្ញានេះ គឺមេធាវីការពារជនជាប់ចោទហ្នឹង មានឱកាសបានតទល់មុខគ្នាជាមួយនឹងសាក្សីដែលបានស្នើនោះចំនួនដល់ទៅ ១១រូប ជាពិសេសកាលក្នុងអំឡុងពេលនៃដំណាក់កាលស៊ើបអង្កេតរួចមកហើយហ្នឹង ។ តើមេធាវីការពារ ជនជាប់ចោទអាចបញ្ជាក់ព័ត៌មាននេះ បានដែរឬទេ? សូមអញ្ជើញ!

នេះគឺជាឱកាសដែលលោកក៏ត្រូវបញ្ជាក់ សួរថាតើលោកបានតទល់ជាមួយសាក្សីទាំង១១រូប នៅក្នុងដំណាក់កាលនោះដែរទេ? សូមលោកជួយបញ្ជាក់ផង ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

អរគុណលោកស្រីចៅក្រមប្រធាន នេះគឺជាព័ត៌មានត្រឹមត្រូវហើយនៅក្នុងដំណាក់កាលសហចៅក្រមស៊ើបហ្នឹង គឺដោយសារការយល់ស្របពីភាគី គឺមានការតទល់ជាពិសេស ជាមួយការចុះទៅពិនិត្យមើលកន្លែងកើតហេតុនោះឡើងវិញ ហើយនៅក្នុងនោះសហចៅក្រមស៊ើបក៏បានរៀបចំឲ្យមានការតទល់មុខគ្នាជាមួយនឹងសាក្សីមួយចំនួន ខ្ញុំមិនមានចំនួនបញ្ជីសាក្សីទាំងអស់នោះទេ គ្រាន់តែខ្ញុំអាចបញ្ជាក់ថា គឺយើងពិតជាមានការតទល់មុខគ្នាអ៊ីចឹងមែន ។ ហើយនេះគឺជាការដែលធ្វើឡើង ដែលមានការយល់ស្របពីភាគីដែលពាក់ព័ន្ធផងដែរ ហើយយើងក៏មានស៊ីគ្នាជាមួយនឹងនីតិវិធី ដែលសហចៅក្រមស៊ើបធ្វើ ហើយវាស៊ីគ្នាជាមួយប្រព័ន្ធច្បាប់ស៊ីវិលដែរ ។ សូមអរគុណ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៍៖**

ឥឡូវនេះ តើមេធាវីជនជាប់ចោទ យើងអាចបញ្ជាក់បន្ថែមទៀតជាពិសេសទាក់ទងជាមួយនឹងភាពមិនស៊ីគ្នានៃបញ្ជី ឬក៏សាក្សីដែលលោកបានពិនិត្យហ្នឹង?

**លោក ហ្វ្រង់ស្វ័រ រូ៖**

យើងនឹងធ្វើតាមការស្នើរបស់អង្គជំនុំជម្រះ ។ សូមអរគុណ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៍៖**

ខ្ញុំចង់សួរបន្តទៅទៀតទៅលើដើមបណ្តឹងរដ្ឋប្បវេណីផងដែរ ជាពិសេសទាក់ទងជាមួយនឹងសេចក្តីសង្ខេបអង្គហេតុ ដែលខ្លួនគិតថា សាក្សីដែលខ្លួននឹងយកមកធ្វើសក្ខីកម្មហ្នឹង គឺយើងនឹងមានអ្វី-- មានយោបល់ទេ? ជាពិសេសខ្ញុំសួរទៅលោក ហ្វ្រង់ស្វ័រ រូ សិន ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកស្រីចៅក្រម ។ នៅក្នុងខាងមេធាវីការពារក្តី គឺមិនបានទទួលបញ្ជីដែលបកប្រែជាភាសាបារាំង យើងទើបតែទទួលបានបីថ្ងៃមុននឹងប៉ុណ្ណោះ ។ អ៊ីចឹងក្នុងន័យនេះ គឺយើងមិនទាន់បានពិនិត្យមើលបញ្ជីហ្នឹងកើតទេ ។ ហើយអ៊ីចឹងបានជាយើងមិនទាន់បានដាក់បញ្ជីរបស់យើងដោយផ្ទាល់នៅឡើយដែរ ។

ប៉ុន្តែ ខ្ញុំគិតថាចំណុចដែលខ្ញុំគួរតបទៅវិញ ទីមួយគឺ យើងមានគម្រោងនឹងមាន-- គម្រោងដែលសហព្រះរាជអាជ្ញាស្នើសុំឲ្យមាន៤០ថ្ងៃ សម្រាប់ស្តាប់ចម្លើយសាក្សីហ្នឹងវាច្រើនពេកទៅហើយ ជាពិសេសដោយសារសាក្សីជាច្រើននៅក្នុងចំណោមសាក្សីទាំងនេះហ្នឹង គឺត្រូវបានគេធ្វើសវនាការរួចទៅហើយនៅក្នុងដំណាក់កាលស៊ើបអង្កេត ។ ហើយដោយសារយើងទាំងអស់ យើងមិនមែនអនុវត្តតាមប្រព័ន្ធរឿងកាលដែលត្រូវធ្វើការសួរ ឬក៏សួរដេញដោលនេះ គឺអ៊ីចឹងបានខ្ញុំគិតថា ថ្ងៃដែលដាក់មកនេះគឺច្រើនពេក ។ អ៊ីចឹងទេ ខ្ញុំសូមមានប្រតិកម្មតបទៅហ្នឹងចំណុចមួយ ដែលលោកសហព្រះរាជអាជ្ញាចង់ដាក់ភស្តុតាងបន្ថែមទៀត ដែលបានមកពីអង្គការក្រៅរដ្ឋាភិបាល ហើយខ្ញុំសូមប្រើពាក្យថា អង្គការក្រៅរដ្ឋភិបាលមួយនេះត្រូវបានចោទប្រកាន់ថា បានទទួលព័ត៌មាននេះ ដែលធ្វើឲ្យខាងមេធាវីការពារក្តីហាក់បីដូចជាមានការភ្ញាក់ផ្អើលបន្តិច ។ ព្រោះអង្គការមួយនេះ គឺកាលពីពីរខែមុននឹងគេបាននិយាយហើយថាខ្លួនឯងហ្នឹងមានព័ត៌មានបន្ថែមដែលជាក់លាក់ ។ បន្ថែមទៀត សូម្បីតែគាត់និយាយពីថា គាត់មានចំនួនសាក្សីដែលធ្លាប់ជាអ្នកទោសនៅ គុកទួលស្លែង គឺ ស-២១ គឺមានដល់១៧៧នាក់ ។ អ៊ីចឹងក្នុងកាលដែលគេផ្តល់ឯកសារ ឬក៏ត្រូវបញ្ចូលឯកសារ ដែលសហព្រះរាជអាជ្ញាស្នើនេះ គឺបានន័យថាខ្ញុំដឹងហើយថាមន្ត្រីដែលធ្វើការនៅនេះហ្នឹង គឺធ្លាប់ធ្វើការជាមួយនឹង អ៊ិនជីអូ ឬមួយក៏អង្គការក្រៅរដ្ឋភិបាលនេះរាប់ឆ្នាំរួចទៅហើយ ។ អ៊ីចឹងទាក់ទងជាមួយនឹងចំណុចនេះ ខ្ញុំគិតថានៅពេលដែលសហព្រះរាជអាជ្ញា យើងខាងមេធាវីការពារក្តីបានទទួលព័ត៌មានកៀកនៅក្នុងពេលដែលជិតសវនាការ ។ ក៏ប៉ុន្តែខាងសហព្រះរាជអាជ្ញាវិញគាត់បានដឹងព័ត៌មាននេះ ព្រោះគាត់មានមន្ត្រីដែលមានធ្លាប់ធ្វើការនៅខាងស្ថាប័នអង្គការក្រៅរដ្ឋាភិបាលនោះ ហើយអ៊ីចឹងទេ គាត់មានលទ្ធភាពហ្នឹងដាក់ភស្តុតាងនោះបានយូរហើយ ។ អ៊ីចឹងបានខ្ញុំថាហេតុអីក៏ឯកសារនេះមិនបានឲ្យខាងមេធាវីការពារក្តី បានឃើញពីមុនមក ។ ហើយចំណុចនេះគឺជាជំហររបស់យើងខ្ញុំ គ្រាន់តែខ្ញុំចង់ជម្រាបថា នៅពេលនេះគឺអ្វីដែលខ្ញុំបារម្ភ ហើយគឺជាអ្វីដែលខ្ញុំជំទាស់ជាមួយសំណើរសូមដាក់ភស្តុតាងថ្មីនេះ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៍៖**

ខ្ញុំគិតថាលោក ពើទីត ប្រហែលជាអាចនឹងឆ្លើយតបទៅនឹងប្រសាសន៍របស់លោក ហ្វ្រង់ស្វ័រ រូ បាន ។

តើលោកអាចបង្ហាញថា តើលោកហ្នឹងផ្តល់នូវភស្តុតាង ឬព័ត៌មានបន្ថែមទៀត ដែលថាលោក នឹងចង់បញ្ចូលទៅក្នុងសំណុំរឿងនេះផ្តល់ទៅខាងក្រុមមេធាវីការពារក្តីបានទេ?

**លោក រ៉ូបឺត ពើទីត៖**

ដូចដែលខ្ញុំបាននិយាយអ៊ីចឹងពិតជាបាន គឺយើងនឹងដាក់ពាក្យមកនៅក្នុងអង្គសាលាជំនុំជម្រះក្តី អំពីចំណុចនេះឯងទាក់ទងទៅនឹងភស្តុតាងបន្ថែម ហើយការិយាល័យសហព្រះរាជអាជ្ញាដែលមានភស្តុតាង ថ្មីនេះ ។ បើខ្ញុំអាចនិយាយបន្ថែមទៀត ដែលថាមេធាវីការពារក្តីបានលើកឡើង ដើម្បីបង្ហាញបញ្ជាក់បាន ច្បាស់អំពីចំណុចនេះ ។

បើនិយាយអំពីចំនួនថ្ងៃខែដែលខ្ញុំបានគិតថា រំពឹងថានឹងត្រូវការ ដូចដែលយើងបានដឹងអ៊ីចឹងនេះ គឺជាចំនួនដែលយើងគ្រាន់តែព្យាករណ៍តែប៉ុណ្ណោះ យើងមិនអាចគិតថាជាចំនួនពិតប្រាកដបានទេ នេះ គ្រាន់តែជាការប៉ាន់ស្មានតែប៉ុណ្ណោះ ដែលយើងបានស្នើឡើង ។ អ៊ីចឹងបានន័យថា យើងអាចរៀបចំផែន ការបានខ្លះទៅតាមចំនួននេះ មិនមែនជាអ្វីចំនួនជាក់លាក់នោះទេ ។ អ៊ីចឹងគឺថា យើងជាអ្នកកំណត់ ក៏ប៉ុន្តែ អាស្រ័យទៅលើបទពិសោធន៍របស់យើងដែលយើងមានពីមុនមកនោះ ។ អ៊ីចឹងគឺយើងធ្វើការ វាយតម្លៃថា នេះគឺជាចំនួនអប្បបរិមានៃថ្ងៃខែ ដែលសាក្សីទាំងនេះត្រូវការជាមួយនិងតុលាការអស់ហ្នឹង អ៊ីចឹងវាអាច វាមានគំនិតអ្វីផ្សេងទៀតនោះ យើងមិនដឹងថា តើខាងសាធារណជនគាត់អាចយល់ដឹងពី ថ្ងៃខែ ដែលយើងលើកឡើងនេះទេ?

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៍៖**

សូមអរគុណលោក ពើទីត ។ តើខាងមេធាវីរដ្ឋប្បវេណីមានមតិយោបល់ទេ ទាក់ទងទៅនឹង សេចក្តីសង្ខេបអង្គហេតុ ដែលខាងសហព្រះរាជអាជ្ញាបានដាក់បញ្ចូលនោះ ។

សូមអគុណ ។ អ៊ីចឹងជាចំណុចចុងក្រោយទាក់ទងបញ្ហានេះ ខាងសហព្រះរាជអាជ្ញាបានស្នើ អំពីនីតិវិធីទាក់ទងទៅនឹងការធ្វើសក្ខីកម្មរបស់សាក្សី ជាពិសេសថា តើសាក្សីនឹងផ្តល់សក្ខីកម្មជាលើក ដំបូង ហើយហ្នឹងត្រូវស្តាប់ចម្លើយនៅពេលក្រោយ ដោយអង្គជំនុំជម្រះសាលាដំបូងនិងដោយភាគី ដែល ជាសង្ខេបអង្គជំនុំជម្រះសូមបញ្ជាក់ថា បានមានការឯកភាពចំពោះចំណុចនេះ ហើយចង់និយាយអំពីបទ

បញ្ញត្តិជាក់លាក់មួយទាក់ទងទៅនឹង ចំណុចនេះគឺទាក់ទៅនឹងវិធាន៨១ ។

តើមានបញ្ហាអ្វីផ្សេងទៀត ដែលខាងក្រុមមេធាវីការពារក្តី ឬក៏មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ឬក៏ខាងសហព្រះរាជអាជ្ញាចង់លើកឡើងនៅពេលនេះ នៅក្នុងអង្គវារៈថ្ងៃនេះមុននឹងយើងបន្តទៀត ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណ លោកស្រីចៅក្រម ។ ខាងក្រុមការពារក្តីចង់ធ្វើការផ្តល់ព័ត៌មានដល់ខាងអង្គជំនុំជម្រះថា ខាងការិយាល័យសហព្រះរាជអាជ្ញា ដើម្បីធ្វើការស្នើនៅក្នុងនីតិវិធី ដែលសាក្សីមួយហ្នឹងគឺគាត់មានអាយុចាស់ជរាណាស់ទៅហើយ អ៊ីចឹងគួរណាស់តែយើងមិនមានការរើសអើងទៅលើចំណុចមួយនេះទេ យើងបានឯកភាពជាមួយខាងសហព្រះរាជអាជ្ញាថា នៅក្នុងការសួរ ហើយនិងការសួរតបទៅលើសាក្សីនោះ ដែលសាក្សីហ្នឹងអាចនឹងត្រូវធ្វើបានឡើង ដោយធ្វើការថតរូប ហើយពេលនោះឯងការថតនេះឯងអាចហ្នឹងបង្ហាញនៅក្នុងអង្គជំនុំជម្រះបាន ពីព្រោះគាត់មិនមែនជាសាក្សីជំនាញទេ ប៉ុន្តែជាសាក្សីដែលមានវ័យជរា ហើយរស់នៅឆ្ងាយពីតុលាការ ហើយគាត់ជាសាក្សីសំខាន់នៅខាងផ្នែកការពារក្តី ហើយយើងមានការបារម្ភចំពោះស្ថានភាពសុខភាពរបស់គាត់ ។ ដូច្នេះហើយ នេះជាការការពារជាមុន គឺថាយើងចង់ធ្វើការស្នើថា នៅក្នុងពេលដែលនឹងកើតមាននាពេលខាងមុខនេះ យើងចង់ឱ្យសាក្សីហ្នឹងឯងត្រូវបានសួរចម្លើយដោយមានថតជាវីដេអូ ទាំងសួរចម្លើយ ទាំងសួរចម្លើយតប ហើយការថតវីដេអូនឹងត្រូវយកមកបង្ហាញ បន្ទាប់ពីបានសួរឆ្លងរួចហើយហ្នឹងឯង និងបានបង្ហាញនូវក្នុងសាលសវនាការ ។ គឺថាយើងរង់ចាំសួរមតិយោបល់ពីខាងផ្នែកសហព្រះរាជអាជ្ញាផងដែរ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

តើលោក រូ មានបានទទួលកិច្ចព្រមព្រៀងពីខាងសហព្រះរាជ្ញាទេ ទាក់ទងទៅនឹងបញ្ហាជាបឋមនេះ?

លោក ពើទីត តើលោកបានឯកភាពព្រមព្រៀងទៅនឹងនីតិវិធីនេះទេ?

**លោក រ៉ូប៊ឺត ពើទីត៖**

ទាក់ទងទៅនឹងវិធី? បាទមាន ក៏ប៉ុន្តែទាក់ទងទៅនឹងទីកន្លែង ទីតាំងនោះគឺថាមិនទាន់មាននៅឡើយទេ ។ ជាបឋមគឺថា អាស្រ័យទៅនឹងសេចក្តីសម្រេច ហើយនិងទៅលើសក្ខីកម្មនោះឯង ឬក៏ទៅលើសមត្ថភាពរបស់យើងក្នុងការផ្តល់មតិយោបល់ទៅលើចំណុចនេះទាក់ទងទៅនឹងសក្ខីជាក់លាក់នេះដែលជាសាក្សីរបស់ខាងមេធាវីការពារក្តីនោះ ។ ជាការពិតណាស់ ជាការពិតមួយដែលថាខាងមេធាវីការពារ

ក្តីបានមកទាក់ទងយើង ហើយនិងផ្តល់ព័ត៌មានមកប្រាប់យើងថា ចង់ឲ្យធ្វើការសម្ភាសន៍សាក្សីនោះដោយចតជាវីដេអូ គាត់ជាបុរសចាស់ម្នាក់ ។ ហើយព័ត៌មានដែលយើងមានចុងក្រោយគឺបង្ហាញថាមានបញ្ហាបារម្ភទាក់ទងទៅនឹងសុខភាពរបស់គាត់ មិនដឹងជាគាត់អាចរស់បានរយៈពេលប៉ុន្មាននោះ ។ បើអ៊ីចឹងទាក់ទងទៅនឹងសេចក្តីសម្រេចរបស់លោកស្រីចៅក្រមផងដែរ ហើយទាក់ទងទៅនឹងនីតិវិធីនោះគឺថាតុលាការនេះ ហើយនិងទាក់ទងទៅនឹងកម្រិតថវិកាដែលយើងមាន យើងគ្រាន់តែសង្ឃឹមថាលោកអាចផ្តល់ការណែនាំទាក់ទងទៅនឹងបញ្ហានេះ ហើយយើងអាចធ្វើការអនុវត្តតាមការណែនាំរបស់ខាងលោកស្រីចៅក្រមផងដែរ ។ សូមអរគុណ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៌៖**

តើលោកចៅក្រម ឡាវែនស៍ យល់យ៉ាងម៉េចដែរ?

**ចៅក្រម ឡាវ៉ែនស៍៖**

ប្រសិនជាខ្ញុំបានយល់ពីសំណើរបស់លោកបានត្រឹមត្រូវនោះ គឺថាលោកមិនចង់ឲ្យធ្វើការផ្តល់សក្ខីកម្មផ្ទាល់ខ្លួនពិតប្រាកដរបស់សាក្សីនោះទេ ។ មានន័យថា គឺមិនធ្វើតាមវិធានផ្ទៃក្នុងនោះ ប៉ុន្តែនេះគឺជាឯកសារមួយ ទាក់ទងទៅនឹងការពិនិត្យនោះ ថាតើចៅក្រមអាចធ្វើការពិនិត្យបានដែរឬទេ? ទាក់ទងទៅនឹងសាក្សីនោះ ឬក៏ថាតើដើមបណ្តឹងរដ្ឋប្បវេណីមានបានពិចារណាទៅលើចំណុចនេះដែរឬទេ? ឬក៏បានពិចារណាថាតើយើងគួរធ្វើយ៉ាងម៉េចទាក់ទងនឹងនីតិវិធីជាក់លាក់នៅក្នុងរឿងនេះ?

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៌៖**

លោកមេធាវី ហ្វ្រង់ស្វ័រ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

តាំងពីដំបូងមកម្ល៉េះយើងបាន គិតថានឹងធ្វើឲ្យសាក្សីហ្នឹងឯងផ្តល់សក្ខីកម្មពីប្រយោល ពីចម្ងាយក៏ប៉ុន្តែ ដោយហេតុថានៅក្នុងកាលៈទេសៈបញ្ហាសុខភាពធ្ងន់របស់គាត់ និងការពន្យារពេលដែលបានកើតមានឡើងទាក់ទងទៅនឹងគ្រាដំបូងនៃដំណើរការនីតិវិធី ហើយក្នុងចំណោមបញ្ហាដទៃទៀតនោះឯង ទាក់ទងទៅនឹងការធ្វើបណ្តឹងប្រឆាំងរបស់ខាងសហព្រះរាជអាជ្ញាទុំងឯង យើងចង់ធ្វើនូវការធានាថា ពាក្យសម្តីនិងសក្ខីកម្មរបស់គាត់ហ្នឹងឯងនឹងត្រូវបានឮដោយតុលាការនោះ ព្រោះសក្ខីកម្មរបស់គាត់ជាភ័ស្តុតាងមួយសំខាន់ណាស់ អ៊ីចឹងហើយបានយើងស្នើឲ្យធ្វើទៅតាមនីតិវិធីបែបនេះ ។ ក៏ប៉ុន្តែ នេះបើយើងបើកចំហសម្រាប់ឲ្យមាននីតិវិធីផ្សេងទៀតបើសិនជាយើងអាចធ្វើបាន ពីព្រោះនៅក្នុងការគិតរបស់យើង

សាក្សីនេះគឺជាសាក្សីមួយសំខាន់បំផុត ហើយគាត់គួរតែមានឱកាសដើម្បីផ្តល់សក្ខីកម្មនៅក្នុងសវនាការនេះឯង ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

បើអ៊ីចឹងប្រហែលជានឹងអាចជាប្រយោជន៍ណាស់ ប្រសិនបើលោក ហ្វ្រង់ស្វ័រ រូ អាចផ្តល់ព័ត៌មានសង្ខេបខ្លះដល់ក្នុងអង្គជំនុំជម្រះសាលាដំបូងនេះទាក់ទងទៅនឹងសាក្សីមួយនេះ ហើយអ៊ីចឹងទៅយើងអាចសេចក្តីសម្រេចបានទាន់ពេលវេលា ។ ហើយនៅក្នុងដំណាក់កាលនេះពួកយើងមិនអាចធ្វើការចង្អុលបង្ហាញថាតើយើងនឹងអាចធ្វើការសម្រេចបែបណានោះទេ?

តើមានបញ្ហាផ្សេងទេដែលត្រូវចង់លើកឡើងទេ ខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងទៅនឹងចំណុចនេះនៅក្នុងរបៀបវារៈអង្គប្រជុំយើងថ្ងៃនេះ?

អ្នកស្រី ស៊ីលឃី ស្ទួនហ្សីនស្គី ?

**លោកស្រី ស៊ីលឃី ស្ទួនហ្សីនស្គី៖**

ទាក់ទងទៅនឹងបញ្ហាចុងក្រោយដែលបានលើកឡើងដោយខាងមេធាវីការពារក្តី ខ្ញុំចង់និយាយ ថាដោយមិនបានដឹងពីប្រភេទសាក្សីបែបណានោះ ខ្ញុំចង់ធ្វើការផ្តល់នូវការធានាថា ខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីថាអាចស្នើក្នុងការរៀបចំសាក្សីនេះ ថាតើយើងអាចមានឱកាសដើម្បីសួរសាក្សីនេះបានឬទេ? សូមអរគុណ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

បើសិនជាមិនមានសំណួរបន្ថែមទៀតទេ នេះគឺជាការបញ្ចប់នូវចំណុចនៅក្នុងរបៀបវារៈរបស់យើង ថ្ងៃនេះ អ៊ីចឹងសូមលោកប្រធាន!

**ប្រធានអង្គជំនុំ៖**

ខ្ញុំសូមអរគុណ លោកស្រីចៅក្រម ដែលបានសម្របសម្រួលនិងធ្វើបទបង្ហាញនៅក្នុងរបៀបវារៈទីពីរដែលមានបីចំណុចសំខាន់នេះ ហើយបទបង្ហាញនឹងការសម្របសម្រួលរបស់លោកស្រីគឺមានភាពរលូន ហើយបានចប់សព្វគ្រប់ហើយៗ ឥឡូវក៏ដល់ពេលម៉ោងកំណត់សម្រាកហើយដែរ អ៊ីចឹងគឺអង្គជំនុំជម្រះសាលាដំបូងសូមប្រកាសសម្រាកដើម្បីអស់លោក លោកស្រីដែលជាសមាជិកសមាជិកានៃអង្គប្រជុំ និងអ្នកដែលចូលរួមនៅក្នុងកិច្ចប្រជុំនេះ សូមពិសាអាហារថ្ងៃត្រង់ ហើយកិច្ចប្រជុំនេះនឹងបន្តទៅទៀតនៅវេលាម៉ោងមួយនិងសាមសិបនាទីរសៀលនេះ ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងសូមអញ្ជើញ

លោក លោកស្រីចូលរួមនៅក្នុងកិច្ចប្រជុំឲ្យមុនម៉ោងដប់មួយនិងសាមសិបនាទីរសៀលនេះ *(ស៊ីក)* ដើម្បី-- ម៉ោងមួយនិងសាមសិបនាទីរសៀល ហើយអនុរក្សពន្ធនាគារ សូមនាំខ្លួនលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច ត្រឡប់ទៅកាន់បន្ទប់រង់ចាំ នៅក្រោមសាលសវនាការនេះ ហើយនឹងបង្គាប់លោកឲ្យនាំគាត់មកកាន់បន្ទប់ជម្រះនេះវិញនៅមុនម៉ោងដប់មួយនិងសាមសិបនាទីរសៀលនេះ *(ស៊ីក)* ។ នេះក្នុងករណីដែលគាត់មានបំណងចូលរួមនៅក្នុងកិច្ចប្រជុំនេះ ប្រសិនបើគាត់មិនចង់ចូលរួមក្នុងកិច្ចប្រជុំទេ គឺអាចអនុរក្សពន្ធនាគារមិនចាំបាច់នាំគាត់មកទេ គឺអាចនាំគាត់ទៅ កាន់បន្ទប់មន្ទីរឃុំឃាំងវិញបាន ។ សូមអរគុណ ។ សូមសម្រាក ។

*(កិច្ចប្រជុំសម្រាកពីម៉ោង ១១:៥៤នាទី ដល់ម៉ោង ១.៣៣នាទី)*

**ប្រធានអង្គជំនុំ៖**

សុំអនុញ្ញាតអស់លោក លោកស្រីអង្គុយចុះ ។

សូមជម្រាបសួរលោក លោកស្រី អ្នកនាងកញ្ញា! ឥឡូវនេះ យើងចាប់ផ្តើមបន្តដំណើរការកិច្ចប្រជុំរបស់យើងតាមរបៀបវារៈ ដែលបានគ្រោងទុក ។

នៅត្រង់របៀបវារៈទី៣ ស្តីពីវិធានភស្តុតាងនិងកិច្ចការពាក់ព័ន្ធទៅនឹងផ្នែកគ្រប់គ្រងតុលាការ នៅក្នុងរបៀបវារៈនេះ យើងចែកចេញជារបៀបវារៈតូចៗមានចំនួន៥៖

របៀបវារៈ៣(ក) នីតិវិធីសម្រាប់ការដាក់ភស្តុតាង អនុលោមតាមវិធាន៨៧.២ ។

៣(ខ) គោលការណ៍ណែនាំអំពីអង្គជំនុំជម្រះសាលាដំបូង ស្តីពីការជូនដំណឹងឲ្យបានត្រឹមត្រូវ និងទាន់ពេលវេលានៃភស្តុតាងដែលភាគីមានបំណងសុំឲ្យពិនិត្យ ដែលជារបៀបវារៈបន្ថែមដែលស្នើឡើងដោយសហព្រះរាជអាជ្ញា ។

៣(គ) តើត្រូវដោះស្រាយជាមួយសាក្សីបន្ថែមយ៉ាងដូម្តេច? បើសាក្សីនោះមិនមាននៅក្នុងសំណុំរឿង ប៉ុន្តែនឹងមិនមាននៅក្នុងដីកាដំណោះស្រាយ ហើយសាក្សីបន្ថែមនោះអាចផ្តល់កសិណសាក្សីចំពោះការចោទប្រកាន់បន្ថែមថ្មី។ របៀបវារៈនេះគឺ ស្នើឡើងដោយមេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

៣(ឃ) តើអង្គជំនុំជម្រះសាលាដំបូង មានបំណងកំណត់នូវកាលបរិច្ឆេទ សម្រាប់ការដាក់នូវបញ្ជីឈ្មោះសាក្សីនិងភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីថ្មីដែរឬទេ? ប្រសិនបើកំណត់ តើកំណត់នៅថ្ងៃណា? ។ នេះក៏ជារបៀបវារៈដែលស្នើឡើងដោយមេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែរ ។

៣(ង) ការកំណត់នូវការកំណត់កាលបរិច្ឆេទសវនាការ សម្រាប់ភាគីដើមបណ្តឹងរដ្ឋប្បវេណី

បានជ្រើសរើសដូចគ្នា គឺស្នើសុំឡើងមេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។

ចំពោះរបៀបវារៈនេះ ខ្ញុំសូមប្រគល់ភារកិច្ច ជូនទៅលោកចៅក្រម ហ្សង់ ម៉ាកឡាវែន៍ ជាចៅក្រមអន្តរជាតិនៅសាលាដំបូង ដើម្បីធ្វើការសម្របសម្រួលនិងធ្វើបទបង្ហាញជំនួសខ្ញុំ ជាប្រធានអង្គជំនុំជម្រះ ។ សូមអញ្ជើញ លោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ ម៉ាកឡាវែន៍៖**

សូមអរគុណលោកចៅក្រមប្រធាន។ ដោយសារប្រធានបទទីមួយនេះគឺទាក់ទងជាមួយនឹងនីតិវិធីក្នុងការដាក់ភស្តុតាងអនុលោមតាមទៅតាមវិធាន៨៧.២ នៃវិធានផ្ទៃក្នុងរបស់យើង។ នៅក្នុងវិធាន ៨៧.២ ចែងដូចខាងក្រោម៖

“សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវផ្អែកលើភស្តុតាងដែលបានដាក់ចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយភស្តុតាងនោះត្រូវឆ្លងកាត់ការដេញដោល ។ នៅពេលអង្គជំនុំជម្រះសាលាដំបូងធ្វើសេចក្តីសម្រេចផ្អែកលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង អង្គជំនុំជម្រះសាលាដំបូងត្រូវធានាថា ភស្តុតាងនោះពិតជាបានលើកឡើងនៅចំពោះមុខភាគីនានាអំឡុងពេលសវនាការ ។

ភស្តុតាងដែលមាននៅក្នុងសំណុំរឿងត្រូវបានចាត់ទុកថាបានលើកឡើងចំពោះអង្គជំនុំជម្រះដំបូង បើសិនជាខ្លឹមសាររបស់វាត្រូវបានសង្ខេប ឬត្រូវបានអាននៅក្នុងសវនាការ។ ហើយអង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឲ្យពិនិត្យភស្តុតាង បើយល់ឃើញថា វាមិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា (ខ)មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ (គ)មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុ ដែលជាគោលដៅនៃការសុំពិនិត្យភស្តុតាង ឬ(ឃ)ច្បាប់មិនអនុញ្ញាត ។

ហើយអង្គជំនុំជម្រះហ្នឹង សុំរំឭកថាខ្លួនបានរៀបចំកិច្ចប្រជុំក្រៅមួយ ជាមួយភាគីកាលពីថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០០៨ ហើយនៅក្នុងកិច្ចប្រជុំនោះ មានការស្វាសស្វែងរកគោលការណ៍ណែនាំស្តីពីការអនុវត្តបញ្ញត្តិនៃវិធាន៨៧.២ ជាពិសេស ពាក់ព័ន្ធនឹងអ្នកដែលមានតួនាទីរៀបចំធ្វើសេចក្តីសង្ខេប ឬក៏អានភស្តុតាងនោះ ។

នៅក្នុងខណៈនោះដែរ គឺអង្គជំនុំជម្រះបានបញ្ជាក់ថា ដោយខ្លួនទទួលខុសត្រូវចំពោះការដឹកនាំកិច្ចការដំណើរការនីតិវិធី ខ្លួននឹងមានតួនាទីសំខាន់ក្នុងការនាំមកបង្ហាញជូននូវភស្តុតាងក្នុងអំឡុងពេលសវនាការ ។ ប៉ុន្តែ បើសិនបើភាគីណាមួយ ឬក៏ច្រើន ចង់យោងទៅរកភស្តុតាងណាមួយ ដែលអង្គជំនុំជម្រះសាលាដំបូងមិនទាន់បាននាំយកមក បង្ហាញជូននៅឡើយ ភស្តុតាងនោះអាចត្រូវបានសង្ខេបឬអាន

ដោយភាគីមួយ ឬច្រើន ។

នៅពេលនាំមកបង្ហាញនូវភស្តុតាងណាមួយ អនុលោមទៅតាមវិធាន៨៧.២ អង្គជំនុំជម្រះនឹងប្រកាសអំពីបំណងដែលខ្លួនចង់ធ្វើដូច្នេះ ។ ចំណុចយោងបឋមរបស់ឯកសារ ដែលជាចំណុចយោងនៃភស្តុតាងនៅក្នុងសំណុំរឿងរបស់ការិយាល័យចៅក្រមស៊ើបអង្កេត ។ ឧទាហរណ៍ *D5* នឹងត្រូវបានលើកយកមកបង្ហាញ ដើម្បីជាការសម្គាល់ ។ ហើយបន្ទាប់មកអង្គជំនុំជម្រះនឹងសង្ខេបឯកសារនោះ ឬក៏អានឯកសារនោះតែម្តង ចេញពីភាសាការងារណាមួយដែលមានស្រាប់ ឬចេញពីសម្រង់នៃឯកសារនោះ ។ ហើយការធ្វើដូច្នេះ គឺអាចធ្វើឡើងដោយប្រធានឬក៏ចៅក្រមរូបឬក្រឡាបញ្ជី ដែលត្រូវបានអនុញ្ញាតដោយប្រធានឲ្យធ្វើដូច្នេះបាន ។

បន្ទាប់ពីអង្គជំនុំជម្រះបាននាំមកបង្ហាញជូននូវភស្តុតាងដែលខ្លួនគិតថាគប្បីដាក់នៅចំពោះមុខភាគី ដើម្បីឲ្យស្របទៅតាមវិធាន៨៧.២ ខ្លួននឹងផ្តល់ឱកាសទៅភាគីឲ្យបានធ្វើដូច្នេះផងដែរ ។

ភាគីណាមួយ ឬច្រើនដែលមានបំណងនាំយកមកបង្ហាញនូវភស្តុតាង ដើម្បីបម្រើគោលបំណងនៃវិធាននេះ គប្បីប្រកាសប្រាប់អង្គជំនុំជម្រះឲ្យបានដឹងអំពីគោបំណងរបស់ខ្លួនដែលចង់ធ្វើដូច្នេះ ហើយនឹងគប្បីអនុវត្តតាមនីតិវិធីដូចគ្នា ទៅនឹងនីតិវិធីនៃការដាក់ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ ។

ភាគីនោះនឹងត្រូវសម្របសម្រួលជាមុនជាមួយផ្នែកគ្រប់គ្រងតុលាការសិន ដើម្បីបំពេញទៅតាមតម្រូវការផ្នែកបច្ចេកទេសនានាពីផ្នែកគ្រប់គ្រងតុលាការ ប្រយោជន៍បំពេញឲ្យបានត្រឹមត្រូវទៅតាមនីតិវិធី ។ ឧទាហរណ៍ ការត្រៀមរៀបចំឯកសាររឹង ការកំណត់ផ្នែកណាមួយនៃឯកសារដែលត្រូវយោង ។ល។

អង្គហេតុនៃភស្តុតាង ដែលបានសង្ខេប ឬក៏បានអានរួច សម្រាប់បម្រើគោលបំណងនៃវិធាន ៨៧.២ នឹងនាំទៅរកការតម្រូវឲ្យដាក់ភស្តុតាងនេះទៅក្នុងសំណុំឯកសារថ្មីមួយនៅក្នុងសំណុំរឿង ហើយភស្តុតាងនេះនឹងត្រូវបង់លេខថ្មី ។

ដោយយោងតាមសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ ភស្តុតាងនេះនឹងត្រូវដាក់ក្នុងសំណុំឯកសារ *អ៊ីស្រ៊ី* គឺ *អ៊ីបី (E3)* លើកលែងតែមានការសម្រេចផ្សេងពីនេះ ដោយអង្គជំនុំជម្រះនិងលើកលែងតែមានដីកាបង្គាប់ឲ្យធ្វើការកោសលុប ។ ភស្តុតាងនេះនឹងក្លាយទៅជាឯកសារសាធារណៈ ដែលវាត្រូវបានដាក់ចូលក្នុងសំណុំឯកសារ *អ៊ីបី ។* ហើយភស្តុតាងដែលត្រូវបាននាំយកមកបង្ហាញនៅក្នុងតុលាការដើម្បីគោលបំណងនិងវិធាន៨៧.២ នឹងត្រូវដាក់ចូលក្នុងសំណុំឯកសារ *អ៊ីបី* នឹងក្លាយជាឯកសារ

00285905



សាធារណៈបានតែក្នុងករណីបន្ទាប់ពីកំណត់ហេតុជាលាយលក្ខណ៍អក្សររបស់ក្រឡាបញ្ជីត្រូវបានបំពេញចប់សព្វគ្រប់ និងបានដាក់រួចរាល់ហើយតែប៉ុណ្ណោះ ។ ការណ៍នេះនឹងអាចបំពេញទៅបានទៅតាមព័ត៌មានដែលមាននៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ ។ ឧទាហរណ៍ការកំណត់លេខថ្មីនៃឯកសារ ឬកម្រិតនៃការលាក់សម្ងាត់ប្រសិនបើមាន ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោក ហ្សង់ម៉ាក ដែលបានធ្វើបទបង្ហាញ ។ តទៅនេះសូមប្រគល់វេទិកានេះជូនទៅភាគីដែលពាក់ព័ន្ធ ដើម្បីអាចក្រែងលោចង់មានសំណួរអ្វីសួរដល់ពាក់ព័ន្ធនឹងប្រធាននេះ ។

ជាដំបូង គឺសូមអញ្ជើញមេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណី តើមានចង់បញ្ចេញមតិ ឬក៏មានសំណួរអ្វីពាក់ព័ន្ធនឹងប្រធានបទ ដែលត្រូវបានបង្ហាញដោយលោក ហ្សង់ម៉ាក អម្បាញ់មិញនេះទេ?

សូមអញ្ជើញ លោកស្រីមេធាវី សូមអញ្ជើញ!

**លោកស្រី ម៉ាកទីន ហ្សាកហ្សីន៖**

(អ្នកបកប្រែមិនមានអាចទទួលបានភាសាអង់គ្លេសពីខាងឆ្វេងដៃ ដូច្នេះយើងខ្ញុំមិនអាចបកប្រែជូនបាន សុំអធ្យាស្រ័យ ។ លោកចៅក្រម សុំលោកអធ្យាស្រ័យ បើអនុញ្ញាតសុំបញ្ឈប់មួយភ្លែតព្រោះអ្នកបកប្រែមិនអាចយកឯកសារ វីឡេពីខាងភាសាអង់គ្លេសបាន សុំអធ្យាស្រ័យចាំមួយភ្លែតយើងមានបញ្ហាបច្ចេកទេស) ។

**ប្រធានអង្គជំនុំ៖**

យើងសម្រាកបន្តិច កុំអាលបន្តកិច្ចប្រជុំយើង ពីព្រោះមានបញ្ហាខាងបច្ចេកទេសក្នុងការបកប្រែ។

**អ្នកបកប្រែ៖**

ឥឡូវ អាចយើងឮវិញហើយ លោកចៅក្រម សូមអញ្ជើញ ។ សូមអធ្យាស្រ័យ ។

**ប្រធានអង្គជំនុំ៖**

បាននៅ?

**អ្នកបកប្រែ៖**

បានហើយលោកៅចៅក្រម ខ្ញុំអាច-- លោកចៅក្រមអញ្ជើញបន្តបានទៀត ។

**លោកស្រី ម៉ាកទីន ហ្សាកហ្សីន៖**

...បញ្ហាដែលខ្ញុំលើកនេះ គឺទាក់ទងជាមួយនឹងកាលបរិច្ឆេទកំណត់ ដោយសួរថាមួយណាជា

កាលបរិច្ឆេទកំណត់សម្រាប់ភាគីក្នុងការដាក់ភស្តុតាង ព្រោះភស្តុតាងដែលសង្ខេប ឬក៏យើងដាក់ភស្តុតាងដែលត្រូវអាននោះ ព្រោះអីបើសិនជាយើងមើលនៅនេះគឺសេចក្តីថ្លែងផ្សេងៗពីភាគីនេះ គឺត្រូវតែដាក់មកក៏ប៉ុន្តែភាគីដោយសារភាគីមិនបានដឹងមុន ក៏យើងនឹងពិបាកដាក់ជូនឲ្យទាន់ពេលដែរ ។

**ប្រធានអង្គជំនុំ៖**

អរគុណចំពោះ-- សូមអញ្ជើញ លោក ហ្សង់ ម៉ាក ។

**ចៅក្រម ហ្សង់ ម៉ាកឡាវែន៍៖**

សូមអរគុណ លោកចៅក្រមប្រធាន ។ តាមពិតទៅនៅក្នុងបញ្ហានេះ គឺយើងដឹងហើយថា មានដើមបណ្តឹង ឬភាគីមួយចំនួនចង់ដាក់ឯកសារមួយចំនួនបានមុន ដែលខ្លួនចង់ឲ្យមានការពិភាក្សានៅក្នុងកិច្ចសវនាការ ។ ហើយក្នុងនេះ គឺមិនមានកាលបរិច្ឆេទកំណត់ណាជាក់លាក់បានកំណត់ទេ ព្រោះអីឥឡូវយើងគិតថា សវនាការគឺជាទូទៅនឹងអាចធ្វើទៅបានទៅតាមការបត់បែន និងទន់ភ្លន់ បើអាចធ្វើបាន ។

បើសិនជាខ្ញុំអាចប៉ាន់ប្រមើលមើលឃើញអំពីកាលវិភាគនេះ មុនគឺវាជាការល្អ ក៏ប៉ុន្តែបើសិនយើងធ្វើអ៊ីចឹងបាន គឺភាគីលោកអាចដឹងថាតើសាក្សីណានឹងត្រូវធ្វើសក្ខីកម្មនៅក្នុងថ្ងៃណា ? ហើយលោកអាចរៀបចំឯកសារផ្សេងៗដែលលោកនឹងដាក់ដើម្បីឲ្យ ឬក៏ជួយសាក្សីរូបនោះ ។ ក៏ប៉ុន្តែ ខ្ញុំគិតថាអ្វីដែលនឹងមានកើតឡើងគឺ ខ្ញុំមិនទាន់ឲ្យចម្លើយជាក់លាក់បាននៅឡើយទេ ។

**ប្រធានអង្គជំនុំ៖**

ជាបន្តសូមអញ្ជើញ មេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណីបន្តទៀត ។

**លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រី ។

**លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី៖**

អ៊ីចឹងគឺខ្ញុំមានសំណួរមួយ ខ្ញុំចង់ដឹងថា នៅក្នុងនីតិវិធីនេះ ដែលលោកចៅក្រមបានផ្តល់បទឧទ្ទេសនាមហ្នឹង ទាក់ទងទៅនឹងឯកសារថ្មីដែលមិនទាន់ត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿង ។

**ចៅក្រម ហ្សង់ ម៉ាកឡាវែន៍៖**

ខ្ញុំគិតថា សំណួរហ្នឹងត្រូវបានលើកឡើងហើយទាក់ទងទៅនឹងឯកសារថ្មី ហើយខ្ញុំនឹងឆ្លើយតប

នឹងសំណួររបស់អ្នកស្រីនៅពេលក្រោយទាក់ទងទៅនឹងការសួរនឹងសំណួរទាក់ទងទៅនឹងឯកសារថ្មី ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត តើមានមេធាវីខាងតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានសំណួរ ឬក៏មានបញ្ហាអីផ្សេងទៀតទេ ពាក់ព័ន្ធនឹងរបៀបវារៈអម្បាញ់មិញនេះ?

បើមិនមានទេ សូមអញ្ជើញសហព្រះរាជអាជ្ញា តើសហព្រះរាជអាជ្ញា មានសំណួរ ឬក៏មានបញ្ហាអ្វីទេ ពាក់ព័ន្ធទៅនឹងបទបង្ហាញអម្បាញ់មិញនេះ?

អ៊ូខេ *(OK)* សូមអញ្ជើញ ។

**លោក រ៉ូបឺត ពើទីត៖**

សូមអរគុណលោកប្រធាន ។ យើងប្រហែលជាអាចត្រូវអាននូវកំណត់ហេតុមួយ ដើម្បីឲ្យបានយល់ដឹងអំពីនីតិវិធីដែលបានទើបតែបង្ហាញនៅពេលថ្មីៗនេះ ។ ប៉ុន្តែ ជាមួយនឹងការយល់ដែលខ្ញុំមាននេះ ទាក់ទងទៅនឹងអ្វីដែលបានលើកឡើងពីភាគីដទៃ គឺមានន័យថា ភាគីទាំងឡាយត្រូវដាក់ចុះជាមុននូវបញ្ជីភស្តុតាង ដែលពួកគេចង់ឲ្យមានការត្រួតពិនិត្យនោះ ។ ហើយខ្ញុំមិនគិតថា បញ្ហានេះនឹងជាបញ្ហាអ្វីមួយធំដុំនោះទេ ទាក់ទងទៅនឹងភាពដែលយើងអាចបទបែនបាននៅក្នុងនីតិវិធីនោះ ។

ខ្ញុំក៏ចង់លើកបញ្ហានេះដែរថា ខ្ញុំក៏ចង់ធ្វើការកត់សម្គាល់ដែលថា យើងប្រហែលជាអាចនឹងប្រើធនធានដែលយើងមានក្នុងការផ្តល់ចម្លងនូវឯកសារចម្លងនូវនៃឯកសារ ពីព្រោះវាពិបាកក្នុងការគ្រប់គ្រងក្នុងការធ្វើសវនាការណាស់ ។ ដូចដែលខាងសហសេវិកខ្ញុំបាននិយាយអីចឹងគឺពិបាកក្នុងការតទល់ពិភាក្សាគ្នា បើសិនជាឯកសារហ្នឹងមិនបានផ្តល់គ្រប់គ្រាន់ ។

ដូច្នេះហើយ ប្រសិនបើអ្វីទាំងអស់ហ្នឹងអាចធ្វើការបានទៅតាមដំណើររបស់ខ្លួននោះ គឺថាយើងអាចដំណើរនីតិវិធីបាន ឬមួយថាភស្តុតាងដែលមាននៅក្នុងសំណុំរឿងហ្នឹង អាចដាក់ក្នុងទម្រង់*ឌីជីថល* មានន័យថា ក្នុងទម្រង់ជាអេឡិចត្រូនិច ហើយខ្ញុំជឿថា គោលបំណងរបស់យើងហ្នឹង គឺថាភាគីនីមួយៗនៅក្នុងអង្គជំនុំជម្រះ គឺត្រូវផ្តល់នូវច្បាប់ចម្លងនៃឯកសារដែលមាននៅក្នុងសំណុំរឿងនោះ ។ ហើយប្រសិនបើប្រព័ន្ធដែលយើងមានបច្ចុប្បន្នហ្នឹង គឺថាអាចដំណើរការដូច្នេះនោះ យ៉ាងណាមិញ គឺអាចជាបញ្ហាមួយ គឺថាបើសិនជាភាគីចង់ដាក់ឯកសារដើម្បីធ្វើការពិភាក្សាគ្នា ហើយសេចក្តីសង្ខេបនោះគឺថានឹងមិនមែនជាចំណែកមួយនៅក្នុងសំណុំរឿងទេ ។ ហើយនឹងមិនអាចផ្តល់ជូន បើក្នុងទម្រង់ផ្សេងទៀតបានទេ ។ ហើយគឺថាឯកសារហ្នឹងឯង អាចជាចំណុចមួយដែលអាចនឹងធ្វើការឆ្លើយតទល់គ្នាបាន

ពីព្រោះ នេះគឺជាអ្វីដែលឯកសារផ្សេងទៀតបានដាក់បញ្ចូល ។ ដូច្នេះ ខ្ញុំចង់ឲ្យខាងអង្គជំនុំជម្រះធ្វើកាលវិភាគទៅលើនីតិវិធីក្នុងការទទួល ឬក៏ផលិតនូវឯកសារសង្ខេបដែលភាគីនីមួយៗបានធ្វើ ដើម្បីធ្វើការការពារបញ្ហាបច្ចេកទេសទាក់ទងទៅនឹងភាពចាំបាច់ក្នុងការផលលទ្ធឯកសារ ដែលមាននៅក្នុងសំណុំរឿង ។

នេះគឺជាមតិយោបល់របស់ខ្ញុំ នៅលើចំណុចនេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណ លោកសហព្រះរាជអាជ្ញា ។ ជាបន្តទៀត លោកមេធាវីការពារជនជាប់ចោទមានអ្វីចង់និយាយទេ ឬក៏មានចង់កត់សម្គាល់ ដែលទាក់ទិនជាមួយរបៀបវារៈនេះ?

សូមអញ្ជើញ ។

**លោក ហ្រ្វង់ស្វ័រ រ៉ូ៖**

សូមអរគុណណាស់ លោកចៅក្រម លោកប្រធាន ។ ជាដំបូង ខ្ញុំបានឮលោកចៅក្រមបានអាននូវរបៀបវារៈ តាមទម្រង់បែប ក ខ គ ឃ គឺថាយើងអត់មានដូចថា អ្នកណាជារបៀបវារៈបន្តបន្ទាប់តូចៗនោះទេ គឺថាយើងអត់ ឬក៏ឯកសារដែលយើងមាននោះមិនមែនជាឯកសារបកប្រែត្រឹមត្រូវ ដែលយើងមានជាភាសាខ្មែរទេ ។ នេះជាសំណួរទាក់ទងទៅនឹងរបៀបវិធី ។

បញ្ហាទាក់ទងនឹងភស្តុតាងថ្មីនោះ ខ្ញុំគិតថា ជាការពិតណាស់ យើងត្រូវតែគិតអំពីវិធានជាក់លាក់ណាមួយនៅក្នុងពេលដំណាលគ្នា ដែលជាការបញ្ជាក់ច្បាស់ថា-- ដោយយោងទៅលើការពិភាក្សាគ្នានៅក្នុងសវនាការ ដែលយើងនឹងរៀបចំសម្របសម្រួលនៅពេលមុខនោះ ទាក់ទងទៅនឹងនីតិវិធី ហើយនិងអ្វីដែលខ្ញុំសុំស្នើនៅក្នុងពេលនេះ គឺគោលការណ៍នៃការត្រួតពិនិត្យភស្តុតាងទាំងនោះ គឺថាត្រូវតែអនុលោមតាម ដែលមានន័យថា គឺថាយើងត្រូវទុកឱកាសដើម្បីខាងមេធាវីការពារក្តី ដើម្បីត្រួតពិនិត្យភស្តុតាងណាមួយ ឬក៏ឯកសារណាមួយ ឬក៏ភស្តុតាងថ្មីណាមួយ ដើម្បីរៀបចំ ហើយនិងរៀបចំនូវការឆ្លើយតបទៅនឹងឯកសារ ឬក៏ភស្តុតាង ដែលគេបានបង្ហាញនៅក្នុងពេលសវនាការនោះ ។

យើងប្រហែលជាត្រូវធ្វើការពិភាក្សានៅពេលក្រោយទៀត អំពីបញ្ជីឯកសារថ្មីដែលខាងការិយាល័យសហព្រះរាជអាជ្ញា បានរៀបចំរួចជាស្រេចហើយ ក្នុងគោលបំណងដាក់បញ្ចូលទៅក្នុងសំណុំរឿងនេះ ។ នេះគឺជាបញ្ជីដែលយើងបានទទួលកាលពីបីថ្ងៃមុន ហើយដូចដែលខ្ញុំបាននិយាយកាលពីព្រឹកមិញអ៊ីចឹង គឺមិនមែនបីថ្ងៃមុន គឺម្សិលមិញ ព្រឹកម្សិលមិញនេះឯង ដែលខាងក្រុមការពារក្តីបានទទួល ។

ហើយយើងបានដឹងថា មានឯកសារថ្មី មានន័យថាបន្ថែមទៀត ដែលខាងការិយាល័យព្រះរាជអាជ្ញាមានបំណងដាក់បញ្ចូលទៅក្នុងសំណុំរឿងនេះ ។ ហើយនៅខាងក្រុមការពារក្ដីហ្នឹង គឺចង់ធ្វើការដាក់ពាក្យបន្ថែមទៀតដែរ ប៉ុន្តែគឺថាយើងអត់មាន ក ខ គ ឃ តូចៗនៅក្នុងរបៀបវារៈរបស់យើងទេ ។ ហើយអ៊ីចឹងតើខាងអង្គជំនុំជម្រះសាលាក្ដីដំបូងហ្នឹង អាចធ្វើការបញ្ជាក់បន្ថែមទៅលើចំណុចនេះបានទេអំពីភស្តុតាងថ្មីដែលខាងពីសហព្រះរាជអាជ្ញាគាត់បានដាក់បង្ហាញជូននោះ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ ម៉ាកឡាវែន៍៖**

អក្សរ ខ ហ្នឹង គឺជាការបង្ហាញ គឺមានសេចក្ដីណែនាំពីខាងអង្គជំនុំជម្រះ ទាក់ទងទៅនឹងភស្តុតាងដែលភាគីណាមួយដែលចង់ឲ្យមានការត្រួតពិនិត្យនោះ ហើយគឺមិនមែននិយាយអំពីនោះទេ នេះគឺជាភស្តុតាងទូទៅ ។ ហើយខ្ញុំមិនដឹងថាតើមានចំណុចណាមួយទាក់ទងនៅនឹងភស្តុតាងថ្មីនោះទ?

ចំណែកទាក់ទងចំណុច គ តូចនោះ គឺបញ្ហាទាក់ទងទៅនឹងសាក្សីបន្ថែមទៀត ដែលសាក្សីនោះមិនមានឈ្មោះនៅក្នុងសំណុំរឿង ឬក៏មិនមាននៅក្នុងដីកាដំណោះស្រាយ ។

ហើយទាក់ទងទៅនឹងអក្សរ ឃ តូចនោះ ទាក់ទងទៅនឹងបញ្ជីឈ្មោះសាក្សី ឬក៏ភស្តុតាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីថ្មី គឺមានន័យថា ជាដើមបណ្ដឹងរដ្ឋប្បវេណីថ្មី នៅក្នុងរង្វង់ក្រចក ។

ហើយទាក់ទងទៅនឹងអក្សរ ង តូចនោះ គឺទាក់ទងនឹងការកំណត់កាលបរិច្ឆេទសវនាការសម្រាប់ភាគីរដ្ឋប្បវេណីដែលបានជ្រើសរើស ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកមេធាវី ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកមេធាវី សូមអរគុណលោកចៅក្រម ។

សំណួររបស់ខ្ញុំ គឺថាវាមានហេតុផល ហើយខ្ញុំសុំគោរពនូវអ្វីដែលលោកចៅក្រមបានលើកឡើងនោះ ហើយនឹងឯកសារបកប្រែដែលខ្ញុំមាននេះ ។ នៅក្នុងបទជាភាសាបារាំងរបស់យើងនេះ គឺថា ក ខ តូចនោះ នៅក្នុងចំណុចបី ចំណែក "គ,ឃ" នោះ គឺនៅក្នុងចំណុចទីពីរវិញទេ អ៊ីចឹងហើយវាពិបាកសម្រាប់រូបខ្ញុំដើម្បីបានធ្វើការតាមដាននៅក្នុងនីតិវិធីនេះ ។ ខ្ញុំមិនដឹងថា នេះគឺជាបញ្ហាទាក់ទងទៅនឹងការ

បកប្រែ ឬក៏យ៉ាងណានោះទេ ។

អ៊ីចឹងនៅក្នុងករណីនេះ គឺអត់មានជាការធ្វើ ឬក៏ការដាក់ទារុណកម្ម ទៅលើអ្នកនិយាយភាសាបារាំងទេមែនទេ?

**ប្រធានអង្គជំនុំ៖**

អរគុណ លោកមេធាវី ។

មានអីទៀតទេ មានអ្វីពាក់ព័ន្ធនឹងការកំណត់សម្គាល់ពាក់ព័ន្ធទៅនឹងរបៀបវារៈ ៣ (ក) នេះ? បើមិនមានទេ គឺសូមអញ្ជើញ លោកឡាវែន៍ បន្តធ្វើបទបង្ហាញបន្តទៀត នៅចំណុចបន្ទាប់ ។

**ចៅក្រម ហ្សង់ ម៉ាកឡាវែន៍៖**

សូមអរគុណលោកប្រធាន ។ ចំណុចបន្ទាប់មកទៀត គឺទាក់ទងនៅនឹងសេចក្តីណែនាំពីអង្គជំនុំជម្រះ អំពីទាក់ទងទៅនឹងការជូនព័ត៌មានអំពីភស្តុតាង ដែលខាងភាគីមានបំណងចង់ឲ្យធ្វើការត្រួតពិនិត្យនៅក្នុងសវនាការ ។ គឺថា ខាងសហប្រជាជាតិ បានចោទសួរថាតើនៅពេលណាទៅដែលត្រូវគួរផ្តល់ដល់អង្គជំនុំជម្រះសាលាដំបូង អំពីភស្តុតាងដែលគួរត្រូវបានលើកឡើងនៅក្នុងអំឡុងពេលសវនាការ ។ ហើយតើដំណើរការហ្នឹងគួរតែធ្វើយ៉ាងដូចម្តេច?

ខាងអង្គជំនុំជម្រះមានការកត់សម្គាល់ទៅតាមវិធាន ៩២ នោះ ភាគីអាចធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររហូតដល់ការបិទការពិភាក្សាដេញដោល ។ អ៊ីចឹងការជូនដំណឹងអំពីភស្តុតាង ដែលភាគីយល់ឃើញថាគួរត្រូវបានលើកឡើង ដើម្បីធ្វើការត្រួតពិនិត្យនោះ គឺត្រូវធ្វើឡើងនៅក្នុងសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ។ គឺនេះអាស្រ័យទៅតាមស្មារតីនៃវិធាន៩២ ដូច្នេះហើយ ទោះបីជាការជូនដំណឹងហ្នឹង មិនបានផ្តល់ជូនក៏ដោយ ភាគីអាចជូននូវការជូនដំណឹងពីភស្តុតាង ដែលខ្លួនមានបំណងចង់លើកឡើងនៅក្នុងអំឡុងពេលសវនាការនោះ សម្រាប់ការក្នុងគោលបំណងនៃការបកប្រែនោះឯង គឺថាឯកសារហ្នឹងគួរតែត្រូវបានទទួលឲ្យមុន ដូច្នេះវាមានប្រយោជន៍ជាង ។ ហើយខាងអង្គជំនុំជម្រះក៏ឲ្យភាគីនីមួយៗចង់ធ្វើការចង្អុលបង្ហាញឲ្យបានច្បាស់លាស់នូវភាសាណាមួយដែលជាភាសាការងារ ដែលចង់ឲ្យមានការបកប្រែឯកសារនោះចូល ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកចៅក្រម ហ្សង់ម៉ាក ដែលបានធ្វើបទបង្ហាញអំពីរបៀបវារៈ បីខ នេះ ។ ទាក់ទិនជាមួយនឹងរបៀបវារៈនេះ តើភាគីពាក់ព័ន្ធនឹងមានសំណួរ ឬក៏មានកត់សម្គាល់អ្វីទេ? ជាបឋម គឺជូន

វេទិកានេះទៅមេធាវីអ្នកតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ។

សូមអញ្ជើញលោកស្រី ។

**លោកស្រី ស៊ីលឃី ស្ទូតហ្វ៊ីនស្គី៖**

សូមអរគុណ លោកប្រធាន ។

ខ្ញុំចង់ដឹងថាតើអង្គជំនុំជម្រះនេះនឹងធ្វើការដោះស្រាយយ៉ាងម៉េចទៅនឹងជម្រើសផ្សេងគ្នាដូចតទៅនេះ៖

ជម្រើសទីមួយ គឺសាក្សីថ្មី ដែលមិនមានឈ្មោះនៅក្នុងសំណុំរឿង ហើយដែលនឹងមិនមាននូវឈ្មោះនៅក្នុងដីកាដំណោះស្រាយនោះ គឺថាទាក់ទងទៅនឹងចំណុចនៃការចោទប្រកាន់ហើយនិងទៅនឹងចំណុចនៃអង្គហេតុ ។

ចំណុចទីពីរ ជម្រើសទីពីរ គឺសាក្សីថ្មី ដែលនឹងត្រូវបង្ហាញមុខទាក់ទងទៅនឹងចំណុចនៃការចោទប្រកាន់គឺគឺបានន័យថាការចោទប្រកាន់ដែលមាននៅពេលបច្ចុប្បន្ននេះ ប៉ុន្តែគឺទាក់ទងទៅនឹងអង្គហេតុដែលមិនទាន់បានលើកឡើងនៅឡើយនោះ ដែលជាអង្គហេតុថ្មី ។

ហើយជម្រើសទីបី សាក្សីនានា ដែលមានឈ្មោះនៅក្នុងសំណុំរឿង ប៉ុន្តែមិនទាន់ត្រូវបានផ្តល់សក្ខីកម្មនៅឡើយទេ មានន័យថាគ្រាន់តែមានឈ្មោះ ប៉ុន្តែមិនទាន់បានផ្តល់សក្ខីកម្មនោះ. ដូចជាមានឈ្មោះនៅក្នុងការជូនដំណឹងជាដើម ។ ហើយសាក្សីអស់ទាំងនុ៎ងឯងគឺមាននៅក្នុងការ ចោទប្រកាន់ទាក់ទងទៅនឹងអង្គហេតុថ្មីដែលមិនបានដាក់បញ្ចូលនៅក្នុងដីកាដំណោះស្រាយ ។ ហើយប្រហែលជាសំណួរដូចគ្នានេះដែរ អាចនឹងត្រូវបាន ឬក៏គួរត្រូវបានពិភាក្សាដើម្បីដោះស្រាយដែលទាក់ទងនឹងភាគីណាមួយនោះ ។

ជាដំបូងខ្ញុំចង់ដឹងថា តើអង្គជំនុំជម្រះហ្នឹងនឹងធ្វើការដោះស្រាយទាក់ទងទៅនឹងចំណុចអស់ទាំងហ្នឹងយ៉ាងដូចម្តេច? គឺទាក់ទងទៅនឹងសាក្សីថ្មីៗនោះ ។ ហើយដើម្បីឆ្លើយតប ប្រសិនបើថានេះអាចជាករណីទាក់ទងនឹង វិធានលេខ៨៣ ឬមួយក៏ត្រូវដោះស្រាយដោយរបៀបណានោះ? សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ហ្សង់ម៉ាក ដើម្បីធ្វើការតតបទៅនឹង--ទៅនឹងអ្វីដែលលើកឡើងដោយមេធាវីអម្បាញ់មិញនេះ ។

**ចៅក្រម ហ្សង់ ម៉ាកឡាវែន៍៖**

ខ្ញុំគិតថាសំណួរនេះនឹងមាននៅក្នុងចំណុច គ គឺបញ្ហាទាក់ទងទៅនឹងសាក្សីថ្មីបន្ថែមទៀតដែលមិនមានឈ្មោះនៅក្នុងសំណុំរឿង ឬក៏មិនមាននៅក្នុងដីកាដំណោះស្រាយ ។ អង្គជំនុំជម្រះបានពិនិត្យទៅលើលទ្ធភាពក្នុងការឆ្លើយតបទៅនឹងចំណុចអស់ទាំងនេះ ទាក់ទងទៅនឹងសាក្សី គឺទាក់ទងទៅនឹងវិធានលេខ៨០ គឺថាអាចរាប់បញ្ចូលទាំង រាល់បុគ្គលិកទាំងអស់ដែលភាគីមានបំណងកោះហៅដើម្បីផ្តល់នូវភស្តុតាង ទាក់ទងទៅនឹងអង្គហេតុដែលមាននៅក្នុងដីការបញ្ជូនរឿងទៅជំនុំជម្រះ ដោយមិនគិតពីចរិតលក្ខណៈផ្លូវច្បាប់នៃអង្គហេតុទាំងនោះ ។

សាក្សីដែលបានស្នើឡើងនោះ អាចជាសាក្សីដែលបានស្តាប់ចម្លើយរួចហើយក្នុងដំណាក់កាលស៊ើបអង្កេត ព្រមទាំងបុគ្គលផ្សេងទៀត ដែលមិនទាន់បានស្តាប់ចម្លើយរហូតមកដល់ពេលនេះ ។ ហើយថាតើសាក្សីនោះ មិនមានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឬទេ? អ្វីចឹងការពិតនៅទីនេះគឺទាក់ទងទៅនឹងអង្គហេតុ គឺថាអ្វីដែលបានដាក់បញ្ចូលបញ្ជូនមកខាងអង្គជំនុំជម្រះនេះ ឬក៏ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ ។

**ប្រធានអង្គជំនុំ៖**

លោក ហ្សង់ម៉ាក ដែលបានឆ្លើយបំភ្លឺតបទៅនឹងសំណួរពាក់ព័ន្ធទៅនឹងសំណួរ ឬការកត់សម្គាល់របស់លោកស្រីមេធាវី ។ ជាបន្តទៀត សូមអញ្ជើញមេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត តើមានអ្វីចង់កត់សម្គាល់ ឬក៏ចង់បញ្ចេញមតិយោបល់ពាក់ព័ន្ធទាក់ទងនឹងរបៀបវារៈនេះទេ?

បើមិនមានទេ គឺសូមជូនវេទិកានេះទៅខាងសហព្រះរាជអាជ្ញា ។ តើលោកសហព្រះរាជអាជ្ញាតើមានអ្វីចង់កត់សម្គាល់ ឬក៏សួរពាក់ព័ន្ធនឹងរបៀបវារៈ ៣(ខ) នេះទេ? សូមអញ្ជើញលោក ពើទីត ។

**លោក រ៉ូប៊ីត ពើទីត៖**

សូមអរគុណលោកប្រធាន ។ ជំហររបស់អង្គជំនុំជម្រះគឺត្រូវធ្វើចេញបទប្បញ្ញត្តិទាក់ទងទៅនឹងចំណុចអស់នេះ ពីព្រោះគឺថាយើងត្រូវពិភាក្សាទៅនឹងចំណុចអក្សរ ឃ ផងដែរ គឺទាក់ទងទៅនឹងឯកសារ ។ ក៏ប៉ុន្តែ បើក្នុងលក្ខណៈទូទៅយើងអាចនិយាយថា ខ្ញុំអាចស្នើសុំឲ្យអង្គជំនុំជម្រះហ្នឹងធ្វើការពិចារណាថា តើភាគីទាំងអស់ដែលថាមានឱកាសច្រើនខែច្រើនឆ្នាំមកហើយនោះ គឺថាអាចនឹងរកឃើញនូវបំណែកនៃភស្តុតាងណាមួយដែលភាគីនោះយល់ថានឹងមានតម្លៃសំខាន់ ហើយដែលគួរតែត្រូវយកមកបង្ហាញនៅក្នុងតុលាការ ។ គួរតែមានវិធីកំណត់ណាមួយ ដែលភាគីនោះអាចពន្យល់ថាតើហេតុ

អ្វីបានជាភស្តុតាងហ្នឹងមិនត្រូវបានបង្ហាញជូនកាលពីមុនមកនោះ ។ ដើម្បីចៀសវាងការរំខានបែបនេះ ទាក់ទងទៅដល់អាកប្បកិរិយា ឬក៏ការប្រព្រឹត្តិទៅនៃនីតិវិធី លោកចៅក្រមបានដឹងហើយទាក់ទងនឹងភាពលំបាកដែលកើតមានឡើងនៅក្នុងនីតិវិធីនេះ ហើយលោកប្រធាន--ហើយនិងអ្វីដែលយើងមានដែលជាកេរដំណែលបន្សល់ពីតុលាការពីមុនមកនោះ ។ នេះជាអ្វីដែលខ្ញុំបានលើកឡើងជាមតិយោបល់របស់ខ្ញុំទាក់ទងទៅនឹងសាក្សី ឬភស្តុតាងថ្ងៃនេះ ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកសហព្រះរាជអាជ្ញា ។ ឥឡូវនេះខ្ញុំផ្តល់នាទីនេះជូនមេធាវីការពារជនជាប់ចោទ ។ តើលោកមានអ្វីពាក់ព័ន្ធ-- បញ្ហាអ្វីពាក់ព័ន្ធនឹងរបៀបវារៈនេះទេ ឬក៏មានអ្វីកត់សម្គាល់ទេ?

សូមអញ្ជើញ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធានអង្គជំនុំជម្រះ ។ អរគុណ ហើយខ្ញុំបានជ្រាបនូវអ្វីដែលលោកសហព្រះរាជអាជ្ញាបានលើកហើយខ្ញុំយល់ស្របតាមហ្នឹង ។ ហើយខ្ញុំក៏សូមស្នើឲ្យភាគីទាំងអស់ហ្នឹង ឬក៏ខ្លួនគាត់ហ្នឹង គឺអនុវត្តទៅតាមវិធានហ្នឹងផង ។ ព្រោះនៅក្នុងនេះគឺខាងមេធាវីជនជាប់ចោទហ្នឹងក៏មានចំណុចត្រូវលើកច្រើនផងដែរ ជាពិសេសទាក់ទងជាមួយនឹងភស្តុតាងថ្មី ដែលគេទើបបានជូនមកឲ្យយើងដឹងកាលពីម្សិលមិញតាមរយៈឯកសារដែលជូនយើង ។ ហើយឥឡូវនៅទីនេះខ្ញុំក៏សូមបញ្ជាក់ផងដែរដំបូងនេះគឺខ្ញុំសុំជជែកអំពីឯកសារលេខ៨ ទាក់ទងជាមួយកថាខណ្ឌលេខ ១២ និងឯកសារលេខ ២៩ ដែលមាននៅក្នុងកថាខណ្ឌ ១៣ ។

នៅក្នុងឯកសារលេខ៨ ហ្នឹង បើតាមទៅឃើញមានពាក្យពេជន៍ទាក់ទងជាមួយនឹងចម្លើយសារភាពដែលយកមកពីសាក្សី ម៉ម ណៃ ហើយនិងឯកសារ ២៩ តាមពិតមិនមានឯកសារដើមទេ ។

**លោក រ៉ូប៊ឺត ពើទីត៖**

សុំទោស ខ្ញុំសុំកាត់លោកបន្តិច ខ្ញុំសុំរំឭកអំពីសេចក្តីសម្រេចរបស់តុលាការនេះទាក់ទងជាមួយនឹងការប្រើរហស្សនាម ទាក់ទងជាមួយនឹងសាក្សី ហើយកុំឲ្យប្រើឈ្មោះគាត់ពេញអ៊ីចឹង ។ សុំទោស ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

ឯកសារ២៩ នេះទាក់ទងជាមួយនេះគឺយើងបាន សហព្រះរាជអាជ្ញាថាមិនមានឯកសារដើមទេ ហើយមិនមានឯកសារបកប្រែជាភាសាអង់គ្លេសចំពោះឯកសារនេះផង ។ អ៊ីចឹងនេះមេធាវីការពារក្តីគឺ

00285914



មិនដឹង មិនមានអ្វីជ្រាបច្បាស់ទាក់ទងជាមួយនឹងការស៊ើបអង្កេតមួយឆ្នាំពេញ ដែលសហព្រះរាជអាជ្ញាហ្នឹង គាត់មានដូចថាកិច្ចសហការគ្នាយ៉ាងល្អច្រើនណាស់ទាក់ទងជាមួយចំណុចនេះ ។

តែយើង--ខាងយើងហាក់ដូចជាគ្មាន ។ ហើយតើមានប្រយោជន៍អីនៅក្នុងការដាក់ឯកសារទាំងនេះ? ព្រោះអីវាហាក់បីដូចជាជំទាស់ទៅនឹងគោលការណ៍មួយដែលខ្ញុំ--ដ្បិតតែថាខ្ញុំយល់ស្រប ក៏ប៉ុន្តែទាក់ទងជាមួយសាក្សីដដែលនេះ ខ្ញុំសូមឆ្លៀតឱកាសនេះផងដែរ សុំឲ្យ--ដូចដែលលោកស្រី ខាតរ៉ាយថ៍ ខ្ញុំសុំរំឭកពីសំណួរដែលលោកលើកពីព្រឹកមិញ កាលពីក្នុងពេលសម្រាកហ្នឹង គឺលោកលើកអំពីសាក្សីដែលមានចំនួន១១ និងសាក្សី២ថ្មីទៀតដែលដើមបណ្តឹងរដ្ឋប្បវេណី ដែលថាបានធ្លាប់មានការតទល់គ្នាក្នុងដំណាក់កាលស៊ើបអង្កេតជាមួយនឹងជនត្រូវចោទក្នុងដំណាក់កាលនោះ ។

ហើយទាក់ទងជាមួយនឹងបញ្ហាសាក្សីដដែលនេះ លោកចៅក្រម ឡាវែន៍ លោកបានសំដៅទៅលើអ្នកដែលជាសាក្សីនៃអង្គហេតុ ។ ហើយបើតាមខ្ញុំដឹង មេធាវីការពារក្តីសុំឲ្យចៅក្រមស៊ើបអង្កេតហ្នឹង គឺផ្តល់ជាការធ្វើសវនាការទៅលើសាក្សី និយាយទៅគឺក្នុងការទទួលបានព័ត៌មានពីអត្តសញ្ញាណរបស់សាក្សីហ្នឹង ដើម្បីកុំឲ្យមានការពន្យារពេលនៅក្នុងសវនាការ ព្រោះនេះជាកាតព្វកិច្ចរបស់យើងនៅក្នុងការស្នើសុំឲ្យមានការធ្វើដូច្នេះ ។

ការយើងធ្វើនេះ គឺដោយសារយើងមិនចង់ឲ្យមានការដំណើរពន្យារពេលហ្នឹង ។ ហើយអ៊ីចឹងជាលទ្ធផល គឺបញ្ជីរបស់យើង គឺមានចំនួនសាក្សីត្រឹមតែ១៥ ប៉ុណ្ណឹងទេ ។ ហើយក្នុងហ្នឹងមានតែសាក្សីតែមួយចំនួនតូចប៉ុណ្ណោះដែលមិនមែនជាសាក្សីនៃអង្គហេតុ ។

ហើយនៅក្នុងនេះក៏យើងបានជម្រាបផងដែរចំណុចទៅខាងការិយាល័យសហព្រះរាជអាជ្ញាទាក់ទងជាមួយនឹងការបែងចែកសាក្សី ដែលយើងមានសាក្សីអង្គហេតុ និងសាក្សីដែលមិនមែនពាក់ព័ន្ធជានឹងអង្គហេតុ ។ ហើយតាមពិតនោះគឺជាអ្វីដែលខ្ញុំចង់ជម្រាបចៅក្រម ខ្ញុំមានតែប៉ុណ្ណឹងឯង ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ដែលបានធ្វើការកត់សម្គាល់ពាក់ព័ន្ធទៅនឹងរបៀបវារៈ ដែលបានបង្ហាញអម្បាញ់មិញនេះ ។ សូមអញ្ជើញចៅក្រម ហ្សង់ ម៉ាកឡាវែន៍ ។

**ចៅក្រម ហ្សង់ ម៉ាកឡាវែន៍៖**

តាមពិតនេះគឺជាមតិយោបល់ទេ មិនមែនជាសំណួរទេ ។ ព្រោះសាក្សី គឺជាសាក្សីនៃអង្គហេតុ ឬក៏ជាសាក្សីដែលអាចនឹងមកផ្តល់ជាគំនិត ដូចថាសាក្សីជំនាញ។ អ៊ីចឹងនៅក្នុងនេះគឺយើងត្រូវតែរៀបចំ

ឲ្យមានជាផែនការ ឬក៏សេនារីយូដើម្បីឲ្យ-- បានន័យថាវាជាការមានប្រយោជន៍ក្នុងការយើងរៀបចំចំណុចនេះ ដើម្បីសម្រាប់សវនាការខាងមុខ ។

ឥឡូវនេះខ្ញុំសុំចូលទៅចំណុច ឃ ដែលនិយាយអំពីកាលបរិច្ឆេទកំណត់នៅក្នុងការដាក់ឈ្មោះសាក្សី ឬក៏វត្ថុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីថ្មី ។ តាមលក្ខណៈជាក់ស្តែងគឺ ក្នុងនេះគឺយើងអាចនឹងចែក ដើមបណ្តឹងរដ្ឋប្បវេណីនេះជាលក្ខណៈក្រៅផ្លូវការដូចខាងក្រោម៖

ទីមួយ៖ យើងអាចហៅដើមបណ្តឹងរដ្ឋប្បវេណីនេះថាជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានស្រាប់ បានន័យថាដែលបានទទួលការជូនដំណឹងអំពីពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណីនេះ ពីសហចៅក្រមស៊ើបអង្កេត ។ ហើយនេះក្នុង-- បើតាមអនុលោមតាមវិធាន២៣.៣ ។ ហើយយើងក៏អាចចែកចំណាត់ថ្នាក់មួយទៀតថា ដើមបណ្តឹងរដ្ឋប្បវេណីថ្មី ដែលបានដាក់ពាក្យសុំក្រោយបញ្ចប់ការស៊ើបសួរ ហើយវិធាន២៣.៤ ក៏មានចែងអ៊ីចឹង។ ហើយពាក្យសុំរបស់គាត់នេះ នឹងត្រូវពិចារណាក្នុងដំណាក់កាលសវនាការបឋមទៅតាមវិធាន៨៣.១ ។

ចំពោះដើមបណ្តឹងរដ្ឋប្បវេណីថ្មី ដែលពាក្យសុំរបស់គាត់មានភស្តុតាងដែលអាចពិនិត្យបានភ្លាមៗ បានន័យថាសេចក្តីបញ្ជាក់ដំបូង នឹងទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីការទទួលស្គាល់បណ្តោះអាសន្ន ដោយក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងមុនសវនាការបឋម ។ ការជូនដំណឹងនេះនឹងរួមបញ្ចូលទាំងបញ្ជីឈ្មោះដែលដាក់ដោយសហព្រះរាជអាជ្ញា ហើយពួកគាត់ដែលទទួលបានងារជាភាគីដើមបណ្តឹងរដ្ឋប្បវេណីបណ្តោះអាសន្ននេះ គឺត្រូវដាក់នូវបញ្ជីឈ្មោះសាក្សី និងភស្តុតាង និងឯកសារថ្មីៗបណ្តោះអាសន្នក្នុងរយៈពេល១៥ថ្ងៃគិតចាប់ពីថ្ងៃជូនដំណឹង ។ ទាក់ទងជាមួយដើមបណ្តឹងរដ្ឋប្បវេណីថ្មីដដែលនេះ គឺដើមបណ្តឹងរដ្ឋប្បវេណីថ្មីដែលមិនទាន់បានទទួលការទទួលស្គាល់បណ្តោះអាសន្ននេះនៅឡើយ ហើយដែលត្រូវបានប្រកាសទទួលស្គាល់ក្នុងអំឡុងពេលសវនាការបឋមក៏នឹងមានរយៈពេល១៥ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលនូវការជូនដំណឹងអំពីសេចក្តីសម្រេចទទួលស្គាល់ក្នុងការដាក់នូវបញ្ជីឈ្មោះបន្ថែមនេះ ។

ប៉ុន្តែ អង្គជំនុំជម្រះរបស់សាលាដំបូងសូមបញ្ជាក់ផងដែរថា ដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះអាចបោះបង់ចោលនូវសិទ្ធិនេះបាន ប៉ុន្តែភាគីផ្សេងទៀតនឹងទទួលនូវការជូនដំណឹងអំពីបញ្ជីឈ្មោះដែលបានទទួលនោះ ហើយនឹងទទួលបាននូវរយៈពេលសមស្រមក្នុងការឆ្លើយតបជាលាយលក្ខណ៍អក្សរ ។ នេះគឺជាការពន្យល់ត្រួសៗ ហើយខ្ញុំគិតថាអស់ប៉ុណ្ណឹងហើយ ។ ហើយខ្ញុំមិនដឹងថាប៉ុណ្ណឹងអាចយល់

00285916



ជ្រាបបានហើយឬនៅយ៉ាងណានោះទេ?

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោក ឡាវែន៍ ដែលបានធ្វើបទបង្ហាញជូនអង្គប្រជុំ ។ ពាក់ព័ន្ធជានឹងរបៀបវារៈ ចំណុច ៣ (ឃ) ។ ហើយទាក់ទិនជាមួយនឹងរបៀបវារៈនេះគឺ យើងខ្ញុំសូមផ្តល់វេទិកានេះជូនទៅភាគី ទាំងអស់ ដើម្បីធ្វើការពាក់ព័ន្ធ ជាការបញ្ចេញមតិយោបល់ជាការសំណួរ ឬក៏កត់សម្គាល់ផ្សេងៗ ។

ហើយជាដំបូងនេះគឺសូមអញ្ជើញផ្តល់វេទិកានេះជូនទៅភាគីមេធាវីអ្នកតំណាងដើមបណ្តឹង រដ្ឋប្បវេណី ដើម្បីឡើងធ្វើចំណាប់អារម្មណ៍ ឬធ្វើការកត់សម្គាល់ពាក់ព័ន្ធនឹងរបៀបវារៈដែលបានបង្ហាញ ដោយលោក ហ្សង់ ម៉ាកឡាវែន៍ ចុងក្រោយនេះ ។ សូមអញ្ជើញ ។

ដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីពុំមានទេ គឺសូមផ្តល់វេទិកានេះជូនទៅសហព្រះរាជ អាជ្ញា ។ តើមានអ្វីចង់កត់សម្គាល់ពាក់ព័ន្ធទៅនឹងរបៀបវារៈអម្បាញ់មិញនេះទេ? មិនមានទេគឺបន្តទៀត សូមផ្តល់វេទិកានេះទៅខាងមេធាវីការពារក្តីជនជាប់ចោទ ។ សូមអញ្ជើញ ។

**លោក ហ្រ្វង់ស្វ័រ រ៉ូ៖**

សូមអរគុណលោកចៅក្រមប្រធាន ។ មេធាវីការពារក្តីសុំសួរទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដែលមានវត្តមាននៅទីនេះ ថាតើពួកគាត់ទាំងអស់មានគំនិតយ៉ាងម៉េច យើងមានដឹងថាសាក្សីប៉ុន្មាននាក់ ដែលគាត់ចង់ដាក់ចូលមក? នេះជាសំណួរទី១ ។ ហើយសួរថាតើមេធាវីដើមបណ្តឹងរដ្ឋប្បវេណីលោក ពិចារណាឃើញថា តើនឹងអាចមានលទ្ធភាពឲ្យកូនក្តីគាត់ហ្នឹងនិយាយ ឬក៏ធ្វើសក្ខីកម្មហ្នឹងដែរឬទេ?

**ចៅក្រម ហ្សង់ ម៉ាកឡាវែន៍៖**

ខ្ញុំអាចនឹងឆ្លើយបានទាក់ទងជានឹងសំណួរចុងក្រោយ ដែលលោក ហ្រ្វង់ស្វ័រ រ៉ូ បានលើកឡើង នេះ គឺពាក់ព័ន្ធជានឹងសវនាការទៅលើកូនក្តី ហើយខ្ញុំគិតថារង់ចាំតែបន្តិចនឹងបានជ្រាបហើយ ព្រោះ នៅក្នុងរបៀបវារៈនៅក្រោយនឹងបន្តិច គឺនឹងឃើញការបំភ្លឺហើយ ។ ហើយពាក់ព័ន្ធនឹងចំនួនសាក្សីដែល នឹងមាន ខ្ញុំប្រហែលជាត្រូវសួរទៅខាងដើមបណ្តឹងរដ្ឋប្បវេណីឲ្យឆ្លើយតបទៅនឹងសំណួររបស់លោក ហ្រ្វង់ស្វ័រ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោក ហ្សង់ម៉ាក ។ ឥឡូវជូនវេទិកានេះទៅមេធាវីអ្នកនៅខាងតំណាងដើមបណ្តឹង រដ្ឋប្បវេណី ។ សូមអញ្ជើញ ។

**លោកស្រី ម៉ាកទីន ហ្សាកឃ្វីន៖**

នៅខាងភាគីរបស់ខាងខ្ញុំនេះ ខ្ញុំសូម--តាមពិតយើងនឹងមានបញ្ជូនសាក្សីតែតិចតួចទេ គឺមានត្រឹម ពីរបីនាក់ទេនៅក្នុងសេនារីយ៉ូរបស់យើង ។ នៅទីនេះសូមរក្សាសិទ្ធិផងដែរនៅក្នុងការនឹងបញ្ចូលសាក្សីថ្មីបន្ថែមទៀត ក៏ប៉ុន្តែនៅពេលបច្ចុប្បន្ននេះ ខ្ញុំគិតថាយើងនឹងមានសាក្សីតិចតួចទេនៅក្នុងការចូលរួមគិតថាមិនលើសពីពីរ-បីនាក់ប៉ុណ្ណឹងទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកស្រីមេធាវី ។ មានអស់លោក លោកស្រីណាចង់កត់សម្គាល់លើរបៀបវារៈដែលបានលើកឡើងដោយលោកចៅក្រម ហ្សង់ ម៉ាកឡាវែន៍ អម្បាញ់មិញនេះទេ? បើពុំមានទេ ខ្ញុំគិតថាពេលវេលាដល់ម៉ោងកំណត់ដែលត្រូវសម្រាកហើយ ។ ហើយឥឡូវសូមអញ្ជើញសមាជិកសមាជិកាអង្គប្រជុំសម្រាក ១៥នាទី ។ រហូតដល់ម៉ោង២និង៤០នាទី សូមអញ្ជើញអស់លោក លោកស្រី អ្នកនាងកញ្ញា ចូលសាលប្រជុំវិញដើម្បីបន្តកិច្ចប្រជុំរបស់យើង ។ សូមសម្រាកចុះ ។

*(កិច្ចប្រជុំសម្រាកពីម៉ោង១៤:២៣នាទី ដល់ម៉ោង ១៤:៤៦នាទី)*

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះយើងចាប់បន្តដំណើរកិច្ចប្រជុំរបស់យើងតទៅទៀត តាមរបៀបវារៈដែលបានគ្រោងទុក ហើយមុននឹងជូនវេទិកានេះទៅចៅក្រម ហ្សង់ម៉ាក ដើម្បីបន្តនូវ បង្ហាញនូវរបៀបវារៈដែលបានគ្រោងទុក ។ ខ្ញុំសូមធ្វើការកត់សម្គាល់ថា អម្បាញ់មិញនេះការ-- បទបង្ហាញរបស់លោក ហ្សង់ម៉ាកលើចំណុច (គ) ។ ដោយហេតុមានការពាក់ព័ន្ធទៅនឹងសំណួរ លោកស្រីមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានតាំងសំណួរ ហើយលោក ហ្សង់ម៉ាក បានធ្វើការឆ្លើយតបដោយយកខ្លឹមសារនៃចំណុច(គ), ៣ (គ) នេះ មកឆ្លើយបញ្ជាក់ ប៉ុន្តែគឺបាត់បង់នូវឱកាសនូវដល់ភាគីផ្សេងទៀតក្នុងការពិភាក្សា ឬក៏កត់សម្គាល់ទៅរបៀបវារៈចំណុច ៣ (គ) នេះ ។

អ៊ីចឹងដើម្បីជាឲ្យបានច្បាស់លាស់ ខ្ញុំសូមត្រឡប់ក្រោយបន្តិច គឺសូមអញ្ជើញលោក ហ្សង់ម៉ាកឡើងធ្វើបទបង្ហាញត្រង់ចំណុច ៣(គ) សិន រួចហើយសុំបន្តចំណុច ៣(ង) ដែលជាចំណុចចុងក្រោយរបស់បទបង្ហាញរបស់លោក ។ ហើយបន្ទាប់មកទៀត យើងខ្ញុំនឹងជូនវេទិកានេះជូនទៅភាគី និងអង្គភាពពាក់ព័ន្ធ ដើម្បីមានការកត់សម្គាល់ ឬក៏មានសំណួរ ឬក៏ចង់បញ្ចេញមតិអ្វីផ្សេងៗទាក់ទិនទៅនឹងរបៀបវារៈនេះ ។ សូមអញ្ជើញលោក ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ ម៉ាកឡាវែន៍៖**

សូមអរគុណលោកប្រធាន ។ ទាក់ទងទៅនឹងចំណុច ៣(ឃ) ទាក់ទងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីថ្មី ខ្ញុំចង់ធ្វើការបញ្ជាក់ថា ទាក់ទងទៅនឹងការអានវិធាន៣៩ គឺថាភាគីដើមបណ្តឹងរដ្ឋប្បវេណី ឬក៏សាក្សី ឬក៏អ្នកជំនាញថ្មីណា ដែលអាចដាក់មកបង្ហាញនៅក្នុងតុលាការ ដែលយើងយល់ថា ជាការមានអត្ថប្រយោជន៍ដល់ដំណើរការនីតិវិធីនោះ ។ ហើយនៅក្នុងពេលនេះមានន័យថា យើងត្រូវធ្វើការវាយតម្លៃឱ្យបានពិតប្រាកដ ថាតើនៅពេលណាដែលសាក្សីណាមួយ ឬក៏អ្នកជំនាញហ្នឹងធ្វើការបង្ហាញខ្លួនបាន?

ដូច្នេះហើយ ទើបខាងអង្គជំនុំជម្រះនឹងធ្វើការពិចារណាទៅលើចំណុចអស់ទាំងនេះ ថាតើវាអាចទាក់ទងទៅនឹងអង្គហេតុឬទេ? ឬក៏អង្គហេតុជាក់លាក់ណាមួយសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីចង់ធ្វើការបង្ហាញនោះ ដើម្បីរៀបចំដំណើរការនីតិវិធីនៃសវនាការនោះនៅក្នុងកម្រិតនៃពេលវេលាដែលយើងបានកំណត់ ដើម្បីសម្របសម្រួលដល់ការកំណត់កាលបរិច្ឆេទនោះ?

ដូច្នេះយើង-- ដើម្បីឱ្យយើងទទួលបាននូវការដាក់ពាក្យឱ្យបានឆាប់រហ័ស តាមដែលអាចធ្វើទៅបាន ។ ថាតើនៅពេលណាដែលពួកគេនឹងអាចកំណត់កាលបរិច្ឆេទនោះ? គឺការកំណត់នូវកាលបរិច្ឆេទនៃសវនាការ ដែលដើមបណ្តឹងរដ្ឋប្បវេណីហ្នឹងឯង ដែលចង់ឱ្យមានការបើកនូវសវនាការនោះ ។

**ប្រធានអង្គជំនុំ៖**

មុននឹងជូនវេទិកាទៅភាគី ខ្ញុំសូមបញ្ជាក់អ៊ីចេះថា ការកត់សម្គាល់របស់ខ្ញុំឃើញថាចំណុច ៣ (គ) នេះគឺលោក ហ្សង់ម៉ាក មិនទាន់បានធ្វើបទបង្ហាញច្បាស់លាស់នៅឡើយទេ ដោយសារលោកយកបទបង្ហាញមុននេះ ត្រូវបានឆ្លើយសំណួររបស់លោកស្រីមេធាវីតំណាងដើមចោទ ។

អ៊ីចឹងខ្ញុំសូមលោកធ្វើការបទបង្ហាញបន្ថែមទៀតលើចំណុច៣(គ) មុននឹងដាក់ជូនវេទិកានេះទៅដល់ភាគី ដើម្បីមានចំណាប់អារម្មណ៍ពាក់ព័ន្ធ ។ ដោយហេតុថា មានសារសំខាន់លើចំណុច ៣(គ) នេះ ហើយអម្បាញ់មិញនេះយើងបានរំលងនូវសិទ្ធិមួយក្នុងការកត់សម្គាល់របស់ភាគី ដែលអាចកត់សម្គាល់ពាក់ព័ន្ធនឹងរបៀបវារៈ ៣(គ) ។ សូមលោក ហ្សង់ ម៉ាក បង្ហាញលើចំណុច ៣(គ) ទៀត ។

**ចៅក្រម ហ្សង់ ម៉ាកឡាវែន៍៖**

តើលោកប្រធានចង់ឱ្យខ្ញុំធ្វើការពន្យល់ម្តងទៀតឬ? ខ្ញុំបានធ្វើការពន្យល់ទាក់ទងទៅនឹងប្រភេទដើមបណ្តឹងរដ្ឋប្បវេណីពីរប្រភេទ ទៅតាមអ្វីដែលយើងអាចធ្វើការបែងចែកក្នុងលក្ខណៈមិនផ្លូវការនោះ

គឺដើមបណ្តឹងរដ្ឋប្បវេណីដែលមាននៅពេលបច្ចុប្បន្ន និងដើមបណ្តឹងរដ្ឋប្បវេណីថ្មី គឺអ្នកដែល-- សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីថ្មី គឺថាជាអ្នកដែលដំណើរការនីតិវិធីស៊ើបអង្កេតនោះបានបញ្ចប់រួចហើយ ។ អ៊ីចឹងមានន័យថា គេត្រូវធ្វើការពិនិត្យឡើងវិញទៅលើសំណុំពាក្យដើមបណ្តឹងរដ្ឋប្បវេណីថ្មី ដែលទាក់ទងទៅនឹងវិធាន៨៣.១ គឺសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីថ្មី ។ អ៊ីចឹងគឺយើងនឹងធ្វើការជូនដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណីថ្មីនេះសម្រាប់ការទទួលស្គាល់ជាបណ្តោះអាសន្ន ឬមួយក៏យ៉ាងណានោះ ហើយការជូនការជូនដំណឹងអំពីការទទួលស្គាល់នោះ នឹងអាចទៅធ្វើបានដោយក្រឡាបញ្ជីនៅក្នុងអង្គជំនុំជម្រះសាលាដំបូង សម្រាប់សវនាការបឋម ។

អ៊ីចឹងការជូនដំណឹងនេះ នឹងក៏រួមបញ្ចូលផងដែរ នូវការជូនដំណឹងអំពីបញ្ជីដែលខាងសហព្រះរាជអាជ្ញាបានដាក់បញ្ជូនមកអង្គជំនុំជម្រះ ហើយនិងត្រូវជូនដំណឹង ។ ហើយពួកគេក៏ត្រូវដាក់នូវបញ្ជីសាក្សី ឬក៏ភស្តុតាងថ្មីរបស់ពួកគេផងដែរ ទៅតាមកាលកំណត់បរិច្ឆេទរយៈពេលពីរសប្តាហ៍ សម្រាប់ការដាក់បញ្ជូននូវបញ្ជីបន្ថែម ហើយនិងការជូនដំណឹងអំពីការដាក់ពាក្យបន្ថែមថ្មីរបស់ខាងសហព្រះរាជអាជ្ញានោះ សម្រាប់រយៈពេលពីរសប្តាហ៍ ។

ទោះបីយ៉ាងណាក៏ដោយសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីថ្មី ដែលមិនទាន់បានទទួល ការទទួលស្គាល់ជាបណ្តោះអាសន្ននោះ គឺថាមិនអាចទទួលបានទេនៅក្នុងសវនាការបឋម ។ ពួកគេគឺត្រូវមានរយៈពេល១៥ថ្ងៃ បន្ទាប់ពីបានទទួលការជូនដំណឹងអំពីសេចក្តីសម្រេចក្នុងការទទួលស្គាល់នូវបញ្ជីថ្មីដែលពួកគេនឹងរៀបចំនោះ ។

ហេតុដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីថ្មីនោះគឺអាចមានសិទ្ធិ ដកចោលនូវសិទ្ធិនេះផងដែរ ។ ប៉ុន្តែការដកសិទ្ធិចេញនេះ គឺត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយបញ្ជី-- នៅពេលដែលបញ្ជីនោះត្រូវបានដាក់បញ្ជូននៅក្នុងសំណុំរឿងហើយៗនុ៎ង គឺនឹងត្រូវមានការជូនដំណឹងទៅឲ្យខាងសហព្រះរាជអាជ្ញា និងខាងមេធាវីការពារក្តី ហើយក្រោយមកនឹងត្រូវមានឱកាសដែលមានការកំណត់មួយ ដើម្បីធ្វើការឆ្លើយតប ។

ហើយខ្ញុំចង់រំលឹកផងដែរថា នៅក្នុងសវនាការបឋមនោះ គឺដើម្បីធ្វើការសម្រេចទៅលើបញ្ជីសាក្សី ។ អ៊ីចឹងហើយគឺថា យើងត្រូវមានការដាក់ពាក្យពីភាគីពាក់ព័ន្ធទាំងអស់ ហើយនិងបញ្ជីឈ្មោះទាំងអស់ ដើម្បីឲ្យយើងធ្វើសេចក្តីសម្រេច ។

អ៊ីចឹងខ្ញុំសង្ឃឹមថា គឺថាខ្ញុំបានពន្យល់ច្បាស់លាស់ហើយអំពីចំណុចនេះ ។

**ប្រធានអង្គជំនុំ៖**

អាចច្រឡំបន្តិច អាចច្រឡំចំណុច ៣(ឃ) ។ ខ្ញុំកត់សម្គាល់ឃើញថា មិនបានធ្វើបទបង្ហាញ ។ ចំណុច ៣(គ) *ប៊ី ស៊ី, ស្រ៊ីស៊ី* ៣(គ) មិនមែន ៣(ឃ) ទេ ។ បញ្ហានេះគឺថាមានការភ័ន្តច្រឡំអម្បាញ់មិញនេះ គឺលោក ហ្សង់ម៉ាក បានឆ្លើយតបទៅនឹងសំណួរតែម្តង ដែលពាក់ព័ន្ធជាមួយនឹងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសួរ ដោយសារធ្វើបទបង្ហាញនូវចំណុចទី ៣(ខ) ដល់សំណួរសួរដល់ទៅពាក់ព័ន្ធនឹងចំណុច ៣(គ) ។ អ៊ីចឹងគាត់ឆ្លើយតែម្តង ។

អ៊ីចឹងមិនបានផ្តល់ឱកាសនេះជូនទៅដល់ភាគីពាក់ព័ន្ធផ្សេងទៀតដើម្បីធ្វើការកត់សម្គាល់ ឬក៏ធ្វើការចាប់អារម្មណ៍បញ្ចេញមតិយោបល់ពាក់ព័ន្ធនឹងរបៀបវារៈត្រង់ចំណុច ៣.គ ទេ ។

អ៊ីចឹងខ្ញុំសូម-- ឱកាសនេះគឺសូមអញ្ជើញលោក ហ្សង់ ម៉ាក ធ្វើការបង្ហាញជូនអង្គប្រជុំបន្ថែមលើចំណុច ៣(គ) មិនមែន ៣(ឃ) ទេ ។ គឺចំណុចត្រូវដោះស្រាយជាមួយជាមួយសាក្សីបន្ថែមយ៉ាងដូចម្តេច? បើសាក្សីនោះមិននៅក្នុងសំណុំរឿង ដោយការនេះគឺបំណងចង់ឲ្យពាក់ព័ន្ធទៅនឹងភាគីទាំងអស់ដែលនៅក្នុងអង្គប្រជុំនេះមានឱកាសដើម្បីធ្វើចំណាប់អារម្មណ៍ ឬក៏កត់សម្គាល់ពាក់ព័ន្ធទៅនឹងរបៀបវារៈនេះ ពីព្រោះអម្បាញ់មិញនេះយើងមិនបានផ្តល់ឱកាសទៅដល់ភាគីពាក់ព័ន្ធផ្សេងទៀតធ្វើចំណាប់អារម្មណ៍អំពីប្រធានបទ ៣(គ) ទេ ។

**ចៅក្រម ហ្សង់ ម៉ាកឡាវែន៖**

អ៊ីចឹងខ្ញុំថាមតិយោបល់ហ្នឹង គឺថាបានលើកឡើងម្តងរួចហើយទាក់ទងទៅនឹងមេធាវីនោះ ។ អ៊ីចឹងចំណុចនេះទាក់ទងទៅនឹងសាក្សីបន្ថែមទៀតដែលមិនមានឈ្មោះនៅក្នុងសំណុំរឿង ឬក៏មិនមាននៅក្នុងដីកាដំណោះស្រាយ ហើយមានន័យថា នៅពេលដែលមានផ្តល់បញ្ជីសាក្សីថ្មីបែបនោះ គឺទាក់ទងទៅនឹងវិធាន៨០ មានន័យថាអាចនឹងរួមបញ្ចូលនូវរាល់បុគ្គលទាំងអស់ភាគីមានបំណងកោះហៅ ដើម្បីផ្តល់នូវភស្តុតាងក្នុងអំឡុងពេលសវនាការ ទាក់ទងនឹងអង្គហេតុដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយមិនគិតពីចរិតលក្ខណៈផ្លូវច្បាប់នៃអង្គហេតុទាំងនោះ ។ សាក្សីដែលបានស្នើឡើងនោះ អាចជាសាក្សីដែលបានស្តាប់ចម្លើយរួចហើយ ក្នុងដំណាក់កាលស៊ើបអង្កេត ព្រមទាំងបុគ្គលផ្សេងទៀត ដែលមិនទាន់បានស្តាប់ចម្លើយរហូតមកទល់ពេលនេះ ។

តើថាសាក្សីទាំងនោះមិនមានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឬទេ?

00285921



**ប្រធានអង្គជំនុំ៖**

អរគុណដល់ចំពោះលោកចៅក្រម ហ្សង់ ម៉ាក ដែលបានធ្វើបទបង្ហាញបន្តបញ្ចប់នូវរបៀបវារៈ ដែលជាភារៈកិច្ច ដែលយើងខ្ញុំបានផ្ដល់ជូន ហើយព្រមទាំងមានការបង្ហាញបន្ថែមទៀតនូវចំណុច៣(គ) របៀបវារៈ ដើម្បីឲ្យច្បាស់លាស់ និងជាឱកាសផ្ដល់ជូនវេទិកានេះជូនទៅភាគីដែលពាក់ព័ន្ធ ដើម្បីធ្វើការកត់សម្គាល់ ឬក៏មានចំណាប់អារម្មណ៍ផ្សេងៗពាក់ព័ន្ធទៅនឹងរបៀបវារៈដែលបង្ហាញទៅដោយលោក ហ្សង់ ម៉ាក នេះ ។ ជាពិសេស គឺរបៀបវារៈ ៣(គ) ហើយនិង ៣(ង) ចុងក្រោយ ។

ហើយខ្ញុំសូមជម្រាបផងដែរថា នេះក៏ជាឱកាសល្អមួយសម្រាប់កិច្ចពិភាក្សានិងផ្លាស់ប្ដូរគ្នារវាងភាគីទាំងអស់នៃរឿងក្ដី និងអង្គភាពពាក់ព័ន្ធ ដើម្បីសម្របសម្រួលធ្វើយ៉ាងណានៅក្នុងកិច្ចដំណើរការសវនាការរឿងក្ដីដំបូងនេះប្រព្រឹត្តទៅបានល្អ បានឆាប់រហ័ស ហើយនិងប្រកបដោយយុត្តិធម៌ ។

អ៊ីចឹងគឺដើម្បីទុកឱកាសនេះបានច្រើន គឺខ្ញុំសូមប្រគល់ជូនវេទិកានេះទៅដល់ភាគី ដើម្បីមាន-- ឡើងធ្វើចំណាប់អារម្មណ៍ ឬក៏កត់សម្គាល់អំពីរបៀបវារៈដែលបង្ហាញឡើងដោយ ហ្សង់ ម៉ាក ។ ជាពិសេសគឺចំណុចរបៀបវារៈចុងក្រោយពីរដែលបានលើកឡើងអម្បាញ់មិញនេះ ។

សូមអរគុណ ។ ហើយជាដំបូងនេះ គឺសូមអញ្ជើញមេធាវីភាគីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី តើមានអ្វីចង់កត់សម្គាល់ ឬក៏មានការពាក់ព័ន្ធទៅនឹងរបៀបវារៈពីរចុងក្រោយដែលបង្ហាញអម្បាញ់មិញនេះទេ? ឬក៏របៀបវារៈផ្សេងក៏បានដែរ ទោះបីរំលងហើយក៏ដោយក៏យើងមានឱកាស ។ សូមអញ្ជើញលោកមេធាវី ។

**លោក គឹម ម៉េងឃី៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំឡើងមកនេះខ្ញុំមានសំណួរសួរពាក់ព័ន្ធទៅនឹងការជ្រើសរើសភាសានៅក្នុងការជូនដំណឹង គឺមានការជ្រើសរើសភាសាខ្មែរនិងភាសាបារាំង ។ ឧទាហរណ៍ ខ្ញុំជ្រើសរើសយកភាសាពីរ គឺភាសាខ្មែរ និងភាសាបារាំងក្នុងការជូនដំណឹង ។ អ៊ីចឹងខ្ញុំចង់សួរថា តើរយៈពេលកំណត់នៃ-- ចង់និយាយថា *ដេតឡាញ* របស់ភាសាណាមួយដែលត្រូវយកមកប្រើ? ឧទាហរណ៍បើសិនជាភាសាដែលខ្ញុំជ្រើសរើសហ្នឹងគឺមានភាសាពីរដូច្នេះ ។ គឺចង់សួរថាតើកាលបរិច្ឆេទកំណត់បន្ទាប់ពីការជូនដំណឹងហ្នឹង គិតពីការជូនដំណឹងជាភាសាខ្មែរ ឬក៏ការជូនដំណឹងជាភាសាបារាំង? សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណ លោកមេធាវី ខ្ញុំផ្ដល់វេទិកានេះ ជូនលោក ហ្សង់ ម៉ាក ឆ្លើយនឹងសំណួរនេះ ។

**ចៅក្រម ហ្សង់ ម៉ាកឡាវែន៖**

ខ្ញុំគិតថា ទាក់ទងទៅនឹងគោលការណ៍នៃការណែនាំនោះ គឺថាភាគីនីមួយៗត្រូវធ្វើការកំណត់ថា តើភាសាណាដែលគេកំណត់ដើម្បីធ្វើការជូនដំណឹងនោះ ។ អ៊ីចឹងជាការច្បាស់ណាស់សម្រាប់ខ្ញុំដែលថា ការបកប្រែភាសា ទៅក្នុងភាសា នៅពេលដែលមិនមាននោះ គឺថា ការជូនដំណឹងហ្នឹងត្រូវតែកំណត់ជាភាសា ។ ជួនកាលវាមានការលំបាលណាស់ ក្នុងការឲ្យដំណើរការនោះមានប្រសិទ្ធភាពទៅតាមអ្វីដែលយើងចង់បាននោះ ។ ពីព្រោះពិបាកក្នុងការបកប្រែអ្វីៗទាំងអស់នោះ ជាភាសាផ្សេងៗទៀត ។ យ៉ាងណាមិញខ្ញុំចង់ធ្វើការបញ្ជាក់ទៅលើចំណុចមួយដែលថា គឺថាភាគីទាំងអស់ហ្នឹងគឺថា នឹងមានការទន្ទឹងរង់ចាំទៅលើសំណើនៃការបប្រែនោះ ។ មានន័យថា កិច្ចការរបស់តុលាការមានការដើរស្រួលនៅពេលដែលផ្នែកបកប្រែរបស់តុលាការ អង្គភាពបកប្រែមានដំណើរមានប្រសិទ្ធភាពនោះ ។

អ៊ីចឹងមានន័យថាគឺថាយើងត្រូវផ្ញើរសំណើបកប្រែហ្នឹងទៅឲ្យអង្គភាពបកប្រែហ្នឹងឲ្យបានលឿននៅតាមការគួរ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោក ហ្សង់ ម៉ាក ដែលបានធ្វើការឆ្លើយតបទៅនឹងសំណួរដែលបានសួរ ។ ជាបន្តទៅទៀតគឺសូមអញ្ជើញសហព្រះរាជអាជ្ញា មានអ្វីចង់បញ្ចេញមតិយោបល់ ឬក៏កត់សម្គាល់នូវបទបង្ហាញដែលពាក់ព័ន្ធនឹងបទបង្ហាញចុងក្រោយនេះទេ?

សូមអញ្ជើញលោកស្រី ។

**លោកស្រី ជា លាង៖**

ដូចជាមិនមានទេ ប៉ុន្តែខ្ញុំហាក់ដូចជាមិនយល់ច្បាស់អំពីបញ្ហានៅ *ស្តេតដ្យូល* នេះទេ ដោយសារមានការវិលងទៅវិលងមក ធ្វើឲ្យខ្ញុំវិលវល់នូវបញ្ហាហ្នឹងដែរ ។ ខ្ញុំស្តាប់ពីដំបូងមិញនិយាយពីអាសាក្សីថ្មីអត់ទាន់មាននៅក្នុងសំណុំរឿង ឬក៏អត់ទាន់មាននៅក្នុងដីកាដំណោះស្រាយ ។ ខ្ញុំត្រឡប់មួយសន្ទុះមកស្រាប់មកដល់និយាយអំពីភស្តុតាងថ្មីវិញ ។ ដូច្នេះ វាមានការវិលទៅវិលមក បញ្ហានេះខ្ញុំពិបាកយល់បន្តិច ។

អ៊ីចឹងហើយខ្ញុំ នៅក្នុងនេះ ខ្ញុំប្រហែលជាខ្ញុំមាន-- អានេះថ្មីមិនដឹង ចាស់មិនដឹង ខ្ញុំមិនដឹងដែរ ហើយខ្ញុំអត់មាន ក ខ គ ដូចលោកប្រធានលើកឡើងនោះទេ ។ អ៊ីចឹងចំណុចនេះ កន្លែងនេះដែលធ្វើឲ្យខ្ញុំពិបាកយល់បន្តិចចំណុចដែលសួរសំណួរនេះ ហើយខ្ញុំមិនបានយល់ច្បាស់អំពីបញ្ហានេះ ។ ចំពោះ

ចំណាប់អារម្មណ៍របស់ខ្ញុំ ដែលលោកចៅក្រម ឡាវ៉ែន៍ គាត់បានលើកឡើងនោះ ខ្ញុំមិនមានបញ្ហាអីទេ ហើយគិតឃើញថា គាត់លើកឡើងនេះជាលក្ខណៈមួយដែលសមស្រប ហើយមានចែងនៅក្នុងនីតិវិធីកម្ពុជាផងដែរ ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកស្រី សហព្រះរាជអាជ្ញា ។ ខ្ញុំសូមមានចំណាប់អារម្មណ៍អ៊ីចេះថា វាមានហេតុផលបញ្ហាមែនពិត មិនមែនបញ្ហាតែអស់លោក លោកស្រីទេ សូម្បីតែបញ្ហាខ្ញុំខ្លួនឯងផ្ទាល់ក៏មានបញ្ហាដែរ ។ ដោយហេតុអ៊ីចេះ យើងកំណត់កាលបរិច្ឆេទចុងក្រោយនៃការដាក់របៀបវារៈបន្ថែមហ្នឹង គឺវាពេលវេលាខ្លី របៀបវារៈបន្ថែមមកអង្គប្រជុំនេះ ។ យើងមានពេលវេលាខ្លីណាស់ ដល់ពេលបន្ថែមរបៀបវារៈហ្នឹងគឺមានរហូតដល់ទៅច្រើនរបៀបវារៈដែលត្រូវបន្ថែម ដែលស្នើដោយសហព្រះរាជអាជ្ញា និងដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។

អ៊ីចឹងដោយសារអំឡុងពេលខ្លី ដើម្បីត្រៀមរៀបចំហ្នឹង គឺយើងធ្វើការប្រជុំពិភាក្សាគ្នាជាប់ជាប្រចាំប៉ុន្មានថ្ងៃចុងក្រោយនេះ ។ យើងទើបតែចប់ម្សិលមិញល្ងាចម៉ោងប្រាំ ម៉ោងបួនកន្លះ ម៉ោងប្រាំទើបចេញពីនេះទៅ ។ អ៊ីចឹងយើងបន្តកិច្ចការនេះនៅពេលប្រថិតប្រថោយនៅចុងម៉ោង ម៉ោងប្រាំ ម៉ោងប្រាំមួយហើយ បានយើងធ្វើកិច្ចការនេះ ។ អ៊ីចឹងហើយបានជាអាចមានបញ្ហារបៀបវារៈបន្ថែមនេះដែលនាំឲ្យមានបញ្ហា ។

ទីពីរខ្ញុំបានបង្ហាញថា ទទួលស្គាល់ដែរអំពីបញ្ហាអម្បាញ់មិញនេះ ដោយសារខ្ញុំបារម្ភអំពីបញ្ហាកង្វះខាតនៅក្នុងការបទបង្ហាញ ពីព្រោះការបទបង្ហាញត្រង់ចំណុច(ខ) ៣(ខ) ស្រាប់តែលោកស្រីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គាត់សួរពាក់ព័ន្ធនឹងសំណួរ ៣(គ) ។ ដល់ ៣(គ) អ៊ីចឹងលោក ហ្សង់ម៉ាក ក៏ឆ្លើយ៣(គ) ទៅ ។ អ៊ីចឹងវាចប់ដោយសារគាត់ឆ្លើយអ៊ីចឹងហើយគាត់ចាប់ផ្តើតចំណុច (ឃ)ទៅទៀតទៅ ។ អ៊ីចឹងខ្ញុំមិនមានឱកាសពាក់ព័ន្ធទៅដល់ភាគីផ្សេងទៀត ចង់បញ្ចេញមតិយល់បល់ពាក់ព័ន្ធជាមួយនឹង ៣(គ) ហ្នឹងទេ ។ ហើយចំណែកឯកិច្ចប្រជុំរបស់អង្គជំនុំជម្រះសាលាដំបូង គឺធ្វើច្រើន លើកច្រើនថ្ងៃ ដូចមានការតឹងតែងក្នុងការជជែករកដំណោះស្រាយឆ្លើយតបទៅនឹងរបៀបវារៈបន្ថែមនេះ ។ ប៉ុន្តែ ដល់កិច្ចប្រជុំយើងមកហាក់ដូចជាបញ្ហាហ្នឹងជាមិនធ្ងន់ធ្ងរដូចអ្វីដែរអង្គប្រជុំ អង្គជម្រះសាលាដំបូងធ្វើកិច្ចប្រជុំជជែកដើម្បីរកដំណោះស្រាយនោះទេ ។ នេះជាបញ្ហា ដែលអាចមានបញ្ហាអ៊ីចឹងមែន ។ នេះដោយសារមានការប្រែប្រួលថ្មី ហើយពេលវេលាដែលយើងខ្វះបទពិសោធន៍ យើងបានកំណត់ខ្លីពេក

ដែលទទួលនូវរបៀបវារៈបន្ថែម ដើម្បីមកបំពេញបង្គ្រប់ ហើយជម្រាបឆ្លើយតបរកដំណោះស្រាយតបទៅនឹងសំណូមពរ ឬក៏សំណើសុំ ឬក៏សំណួររបស់ភាគីនៅក្នុងកិច្ចប្រជុំនេះ ។

ជាចុងក្រោយនេះគឺសូមអញ្ជើញលោកមេធាវីការពារជនជាប់ចោទមានសំណួរ ឬក៏មានការកត់សម្គាល់អ្វីទៅលើរបៀបវារៈចុងក្រោយនេះទេ?

**លោក ហ្រ្វង់ស្វ័រ រូ៖**

លោកចៅក្រម សូមអរគុណ ទៅលើចំណុចចុងក្រោយនៅលើរបៀបវារៈនោះ គឺថាយើងមិនបាន-- ខ្ញុំអត់មានមតិយោបល់អីទេ ទៅលើដើមបណ្តឹងរដ្ឋប្បវេណីថ្មី ។ ប៉ុន្តែ ខ្ញុំក៏អាចលើកនិយាយបន្ថែមទាក់ទិនទៅនឹងព័ត៌មានដែលខ្ញុំបាននិយាយពីមុន ទាក់ទងទៅនឹងសាក្សីដែលខាងមេធាវីការពារក្តីយើងខ្ញុំនេះ ចង់ឲ្យផ្តល់សក្ខីកម្មតាមរយៈការធ្វើតាម *វីដេអូ* ។ មានន័យថា គឺទាមទារប្រតិចារឹកនៃការធ្វើការផ្តល់សក្ខីកម្មនោះ ។ មានន័យថា គឺជាការថតជារបៀប*វីដេអូ*ខ្លីមួយ ប៉ុន្តែ តើយើងអាចចាត់ទុកវាថា នេះជាឯកសាររបស់សាក្សីនោះបានឬក៏យ៉ាងម៉េច? គឺយើងយល់ថា ជាការសំខាន់ណាស់ក្នុងការចាក់បង្ហាញ*វីដេអូ* បើសិនជាសក្ខីកម្មបែបនោះអាចធ្វើបាន ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណ នូវការកត់សម្គាល់របស់លោកមេធាវីការពារជនជាប់ចោទ ។ ឥឡូវនេះគឺមានសំណួរ ឬក៏មានបញ្ហាអីពាក់ព័ន្ធផ្សេងទៀតទេ?

សូមអញ្ជើញលោកមេធាវី ។

**លោក គង់ ពិសី៖**

ពាក់ព័ន្ធទៅនឹងសាក្សីដែលមេធាវីការពារបានលើកឡើងថា សុំឲ្យថត*វីដេអូ* ។ អាហ្នឹងក៏ជាការម្យ៉ាងដែរ ក៏ប៉ុន្តែនៅពេលដែលភាគីផ្សេងៗត្រូវការសួរដេញដោល អ៊ីចឹងសាក្សីហ្នឹងគាត់មកតែរូបភាព *វីដេអូ* នៅពេលហ្នឹងភាគីផ្សេងៗទៀតត្រូវការសួរដេញដោល អត់មាន-- មិនអាចមានលទ្ធភាពនៅក្នុងការសួរដេញដោលបាន ។ អ៊ីចឹងគួរតែឲ្យដឹងថា តើគាត់នឹងសួរសំណួរអី ដើម្បីឲ្យខាងភាគីផ្សេងៗទៀតគេនឹងមានលទ្ធភាពអាចសួរដេញដោលបាន ។ នេះជាសំណូមពររបស់ខ្ញុំ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណ លោកមេធាវីដែលបានធ្វើកត់សម្គាល់ដូច្នេះ ។ សូមអញ្ជើញ!

**លោក ហ្វេង់ស្វ័រ រូ៖**

សូមអរគុណ លោកចៅក្រម ។ ទាក់ទងជាមួយនឹងចំណុចនេះ ខ្ញុំសូមចែកជូននូវព័ត៌មាន ឬឯកសារដែលទាក់ទងជាមួយនឹង *អុប្រ៊ីណូវិច ខេស* ហើយខ្ញុំនៅទីនេះ ខ្ញុំចង់ឲ្យយក *វីដេអូ*ហ្នឹងយកមកចាក់បញ្ចាំងនៅក្នុងសវនាការ គឺគេធ្លាប់ធ្វើហើយ គឺបានន័យថា បើសិនជាយើងបង្ហាញរូបថត *វីដេអូ*ហ្នឹង យើងមិនអាចនឹងធ្វើការជជែកដេញដោល ឬតាំងសំណួរបានមែន ព្រោះរូបវាគ្រាន់តែជារូប *វីដេអូ* ក៏ប៉ុន្តែនៅក្នុងហ្នឹងយើងបានទទួលព័ត៌មានពី *វីដេអូ*ហ្នឹងមិនលែងទេ
ជាប្រយោជន៍ដល់សវនាការផងដែរ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ហ្សង់ ម៉ាក ។

**ចៅក្រម ហ្សង់ ម៉ាកឡាវ៉ែន៍៖**

ខ្ញុំសុំអាននូវសំណួរដែលយើងអានពីព្រឹកមិញទាក់ទងជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី ឬក៏ភាគី ។ ជាទូទៅគឺនៅពេលដែល-- ព្រឹកមិញលោកបាននិយាយទាក់ទងជាមួយនឹងគំនិតដែលលើកដោយដើមបណ្តឹងរដ្ឋប្បវេណី-- ភាគី ទាក់ទងជាមួយនឹងសំណើសុំឲ្យមានការធ្វើការបញ្ជាក់បន្ថែម ហើយដោយសារនៅក្នុងពេលឥឡូវនេះ គឺអង្គជំនុំជម្រះសាលាដំបូង គឺមិនទាន់មានជំហរដែលអាចនឹងឆ្លើយតបទៅនឹងចំណុចនោះនៅឡើយ គឺយើងមិនទាន់មានឯកសារគ្រប់គ្រាន់នឹងអាចពិភាក្សា ឬក៏សម្រេចបាននៅពេលនេះនៅឡើយទេ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកចៅក្រម ។ ប្រសិនបើមិនមានអ្វីទៀតទេ គឺកិច្ចប្រជុំនៅរសៀលនេះ គឺដោយហេតុនៃការលឿន ជឿនលឿននៃដំណើរការប្រព្រឹត្តទៅនៃកិច្ចប្រជុំ ដែលលឿនជាងអ្វីដែលយើងបានគ្រោងទុក ។ អ៊ីចឹងទេ គឺខ្ញុំសូមរំឭកដល់អស់លោក លោកស្រី ដែលមកពីអង្គភាពពាក់ព័ន្ធ ដែលមកពីអង្គភាពការិយាល័យរដ្ឋបាល ឬក៏ *ស៊ីអ៊ីមអេស* ដែលត្រូវធ្វើបទបង្ហាញនៅថ្ងៃស្អែក ដែលថ្ងៃស្អែកនេះគឺមានគ្រោងទុកគឺយើងធ្វើមួយថ្ងៃ ប៉ុន្តែតាមការគណនាអំពីពេលវេលា និងរបៀបវារៈដែលនៅសេសសល់ យើងប៉ានស្មានទៅឃើញថា មួយព្រឹកទៀតយើងនឹងអស់ហើយ ។

អ៊ីចឹងខ្ញុំសូមជម្រាបជូនដំណឹង ដោយសារអង្គជំនុំជម្រះសាលាដំបូងរក្សាសិទ្ធិក្នុងការកែប្រែសម្របសម្រួលនូវរបៀបវារៈនៃកិច្ចប្រជុំនេះ ។ អ៊ីចឹងគឺរបៀបវារៈកិច្ចប្រជុំទាំងអស់នៅសេសសល់គឺយើងយកមកធ្វើនៅព្រឹកថ្ងៃស្អែកតាមលំដាប់បន្តបន្ទាប់នៃរបៀបវារៈដែលបានគ្រោងទុក ។

អ៊ីចឹងសូមអញ្ជើញអស់លោក លោកស្រី ដែលមានភារៈក្នុងការធ្វើបទបង្ហាញទាក់ទិនជាមួយនឹងរបៀបវារៈដែលត្រូវធ្វើថ្ងៃស្អែក គឺសូមអញ្ជើញមកធ្វើនៅពេលព្រឹកទាំងអស់គ្នា ។ ដោយពេលវេលាក៏នេះហើយដែរ ហើយរបៀបវារៈដែលត្រូវជជែកវែកញែកនាថ្ងៃនេះគឺឃើញថាចប់សព្វគ្រប់ហើយ ។

ដូច្នេះគឺថ្ងៃនេះ យើងប្រកាសសម្រាកត្រឹមប៉ុណ្ណេះ ហើយកិច្ចប្រជុំនឹងបន្តទៀតនៅថ្ងៃស្អែក ចាប់វេលាម៉ោងប្រាំបួនព្រឹក ។ ដូច្នេះ សូមអញ្ជើញលោក លោកស្រី នាងកញ្ញាទាំងអស់ចូលរួមប្រជុំ ចូលមកកាន់សាលប្រជុំនេះឲ្យបានមុនម៉ោងប្រាំបួនព្រឹក នៅថ្ងៃស្អែកដើម្បីបន្តកិច្ចប្រជុំរបស់យើង ។

អ៊ីចឹងខ្ញុំសូមប្រកាសសម្រាកប៉ុណ្ណេះ ហើយអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ ហើយបង្គាប់លោកឲ្យនាំគាត់មកកាន់សាលប្រជុំនេះវិញ ឲ្យបានមុនម៉ោងប្រាំបួនព្រឹកថ្ងៃស្អែក ក្នុងករណីដែលគាត់មានបំណងចូលរួមក្នុងកិច្ចប្រជុំនេះ ។ ប្រសិនបើគាត់មិនមានបំណងចង់ចូលរួមក្នុងកិច្ចប្រជុំនេះទេ សូមអនុរក្សមន្ទីរឃុំឃាំងមិនចាំបាច់នាំខ្លួនគាត់មកទេ ៕

*(កិច្ចប្រជុំសម្រាកនៅម៉ោង១៥:១៣នាទី)*